ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jan-2016, 11:55
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៣៦២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធ្យូ ម៉ាកាធី *(Mr.Matthew Mccarthy)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ដួង អឿន (2-TCCP-869) | ខ្មែរ |
| លោក ព្រុំ សារ៉ាត (2-TCP-1009) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ដួង អឿន/ ឌិន អឿន** (2-TCCP-869)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី .................................................................... ទំព័រ ៣
សួរដោយលោក ពេជ អង្គ ផ្តើមពី .................................................................... ទំព័រ ៦
សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី.................................................... ទំព័រ ១៦
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី .................................................................... ទំព័រ ៣៤
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.................................................................... ទំព័រ ៣៩
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី................................................................ ទំព័រ ៤៩
សួរដោយលោក ពេជ អង្គ ផ្តើមពី .................................................................... ទំព័រ ៥៣

**ការសួរសំណួរទៅសាក្សី៖ លោក ព្រុំ សារ៉ាត** (2-TCP-1009)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី .................................................................... ទំព័រ ៥៧
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.................................................................... ទំព័រ ៥៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCW-869 -- TCCP-869 ហើយការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមានលោកស្រី ទេព ធីតា ជាបុគ្គលិកអង្គការ ធី.ភី.អូ នៅអង្គុយអមដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលដែលគាត់ផ្ដល់សក្ខីកម្ម។ ហើយមុននឹងដំណើរការសវនាការពិភាក្សាស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅថ្ងៃនេះអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី នៅក្នុងដំណើរការសវនាការនេះរឿងក្ដីនេះថា នៅថ្ងៃនេះ និងនៅថ្ងៃបន្តបន្ទាប់អាចលោកចៅ-- នឹងអាចនៅថ្ងៃបន្តបន្ទាប់ លោកចៅក្រមយូរ ឧត្តរា ដែលជាចៅក្រមជាតិ លោកអវត្តមានដោយមូលហេតុមានធុរៈចាំបាច់ផ្ទាល់ខ្លួន មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្ដាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចចាត់តាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមខាងភាគីជាតិ ជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលអវត្តមាន ហើយរហូតដល់ពេលណាដែលចៅក្រម យូរ ឧត្តរា មានវត្តមាន និងមានលទ្ធភាពអាចចូលរួមបំពេញការងារនៅក្នុងកិច្ចដំណើរការសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។

ហើយការសម្រេចនេះដោយផ្អែកលើតាមបទប្បញ្ញត្តិនៃវិធាន ៧៩(៤) នេះវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហើយថ្ងៃនេះក៏ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ចៅក្រមអន្តរជាតិក៏មានវត្តមានវិញដែរ។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ លើកលែងតែមេធាវីជាតិការពារក្ដីឲ្យលោក ខៀវ សំផន បាន

ជូនដំណឹងមកថានឹងអវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCCP-869។ ដើមបណ្តឹងមានវត្តមាននៅបន្ទប់រង់ចាំៗការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-1009 សាក្សីបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅព្រឹកនេះ។ ហើយសាក្សីមានមេធាវីប្រឹក្សា គឺលោក មឿន សុវណ្ណ។

សូមអរគុណ លោកប្រធាន។

[០៩:០៧:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ កញ្ញាជា ស៊ីវហ័ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។ បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក

នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។ ហើយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោត-ទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ហើយជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-869រួមទាំងបុគ្គលិកនៃអង្គការធី.ភី.អូ ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

យ៉ាងម៉េចទៅមានៗវត្តមានទេ? ហើយជា ស៊ីវហ័ង សម្របសម្រួល!

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:១១:៤១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអ្វី? លោកស្រីកុំអាលទាន់ឆ្លើយតប រង់ចាំ បង្អង់បន្តិចទៅ ហើយចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យភ្លើងសញ្ញាក្រហមជាមុនសិន សឹមលោកស្រីឆ្លើយតប។ លោកស្រីឈ្មោះអ្វី?

**លោកស្រី ដួង អឿន៖**

**ឆ៖** ឈ្មោះ អឿន។

**ស៖** ឈ្មោះត្រកូនអីទៅ អ៊ំអឿន ឈ្មោះអី ត្រកូលឈ្មោះអ្វីទៅ?

**ឆ៖** ដួង អឿន។

**ស៖** ម្តងទៀត លោកស្រី ត្រកូលរបស់លោកស្រីឈ្មោះអ្វី?

**ឆ៖** ដួង អឿន។

**ស៖** ឈ្មោះ ដួង អឿន! អ៊ីចឹងមែនទេ?

[០៩:១៣:០៤]

**ឆ៖** ចាស ឈ្មោះ ដួង អឿន។

**ស៖** នៅក្នុងឯកសារ គឺមានឈ្មោះមួយទៀតថាឈ្មោះ ឌិន អឿន យ៉ាងម៉េចទៅ ឌិន អឿន នេះ?

**ឆ៖** ឌិន អឿន ក៏បាន។

**ស៖** ចាំបន្តិច លោកស្រីចាំអង់ៗតិច ស្ដាប់សំណួរហើយ បង្អង់បន្តិចរង់ចាំក្បាលមីក្រូហ្វូនហ្នឹងឲ្យភ្លើងសញ្ញាណក្រហមសឹមឆ្លើយ។ ឆ្លៀតឱកាសហ្នឹង គឺលោកស្រីអាចគិតពីសំណួរដែលអ្នកសួរហ្នឹងថាតើត្រូវឆ្លើយតបនឹងសំណួរហ្នឹង តាមអ្វីដែលត្រឹមត្រូវ ច្បាស់លាស់ ហើយនិងពេញទៅនឹងចម្លើយតបទៅនឹងសំណួរណ៎ះ! បាទ ឥឡូវឈ្មោះប្រើផ្លូវការដែលនៅក្នុងអត្ត -- ធ្វើអត្តសញ្ញាណប័ណ្ណពលរដ្ឋខ្មែរ លោកស្រីប្រើឈ្មោះស្អីមួយ ក្នុងចំណោមឈ្មោះពីរនេះ?

**ឆ៖** ដួង អឿន។

**ស៖** លោកស្រីកើតនៅថ្ងៃឆ្នាំណា ខែឆ្នាំណា លោកស្រីចាំដែរទេ?

**ឆ៖** ខ្ញុំអត់ចាំទេ ភ្លេចអស់ហើយ។

**ស៖** បាទ អរគុណ មិនអីទេ ហើយលោកស្រីអាយុប៉ុន្មានហើយ ឥឡូវហ្នឹង?

**ឆ៖** ៧៥។

**ស៖** បាទ អរគុណ ហើយលោកស្រីមានទីកន្លែងកំណើតនៅភូមិអី ឃុំអី ស្រុក ខេត្តអីដែរ?

**ឆ៖** មាន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

[០៩:១៤:៥៦]

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃរបស់លោកស្រី តើលោកស្រីរស់នៅទីកន្លែងណា នៅភូមិអី ឃុំអី ស្រុកអី ខេត្តអី?

**ឆ៖** ភូមិពោធិ៍ចិន្ដាំ ឃុំស្វាយអន្ទរ ខេត្តព្រៃវែង។

**ស៖** បាទ អរគុណ។ ចុះលោកស្រីប្រកបមុខរបរអីដែរ សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំគ្មានលក់ដូរអីទេ ខ្ញុំដើរមិនដែលរួចផងនុ៎ង។ គ្មានរកស៊ីអីទេ។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ឈ្មោះ យាយឱ, តាឱន។

[០៩:១៦:០១]

**ស៖** ប្ដីរបស់លោកស្រីឈ្មោះអី ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ឈ្មោះ ជុយ។ កូន១នាក់។

**ស៖** បាទ អរគុណ លោកស្រី ដួង អឿន ហើយអង្គជំនុំជម្រះសូមជម្រាបលោកស្រីថា ជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកស្រី ក្នុងឋានៈលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ លោកស្រីមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម។ បានន័យថា ផលអន្តរាយដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ទី០៦ ខែមករា ឆ្នាំ១៩៧៩ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ លោកស្រី ឌិន អឿន តើលោកស្រីធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេពេលកន្លងមក? ហើយបើសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅកន្លែងណា នៅពេលណា លោកស្រីចងចាំដែរទេ?

**ឆ៖** ខ្ញុំ គេហៅមកប៉ុន្មានដងហើយ ប៉ុន្តែខ្ញុំមិនដែលមកកន្លែងហ្នឹងទេ។ ខ្ញុំនៅតែឯក្រោមទេ។

**ស៖** លោកស្រីចាំថា គេមកហៅមក -- មកឲ្យលោកស្រីផ្ដល់សក្ខីកម្មហ្នឹង ឬក៏ធ្វើកិច្ចសម្ភាសន៍ហ្នឹង ប៉ុន្មានដងដែរ នៅក្រោមនុ៎ង?

**ឆ៖** ប្រាំដង។

[០៩:១៧:៥៦]

**ស៖** លោកស្រីចាំទេ ប្រាំដងហ្នឹងធ្វើនៅពេលណាខ្លះ?

**ឆ៖** ខ្ញុំភ្លេចហើយ ដឹងឆ្នាំណាអីឆ្នាំណាទេ។

**ស៖** ហើយនៅពេលមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកស្រីបានពិនិត្យមើលបានអាន ឬក៏ស្ដាប់នូវការកំណត់ហេតុដែលលោកស្រីបានផ្ដល់សក្ខីកម្ម និងកាលពីលើកមុន ដែលលោកស្រីអះអាងអំមិញថា បានធ្វើចំនួនប្រាំដង ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំរំឭក។

**ស៖** តាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំបាន ថាតើលោកស្រីអាចបញ្ជាក់បានដែរទេ ថាកំណត់ដែលស្ដាប់សក្ខីកម្មដែលលោកស្រីបានអាន ឬក៏ស្ដាប់ការអានឲ្យស្ដាប់ ដើម្បីរំឭកការ

ចងចាំ គឺវាត្រឹមត្រូវសមស្រប ស៊ីចង្វាក់គ្នានឹងចម្លើយដែលលោកស្រីបានធ្វើ ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាន ខ្ញុំចងចាំបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនូវរឿងក្តី។

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី សាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណដែលផ្តល់វេទិកាឲ្យខ្ញុំសួរទៅលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:១៩:៥៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន។ ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរលោកស្រីពាក់ព័ន្ធទៅនឹងរឿងរ៉ាវរបស់លោកស្រី ដែលបានជួបប្រទះនៅក្នុងរបបខ្មែរក្រហម។

ដំបូង លោកស្រីអាចបញ្ជាក់បានទេ នៅមុនសម័យខ្មែរក្រហម ១៩៧៥ តើលោកស្រីរស់នៅកន្លែងណា?

**លោកស្រី ដួង អឿន៖**

**ឆ៖** រស់នៅពោធិ៍ចិន្តាំ។ ខ្ញុំនៅហ្នឹងតែម្តង គ្មានទៅណាមកណាទេ។ ស្រុកកំណើតនៅកន្លែងនុ៎ង។

**ស៖** អ៊ីចឹងនៅមុនឆ្នាំ១៩៧៥ហ្នឹង លោកស្រីអាចបញ្ជាក់បានទេ លោកស្រីមានគ្រួសារហើយឬនៅ?

**ឆ៖** ខ្ញុំមានហើយ។

**ស៖** តើគ្រួសាររបស់លោកស្រីមានឈ្មោះអ្វី?

**ឆ៖** ឈ្មោះ ជុយ។

[០៩:២១:៣៤]

**ស៖** ហើយលោកស្រីបានរួមរស់ជាមួយគាត់តាំងពីពេលណាមក ជាប្តីប្រពន្ធ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបណ៎ះ! បង្អស់បន្តិចសិន!

**លោក ស្រី ដួង អឿន៖**

**ឆ៖** ខ្ញុំជួបគ្នាតាំងពីជំនាន់លន់នល់។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** តើលោកស្រីធ្លាប់ឃើញគាត់រស់នៅកន្លែងណាទេ ដែលមុនដែលលោកស្រីបានជួបគាត់ជាប្តីប្រពន្ធនុំង លោកស្រីមានបានឃើញគាត់រស់នៅកន្លែងណាដែរទេ?

**ឆ៖** គាត់នៅផ្ទះគេ។ ដល់នេះគាត់មកឲ្យយាយនុំងមកសួរខ្ញុំ ស្តីដណ្តឹងខ្ញុំទៅ បានជាប្តី បានជាប្រពន្ធទៅ។

**ស៖** លោកបានមានៗប្រសាសន៍ថា គាត់រស់នៅផ្ទះគេ។ ផ្ទះគេហ្នឹង ជាផ្ទះរបស់ខ្មែរ ឬក៏ជាផ្ទះរបស់វៀតណាម?

**ឆ៖** គាត់ខ្មែរ។

**ស៖** អ៊ីចឹងអ្នកដែលមកសួរ -- អ្នកដែលប្តីលោកស្រីរស់នៅជាមួយហ្នឹង ថាតើគាត់ជាខ្មែរ ឬក៏ជាវៀតណាម? លោកស្រីអាចបញ្ជាក់បញ្ហាហ្នឹងបានទេ?

**ឆ៖** គាត់វៀតណាម។

**ស៖** ហើយលោកស្រីដឹងទេថា ប្តី -- នៅពេលនោះ ប្តីរបស់លោកស្រីហ្នឹង គឺជាជនជាតិខ្មែរ ឬក៏ជាជនជាតិវៀតណាម?

**ឆ៖** ជនជាតិវៀតណាម។

[០៩:២៤:៥៥]

**ស៖** តើលោកស្រីមានដឹងទេថា ប្តីរបស់លោកស្រីហ្នឹងមានស្រុកកំណើតរបស់គាត់នៅកន្លែងណាដែរទេ?

**ឆ៖** ស្រុកកំណើតគាត់នៅពាម។

**ស៖** លោកស្រីមានប្រសាសន៍ថា ស្រុកកំណើតរបស់ប្តីលោកស្រីនៅពាម ក៏ប៉ុន្តែហេតុអីបាន

ជាលោកស្រីមានប្រសាសន៍ថា ប្ដីរបស់លោកស្រីជាជនជាតិវៀតណាម? តើលោកស្រីអាចពន្យល់បានទេ?

**ឆ៖** ពន្យល់បាន។ អើ បើគាត់នៅយៀកណាមមែន -- អើគាត់នៅនឹងពាមមែន។ គ្មានភូត គ្មានកុហកទេ។

**ស៖** តើសាច់ញាតិរបស់គាត់ ជាបងប្អូន ឬក៏ជាឪពុកម្ដាយ -- ឪពុកម្ដាយរបស់គាត់ជាជនជាតិវៀតណាមដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់ជនជាតិវៀតណាមដែរ ឪពុកម្ដាយគាត់ បងប្អូនកូនក្មួយគាត់។

**ស៖** តើពួកគាត់និយាយភាសាអ្វីខ្លះ?

**ឆ៖** គាត់និយាយវៀតណាម។

**ស៖** ចុះប្ដីរបស់លោកស្រីគាត់និយាយភាសាវៀតណាមដែរឬទេ?

**ឆ៖** គាត់និយាយ – គាត់និយាយមិនសូវច្បាស់ទេ។

[០៩:២៥:៤៦]

**ស៖** លោកស្រីមានប្រសាសន៍ថា គាត់និយាយមិនសូវច្បាស់ហ្នឹងគាត់និយាយភាសាវៀតណាមមិនសូវច្បាស់ ឬក៏និយាយភាសាខ្មែរមិនសូវច្បាស់?

**ឆ៖** គាត់និយាយវៀតណាមច្បាស់ ខ្មែរ គាត់មិនសូវច្បាស់ទេ។

**ស៖** បាទ សូមអរគុណលោកស្រី។ នៅក្រោយឆ្នាំ១៩៧៥ មានន័យថា នៅក្នុងរបបខ្មែរក្រហមថាតើលោកស្រី និងប្ដីរបស់លោកស្រីនៅរួមរស់ជាមួយគ្នាដែរឬទេ?

**ឆ៖** រួមរស់ជាមួយគ្នា រហូតទាល់តែទៅបាត់។

**ស៖** បាទ អ៊ីចឹងមុនពេលដែលគាត់ទៅបាត់ហ្នឹង ថាតើគាត់ធ្វើអ្វីខ្លះនៅពោធិ៍ចិន្ដាំ? ខ្ញុំចង់និយាយអំពីការងាររបស់គាត់ គាត់ធ្វើអ្វីខ្លះ?

**ឆ៖** គាត់ គេឲ្យគាត់រែកអាចម៍ក្របី អាចម៍គោ យកទៅចាក់ស្រែ។

**ស៖** ហើយពេលនោះ លោកស្រីមានកូនជាមួយគាត់ដែរឬទេ?

**ឆ៖** មានកូនមួយ។

**ស៖** លោកស្រីអាចបញ្ជាក់បានទេ កូននោះ ស្រីឬប្រុស ហើយឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ គីម វ៉ា។

សៈ តើកូននោះ មានឈ្មោះហៅក្រៅដែរឬទេ លោកស្រី?

ផៈ មាន។

សៈ ឈ្មោះអីទៅ ?

ផៈ កាំមាន។

សៈ ឈ្មោះ កាំមាន?

ផៈ ចាស។

សៈ លោកស្រីអាចបញ្ជាក់ម្តងទៀតបានទេ ប្តីរបស់លោកស្រីឈ្មោះអ្វីដែរ?

ផៈ ឈ្មោះ ជុយ។

[០៩:២៨:៣៨]

សៈ តើគាត់មានឈ្មោះពេញរបស់គាត់ទេ?

ផៈ ឈ្មោះពេញរបស់គាត់ ទេព យន់។

សៈ បាទ លោកស្រី ពេលដែលខ្ញុំសួរ សូមលោកស្រីកុំអាលឆ្លើយភ្លាម បង្អង់បន្តិច គិតបន្តិច ហើយចាំឆ្លើយនូវសំណួររបស់ខ្ញុំ ហើយមើលភ្លើងផង។ បាទ ខ្ញុំសួរបន្ត។ ប្តីរបស់លោកស្រីឈ្មោះ ទេព យន់ ហេតុអ្វីបានជាកូនរបស់លោកស្រីដាក់ឈ្មោះ គឹម វ៉ា? ហើយយកត្រកូលតាមពីណា លោកស្រីអាចបញ្ជាក់បានទេ?

ផៈ ត្រកូលឪវាហ្នឹង គេដាក់ត្រកូលឪហ្នឹងទៅ។

សៈ លោកស្រីនៅពេលដែលកូនរបស់លោកស្រីដូរឈ្មោះដាក់ កាំមាន តើមានហេតុផលអ្វីបានជាកូនរបស់លោកស្រីត្រូវមានឈ្មោះមួយទៀត ឈ្មោះ កាំមាន ហ្នឹងដែរទេ លោកស្រីអាចបញ្ជាក់បានទេ រឿងនេះ?

ផៈ ខ្ញុំបញ្ជាក់បាន។ អង្កាល់ហ្នឹង ខ្លាចអាពួកហ្នឹងវាយកទៅវ៉ៃចោល ខ្ញុំដាក់ឈ្មោះវាអ៊ីចឹងទៅ។ គេប្រាប់ថា កុំដាក់ឈ្មោះវា គឹម វ៉ា ដាក់ឈ្មោះវាមី កាំមាន ទៅ។ ហើយក៏ខ្ញុំដាក់តាមគេទៅ។

សៈ បាទ សូមអរគុណលោកស្រី។ លោកស្រីអាចបញ្ជាក់បានទេ កូនស្រីរបស់លោកស្រីនៅរស់ឬក៏ស្លាប់ហើយនាពេលបច្ចុប្បន្ននេះ ហើយអាយុប៉ុន្មានដែរ កូនស្រីរបស់លោកស្រីម្នាក់ហ្នឹង?

ផៈ កូននៅរស់ អាយុ៤៥ឆ្នាំ។

សៈ បាទ សូមអរគុណលោកស្រី។ ខ្ញុំចង់សួរអំពីបញ្ហាប្តីរបស់លោកស្រីជាបន្ថែមទៀត។ ក៏

ប៉ុន្តែជាបឋមចង់សួរលោកស្រីបន្តិចថា នៅពេលចូលដល់របបខ្មែរក្រហមឆ្នាំ១៩៧៥ តើលោកស្រីមានធ្លាប់ឮមានព័ត៌មានណាថាឲ្យប្រជាជនវៀតណាមដែលរស់នៅលើដីខ្មែរ ឬក៏នៅក្នុងស្រុកភូមិរបស់លោកស្រីហ្នឹងឲ្យទៅត្រឡប់ទៅវៀតណាមវិញទេ? មានទេ?

**ផ៖** មាន ប៉ុន្តែខ្ញុំ គាត់មិនទៅ ខ្ញុំបបួលគាត់ដែរ គាត់មិនទៅទេ គាត់ថាសុខចិត្តនៅងាប់ស្រុកខ្មែរចុះ។ គាត់អត់វិលទៅវិញទេ។

[០៩:៣១:៣៤]

**ស៖** តើលោកស្រីមានដឹងថាមានក្រុមគ្រួសារវៀតណាមណាដែលគេត្រឡប់ទៅវៀតណាមទេ នៅពេលដែលមានការប្រកាសឲ្យប្រជាជនវៀតណាមត្រឡប់ទៅវៀតណាមហ្នឹង? មានស្គាល់គ្រួសារណាទេ?

**ផ៖** មាន តាគី យាយម៉ាន់ កូនចៅគាត់ទៅវៀតណាមអស់វិញ ទាំងអស់។ ដល់ទៅហើយ គាត់ត្រឡប់មកវិញមក។ ត្រឡប់មកវិញហ្នឹង គាត់ស្លាប់ទៅតាហ្នឹង។

**ស៖** តើក្រុមគ្រួសារនេះគាត់ត្រឡប់មកវិញនៅពេលណាដែរលោកស្រីអាចបញ្ជាក់បានទេ? នៅពេលក្នុងសម័យខ្មែរក្រហមនៅឡើយ ឬក៏ក្រោយសម័យនោះ?

**ផ៖** ខ្មែរក្រហមបែកហើយបានគាត់មកវិញ ស្រុកស្រួលបួលហើយបានគាត់មកវិញ។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់សួរអំពីប្តីរបស់លោកស្រីជាពិសេស ថាតើគេធ្វើអ្វីគាត់ទៅលើ -- នៅសម័យនោះ? អ៊ីចឹងសំណួរជាដំបូងរបស់ខ្ញុំចង់សួរថា លោកស្រីបានបញ្ជាក់ថា ប្តីរបស់លោកស្រីបាត់ខ្លួន តើលោកស្រីអាចនិយាយបានទេ ប្តីរបស់លោកស្រីហ្នឹងត្រូវគេធ្វើយ៉ាងម៉េចទៅលើគាត់ បានគាត់បាត់ខ្លួនហ្នឹង?

[០៩:៣៣:១៣]

**ផ៖** បាត់ខ្លួន គេឲ្យគាត់ទៅកាប់រំពាក់ បានបាត់ខ្លួន អត់មានឃើញមកវិញទេ ទៅតែម្តង។

**ស៖** តើលោកស្រីអាចបញ្ជាក់បានទេ ថាតើឆ្នាំ ពេលដែលគេ -- គាត់បាត់ខ្លួនហ្នឹង?

**ផ៖** ដឹងឆ្នាំណាទេ ខ្ញុំភ្លេចហើយ ខ្ញុំមិនចាំទេ។

**ស៖** លោកស្រីមានចាំជារដូវទេ ជារដូវអីពេលនោះ?

**ផ៖** ខ្ញុំចាំជារដូវ ចាំជារដូវច្រូត ខ្ញុំទៅច្រូត។ ហើយដល់មកផ្ទះវិញ គេយកប្តីទៅបាត់ទៅ ខ្ញុំអត់ដឹងទេ។ មិនដឹងគេយកទៅណាទៅណី ខ្ញុំមិនដឹងដែរ។

**ស៖** បាទ អរគុណ។ តើលោកស្រីអាចរៀបរាប់បានទេ អ្នកណាដែលបានឃើញគេយកប្ដីរបស់លោកស្រីទៅ? ហើយគាត់បាននិយាយថាយ៉ាងដូចម្ដេចខ្លះ ពេលដែលយកប្ដីលោកស្រីទៅហ្នឹង?

**ឆ៖** យកប្ដីខ្ញុំទៅហ្នឹង ម៉ែទេ ម៉ែខ្ញុំគាត់ប្រាប់។ ថាមើលអ្វែង គេយកប្ដីអ្វែងទៅហើយ មិនដឹងទៅខាងណាខាងណីទេ។ អញមិនដឹងទេ។ គ្រាន់តែខ្ញុំ ថាអ៊ីចឹងទៅ ខ្ញុំឡប់ទៅស្រែវិញទៅ។

**ស៖** តើម្ដាយរបស់លោកស្រីមានបានជម្រាបលោកស្រីទេ ថាមនុស្សប៉ុន្មាននាក់មកយកប្ដីលោកស្រីទៅ? ហើយពេលយកទៅហ្នឹង មានចាប់ចងអីដែរទេ?

**ឆ៖** អត់មានចងទេ គេគ្រាន់តែបណ្ដើរទៅពីផ្ទះទៅទេ ម៉ែខ្ញុំគាត់ថាអ៊ីចឹង។ ហើយខ្ញុំក៏ទៅច្រូតវិញទៅ។

**ស៖** តើមនុស្សប៉ុន្មាននាក់បណ្ដើរប្ដីរបស់លោកស្រីចេញទៅ?

**ឆ៖** ទៅតែម្នាក់ទេ បណ្ដើរតែម្នាក់ទេ។

[០៩:៣៥:៥២]

**ស៖** នៅពេលដែលបណ្ដើរចេញទៅ ម្ដាយរបស់លោកស្រីមានបាននិយាយអ្វីទៅកាន់ប្ដីរបស់លោកស្រីទេ ពេលនោះ?

**ឆ៖** ថាទៅកូនអើយ ត្រឡប់មកវិញមក ទៅកុំនៅយូរពេក ឆាប់មកវិញ។ ហើយគាត់ថាម៉ែអើយ ខ្ញុំដល់ខ្ញុំនេះ ខ្ញុំត្រឡប់មកវិញហើយ។ ស្រាប់តែបាត់តាំងពីហ្នឹងមករហូតទៅ មានត្រឡប់មកវិញឯណា។

**ស៖** ម្ដាយរបស់លោកស្រីបានបញ្ជាក់ថាប្ដីរបស់លោកស្រីទៅកាប់រពាក់។ តើលោកស្រីដឹងទេកន្លែងកាប់រពាក់ហ្នឹងនៅកន្លែងណាលោកស្រី?

**ឆ៖** ខ្ញុំអត់ដឹងដែរ មិនដឹងកន្លែងណា អីកន្លែងណា ខ្ញុំអត់ស្គាល់ទេ ស្រាប់តែបាត់តែម្ដងទៅ មិនដឹងនៅឯណាឯណីទេ។

**ស៖** ក្រៅពីប្ដីរបស់លោកស្រី តើលោកស្រីមានដឹងថាមានក្រុមគ្រួសារវៀតណាមណាផ្សេងទៀតដែលរស់នៅក្នុងស្រុកភូមិជាមួយលោកស្រីដែរឬទេ?

**ឆ៖** មានគ្រួសារ ឡាច នី។ ទៅមួយហ្វូង កូនចៅគាត់ទៅទាំងអស់ នៅតែគាត់មួយទេ។

**ស៖** អ៊ីចឹងអ្នកណាៗក្រុមគ្រួសារ ឡាច នី ដែលទៅមួយហ្វូងហ្នឹង លោកស្រីអាចបញ្ជាក់បានទេពីណាខ្លះដែលទៅហ្នឹងនៅក្នុងក្រុមគ្រួសាររបស់គាត់ហ្នឹង? ជាបងប្អូន ឬក៏ថាជាយ៉ាងម៉េច ត្រូវនឹង

ឡាច នី?

**ឆ៖** កូនចៅគាត់ហ្នឹង ទាំងអស់ហ្នឹងកូនចៅគាត់បួន ប្រាំ ប្រាំមួយនាក់។ ទាំងម្ដាយទាំងអីទៀត ប្រាំមួយនាក់។ មានគ្រួសារទៀត គ្រួសារគាត់តែមួយគ្រួសារហ្នឹងទេ។

**ស៖** អ៊ីចឹងប្រសិនបើខ្ញុំយល់ពីលោកស្រីៗចង់មានប្រសាសន៍ថាគេយកទៅទាំងប្រពន្ធរបស់ ឡាច នី ទាំងកូនរបស់ ឡាច នី ជាមួយនឹងប្រពន្ធហ្នឹង ប្រាំ ឬប្រាំមួយនាក់។ តើខ្ញុំនិយាយអ៊ីចឹងត្រូវទេ លោកស្រី?

**ឆ៖** ត្រូវ។ យកទៅកូនចៅកាលហ្នឹងប្រាំ ប្រាំមួយនាក់ ទាំងម៉ែហ្នឹង។

**ស៖** តើលោកស្រីស្គាល់ប្រពន្ធរបស់ ឡាច នី ដែរឬទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ ខ្ញុំភ្លេចៗឈ្មោះគាត់ហើយ មិនដឹងគាត់ស្គាល់ឈ្មោះអីទេ ខ្ញុំអត់ចាំទេ។

[០៩:៣៩:២៤]

**ស៖** គាត់មានឈាមជ័រជាជនជាតិអ្វីដែរ លោកស្រី?

**ឆ៖** គាត់ជនជាតិវៀតណាមដែរ គាត់និយាយវាមិនច្បាស់។

**ស៖** លោកស្រីដឹងថាពេលមុនសម័យខ្មែរក្រហម ប្រពន្ធរបស់ ឡាច នី ហ្នឹងរកស៊ីអីដែរទេ?

**ឆ៖** រកស៊ីលក់បន្លែបន្តិចបន្តួចហ្នឹងផ្សារហ្នឹង គាត់បេះពីផ្ទះទៅ យកទៅលក់នៅផ្សារទេ បន្លែ កំប៉ិកកំប៉ុកបន្តិចបន្តួច។

**ស៖** បាទ ខ្ញុំអរគុណ។ អ៊ីចឹងខ្ញុំចង់សួរថែមទៀត ក្រៅពីក្រុមគ្រួសាររបស់ ឡាច នី តើមានក្រុម គ្រួសារណាផ្សេងទៀតដែលជាជនជាតិវៀតណាមដែលអ៊ំស្រីដឹងទេ?

**ឆ៖** ឈ្មោះ ង៉ាង។ ង៉ាង យកទៅមុនគេ ទៅកាប់រពាក់ ស្រាប់តែបាត់ទៅ ទាល់ហ្នឹងឥឡូវទៅ វាមិនឃើញទេ មិនវិលមកវិញទេ។ ហ្នឹងវៀតណាមដែរ។

**ស៖** ចុះកូនចៅរបស់ ង៉ាង ហ្នឹងមានគេយកទៅជាមួយដែរ ឬក៏អត់ទេ?

**ឆ៖** អត់ទេ នៅផ្ទះទាំងអស់។ យកតែឪទៅទេ។

**ស៖** តើធ្វើម្ដេចបានលោកស្រីដឹងថា ង៉ាង ហ្នឹងគឺជាវៀតណាម?

**ឆ៖** ង៉ាង និយាយមិនច្បាស់ដែរ គាត់និយាយអត់ច្បាស់ទេ។

**ស៖** តើ ង៉ាង ហ្នឹងនិយាយភាសាវៀតណាមដែរ ឬអត់ទេ? អ៊ំមានដឹងទេ?

[០៩:៤២:០៥]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោកស្រី ដួង អឿន៖**

**ឆ៖** ម៉ែឪវាវៀតណាម។ បានខ្ញុំដឹង ត្រង់វានិយាយ ឬមិននិយាយ ខ្ញុំមិនដឹងទេ។ ប៉ុន្តែដឹងម៉ែឪវាវៀតណាមហើយ។

**ស៖** លោកស្រីធ្លាប់ឮឪពុកម្ដាយគាត់និយាយភាសាវៀតណាមដែរ ឬអត់ទេ?

**ឆ៖** ខ្ញុំមិនដែលឮនិយាយទេ ព្រោះនៅឆ្ងាយផ្ទះ ឆ្ងាយពីគ្នា។ ប៉ុន្តែដឹង ង៉ាង ហ្នឹងវៀតណាមហើយ។

**ស៖** អ៊ំធ្វើយ៉ាងដូចម្ដេចបានដឹងថា ក្រុមគ្រួសារគាត់ហ្នឹង គឺជាវៀតណាម?

**ឆ៖** ខ្ញុំមើលមុខ មើលមាត់វា ដឹងថាវាវៀតណាម បើវានិយាយមិនច្បាស់ដែរ និយាយខ្មែរវាមិនច្បាស់។

**ស៖** អ៊ីចឹងមានន័យថា អ៊ំធ្លាប់ជួបគាត់ ធ្លាប់និយាយជាមួយគាត់មែនទេ?

**ឆ៖** ខ្ញុំមិនដែលបាននិយាយជាមួយទេ គ្រាន់តែឃើញគ្នា ឃើញ។ ត្រង់និយាយ ខ្ញុំមិនដែលនិយាយទេ។

**ស៖** អ៊ំធ្លាប់ឮគាត់និយាយខ្មែរដែរទេ?

**ឆ៖** និយាយវាមិនសូវច្បាស់។

**ស៖** តើអ៊ំមានស្គាល់ក្រុមគ្រួសារ -- កូនរបស់គាត់ទេ តើកូនរបស់គាត់មានឈ្មោះអ្វីខ្លះ?

**ឆ៖** ឈ្មោះ មីកន្ទុប, អាមួយទៀតឈ្មោះ អាងួន សៀង។

**ស៖** តើពួកគាត់មានត្រូវបានខ្មែរក្រហម ឬក៏កម្មាភិបាលអីយកទៅដែរ ឬអត់ទេ?

**ឆ៖** យកជំនាន់ខ្មែរហ្នឹងណ៎ា យកទៅទាំងអស់គ្នាហ្នឹង កូនចៅ មិនទៅទេ នៅ កូនចៅនៅ យកតែអាប្ដីហ្នឹងទៅទេ។

[០៩:៤៤:៤៨]

**ស៖** លោកស្រីបាននិយាយថាយកទៅ ឈ្មោះ ង៉ាង, ក្រុមគ្រួសាររបស់លោក ឡាច នី ហើយនិងប្ដីរបស់លោកស្រី។ តើលោកស្រីអាចបញ្ជាក់ទេ អ្នកណាគេត្រូវបានគេយកទៅមុន ហើយនិងយកទៅបន្តបន្ទាប់ទៀត?

**ផ៖** ង៉ាង យកទៅមុនគេបង្អស់ បានតមកអ៊ីចឹងទៅ ឡាច នី ហើយប្ដីខ្ញុំក្រោយគេ។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់វិលមកក្រោយបន្តិច ពាក់ព័ន្ធទៅនឹងប្ដីរបស់លោកស្រី។ នៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ ថាតើពេលដែលលោកស្រីរស់នៅជាមួយប្ដីលោកស្រីហ្នឹង លោកស្រីមានឃើញទេ តើប្ដីរបស់លោកស្រីហ្នឹងរកស៊ីអ្វីខ្លះ? គាត់ប្រកបមុខរបរអី?

**ផ៖** ប្រកបមុខរបរ គាត់លក់ដូរមាន់ ទា តែប៉ុណ្ណឹង។ លក់ទៅ គេមកយកដល់ៗផ្ទះទៅ។ ទិញឲ្យតែបានមក គាត់គ្មានរកស៊ីអីទៀតទេ។

**ស៖** គាត់មានលក់កញ្ឆាលក់អីដែរទេ?

**ផ៖** គាត់គ្មានលក់ទេ។

**ស៖** ពេលនោះ ក្រុមគ្រួសាររបស់លោកស្រីរស់នៅជីវភាពធូរធារដែរឬទេ?

**ផ៖** គ្រួសារពិបាកវេទនាណាស់ក្មួយហើយ រកអីហូបមិនបានទេ កាលជំនាន់នុ៎ង ធ្វើអីក៏មិនបានស៊ីដែរ។ ធ្វើបាប ហើយគេវ៉ៃជេរ ប្រើគ្មានទំនេរផង។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់ចូលមកក្នុងអំពីរូបលោកស្រីផ្ទាល់តែម្ដង។ នៅក្នុងសម័យខ្មែរក្រហម ចង់និយាយថា នៅពីក្រោយឆ្នាំ១៩៧៥ តើលោកស្រីខ្លួនឯងផ្ទាល់ហ្នឹង ធ្វើការងារអ្វីខ្លះ?

**ផ៖** ខ្ញុំជំនាន់ហ្នឹង ខ្ញុំ គេឲ្យខ្ញុំទៅជីកដី ជីព្រែក ច្រូតកាត់ ស្ទូងដក ម៉ាចប់។ មកវិញ ខ្ញុំច្រូត ហើយចាត់តាំងឲ្យខ្ញុំទៅជីកព្រែក ជីកអាង ស្រុកគេឆ្ងាយៗណាស់។

[០៩:៤៨:១១]

**ស៖** ហើយអ្នកណាជាអ្នកមើលកូន?

**ផ៖** ម៉ែខ្ញុំ។

**ស៖** ចុះប្ដីលោកស្រីពេលនោះ មុនដែលគេយកខ្លួនគាត់ទៅបាត់ តើគាត់មានជួយមើលកូនស្រីហ្នឹងដែរទេ?

**ផ៖** មុនគេទៅបាត់ គាត់នៅមើល។ គាត់នៅដឹកដៃកូន រែកជី រែកអាចម៍ក្របីយកទៅចាក់ស្រែ ហើយគាត់ដឹកដៃកូនដើរតាមរហូតទៅ។ ដល់ពេលបាយរួម គាត់ដឹកដៃកូនទៅហូបបាយរួមទៀតទៅ មកពីធ្វើការងារនុ៎ង។ ដល់គាត់ទៅបាត់ទៅ គាត់ឲ្យម៉ែខ្ញុំមើលទៅ។

**ស៖** បាទ អរគុណលោកស្រី។ ក្រៅពីកូនស្រីលោកស្រីម្នាក់នោះ ថាតើលោកស្រីមានកូនផ្សេងទៀតទេ?

**ឆ៖** មានមួយ ឈ្មោះ មាំង ជំនាន់អាប៉ុល ពត គេយកទៅវ៉ៃចោលហើយ។ វាមកនេះ វាទៅសុំសាំងគេចាក់ដែកកេះ ហើយវារុះអាគរចូលក្នុងសាំងគេហ្នឹងទៅ ហើយគេចាប់វាទៅ។

**ស៖** តើកូនហ្នឹង ជាកូនជាមួយប្តីរបស់លោកស្រីឈ្មោះ ជុយ ហ៊្នឹង ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** អាកូនមួយនោះ បានប្តីខ្ញុំមុនទេ ប្តីដើម បានកូនន៎ុងមួយ បានតែមួយន៎ុង វាបែកគ្នាទៅ។

**ស៖** តើមានអ្វីកើត -- តើពេលដែលគេចាប់កូនប្រុសរបស់លោកស្រីហ្នឹង ព្រឹត្តិការណ៍ហ្នឹងកើតឡើងមុនគេចាប់ប្តីលោកស្រី ឬក៏ក្រោយពេលដែលគេចាប់ប្តីលោកស្រីទៅ?

**ឆ៖** ចាប់ទៅជំនាន់អាពតហ្នឹងណ៎ា។ វាទៅធ្វើដែកកេះអី ឆេះសាំងអីហ្នឹង គេចាប់យកទៅភ្លាមន៎ុង។ ខ្ញុំមិនទាំងដឹងផង ឮតែគេថា ខ្ញុំមិនប៉ានទៅជិតគេផង។

**ស៖** តើពេលដែលគេចាប់យកកូនហ្នឹងទៅ គឺគេចាប់ទៅមុនពេលដែលគេប្តី -- ចាប់ប្តីរបស់លោកស្រីទៅ ឬក៏ក្រោយពេលដែលគេចាប់ប្តីលោកស្រីទៅ?

**ឆ៖** ប្តីខ្ញុំទៅមុន បានចាប់កូនក្រោយ។

**ស៖** បាទ លោកស្រី។ ខ្ញុំមិនមានសំណួរច្រើនសម្រាប់លោកស្រីទេ ក៏ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់បន្តិច។ ពេលដែលរៀបការជាមួយប្តីរបស់លោកស្រីឈ្មោះ ជុយ ហ៊្នឹង តើលោកស្រីមានដឹងថា ប្តីរបស់លោកស្រីធ្វើអីទេ គាត់អាចមានធ្វើទាហានធ្វើអីទេ ពេល មុនពេលហ្នឹង?

[០៩:៥២:២៥]

**ឆ៖** ឃើញតែគាត់មក ត្រង់គាត់ធ្វើទាហានៗអី ខ្ញុំអត់ដឹងទេ ប៉ុន្តែដឹងតែគាត់មកពីណាមកទេ គាត់មកនៅស្រុកហ្នឹង។ ហើយត្រង់គាត់ធ្វើទាហានៗ គាត់មិនដែលនិយាយទេ។

**ស៖** បាទ អរគុណ។ ហើយសំណួរចុងក្រោយរបស់ខ្ញុំ នៅក្រោយ -- នៅមុនពេលដែលប្តីរបស់លោកស្រីត្រូវបានគេចាប់ទៅ ហើយបាត់ខ្លួន នាំទៅ ហើយបាត់ខ្លួន។ តើលោកស្រីអាចបញ្ជាក់បានទេ មានការរើសអើងទៅលើប្តីលោកស្រីដែរឬទេ?

**ឆ៖** ខ្ញុំថីមិននេះ ខ្ញុំនឹកឃើញសព្វគ្រប់គេយកប្តីទៅវាយចោល យកកូនទៅសម្លាប់ចោលអស់។ ខ្ញុំនឹកស្តាយសោកសង្រេង ប្រៀបពុំបានទេ គ្មានសល់អ្វីអីទេ។

**ស៖** ខ្ញុំសូមអធ្យាស្រ័យលោកស្រី ខ្ញុំសូមកាត់លោកស្រីបន្តិច។ មុននឹងគេយកប្តីលោកស្រីយកទៅបាត់ ថាតើការរស់របស់លោក -- ប្តីរបស់លោកស្រីនៅក្នុងស្រុកភូមិហ្នឹង ជាមួយអ្នកផ្សេងៗទៀត ថាតើមានអ្នកណា អ្នកណើ គេរើសអើងលោកស្រីទេ ហើយឬក៏មានមេភូមិអីគេរើសអើងប្តីលោកស្រីថា

ជាវៀតណាម ជាអីដែរទេ?

**ឆ៖** គេមិនដែលថាទេ មិនដែលឮពីណានិយាយអីទេ។ ទាល់តែគេយកទៅបាត់ទៅ គ្មានពីណាថាអីៗទេ។

**លោក ពេជ អង្គ៖**

បាទ អ៊ីចឹងខ្ញុំអរគុណ លោកស្រី ចំពោះការឆ្លើយនឹងសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធានចំពោះការផ្តល់ឱកាសឲ្យខ្ញុំសួរសំណួរទៅលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហ តំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រី ចៅក្រម។

[០៩:៥៥:០៩]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ ប៊ិយ មកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំនឹងសួរសំណួរលោកស្រីមួយចំនួនពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់លោកស្រី។ ខ្ញុំនឹងសួរបន្តពីអ្វីដែលលោកស្រីទើបតែត្រូវបានសួរដោយសហមេធាវីនាំមុខ។ លោកស្រីនិយាយអំពីកូនស្រីបីនាក់ដែលលោកស្រីយល់ឃើញថា ពួកគេអាចនឹងត្រូវបានគេនាំខ្លួនយកទៅសម្លាប់ចោល ដោយលោកស្រីដាក់ឈ្មោះអ្នកទាំងបីថ្មី។ លោកស្រីនៅចាំទេ នៅពេលណាដែលលោកស្រីដាក់ឈ្មោះថ្មីឲ្យកូនស្រីទាំងបីនាក់ហ្នឹង?

**លោកស្រី ដួង អឿន៖**

**ឆ៖** ខ្ញុំមានដាក់ឈ្មោះស្អីទេ ប៉ុន្តែកាលនោះ គេមិនឲ្យដាក់ឈ្មោះអ៊ីចឹងទេ គេឲ្យប្រែឈ្មោះ ទៅខ្លាចលោគេយកទៅវៃចោលទៀត។ ដាក់ឈ្មោះវា មីគីមវ៉ា អ៊ីចឹងទៅ។ ខ្ញុំអត់ប៉ានដាក់ឈ្មោះអីផ្សេងទៀតទេ ដាក់អ៊ីចឹងទៅ។

**ស៖** ហើយនៅពេលដែលលោកស្រីសម្រេចប្រើប្រាស់ឈ្មោះថ្មីហ្នឹង គឺនៅពេលក្រោយដែលខ្មែរក្រហមចូលទៅដល់ភូមិពោធិ៍ចិន្តាំហ្នឹងមែនទេ?

**ឆ៖** ចាស ខ្ញុំដាក់ក្រោយហ្នឹង។ ដាក់ក្រោយខ្មែរក្រហមចូលភូមិហ្នឹង។

**ស៖** ចុះឈ្មោះដើមរបស់ពួកគេដែលលោកស្រីគិតថា អាចនឹងគេដឹង គេយកទៅកម្ទេចចោលហ្នឹង ឈ្មោះដើមហ្នឹងឈ្មោះអីទៅ?

**ឆ៖** មិនដឹងឈ្មោះអីទេ។ កាលឈ្មោះដើម ឈ្មោះមី គីម វ៉ា ដល់ពីនោះមក ខ្ញុំដាក់ឈ្មោះវាមី កាមាន ទៅ។

[០៩:៥៧:៤៤]

**ស៖** ហេតុអ្វីបានជាលោកស្រីគិតថា បើនាងទុកនៅប្រើឈ្មោះ គីម វ៉ា ហ្នឹង អាចនឹងត្រូវបានគេកម្ទេចចោល?

**ឆ៖** ចាស ខ្ញុំខ្លាចអ៊ីចឹងបានខ្ញុំដាក់ឈ្មោះវា មីកាមាន ទៀតទៅ ខ្លាចគេយកទៅវ៉ៃចោលដូចឪអ៊ីចឹងទៅ។

**ស៖** ខ្ញុំសូមសួរតាមរបៀបផ្សេង។ ហេតុអ្វីបានជា កាមាន មិនប៉ានទុកឈ្មោះចាស់របស់នាងឈ្មោះ គីម វ៉ា ហេតុអីក៏មកប្រើឈ្មោះ គីម មាន ជំនួសឲ្យឈ្មោះ គីម វ៉ា នេះទៅវិញ?

**ឆ៖** ព្រោះជំនាន់ហ្នឹង ខ្ញុំខ្លាចគេយកកូនទៅវ៉ៃចោល បានខ្ញុំប្រែឈ្មោះថាវាមី កាមាន ទៀតទៅអ្នកស្រុកអ្នកភូមិប្រាប់ថា កុំដាក់ឈ្មោះវាមី គីម វ៉ា ដាក់ឈ្មោះវាមី កាមាន ទៅ។ ខ្ញុំក៏ដាក់ទៅ ខ្ញុំខ្លាចគេយកទៅដូចឪពុកអ៊ីចឹង ជំនាន់ហ្នឹងនោះ។

**ស៖** តើឈ្មោះ គីម វ៉ា អាចឲ្យគេដឹងថា វាជាប់សាច់ឈាមជាមួយនឹងឪពុករបស់នាង ឬក៏យ៉ាងណា បានជាមកដាក់ កាមាន ទៅហើយវាមិនជាប់ វាអ៊ីចឹង ឬយ៉ាងណា?

**ឆ៖** ចាស អ៊ីចឹងហើយ ព្រោះដាក់ឈ្មោះ គីម វ៉ា ទៅ ខ្លាចជាប់ដូចឪវាអ៊ីចឹង ឈ្មោះឪវាអ៊ីចឹងប៉ុនដល់នេះទៅ វាប្រែមកឈ្មោះវាមី កាមាន វិញទៅ។

**ស៖** សូមអរគុណច្រើន។ តើលោកស្រីអាចនៅនឹកឃើញបានទេ ថានៅពេលណាដែលខ្មែរក្រហមបានចូលមកដល់ភូមិពោធិ៍ចិន្តាំ?

**ឆ៖** ឆ្នាំ៧៧ ចូលមកដល់ភូមិពោធិ៍ចិន្តាំ។

**ស៖** ខ្ញុំស្តាប់ឮថា លោកស្រីថាខ្មែរក្រហមបានចូលមកដល់ភូមិរបស់លោកស្រីនៅឆ្នាំ១៩៧៧។

ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្រីស្ដាប់ចេញពីប្រតិចារឹករបស់បុគ្គលម្នាក់ ដែលជាអ្នកភូមិរបស់លោកស្រីដែរ ឈ្មោះ តេង ផល ឬ តេង ហ៊ុយ ដែលបានមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺប្រតិចារឹក E1/378.1 នៅមុនម៉ោង ០៣:១៥ ថ្ងៃ -- គាត់បានឆ្លើយថា៖ "ខ្មែរក្រហមបានមកត្រួតត្រាភូមិពោធិ៍ចិន្ដាំនៅក្នុងឆ្នាំ១៩៧២ ឬ១៩៧៣"។ ក្រោយពីស្ដាប់នូវសម្រង់នេះហើយ តើវាជួយរំឭកដល់ការចងចាំបានថា ខ្មែរក្រហមបានចូលមកដល់ភូមិពោធិ៍ចិន្ដាំឆ្នាំ១៩៧២ ឬ៧៣ នោះដែរទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែ៧៧ ខ្មែរក្រហមចូលដល់ភូមិពោធិ៍ចិន្ដាំ ៧៧។ ថាប៉ុន្មានៗទៀត ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែប៉ុណ្ណឹង។

[១០:០២:០១]

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា នៅពេលដែលខ្មែរក្រហមចូលមកដល់ពោធិ៍ចិន្ដាំ តើគេមានចាត់តាំងឲ្យអ្នកណាម្នាក់គ្រប់គ្រងភូមិនោះទេ?

**ឆ៖** អត់មានទេ។

**ស៖** តើឈ្មោះ ហាន នេះ បើខ្ញុំប្រាប់មនុស្សម្នាក់ឈ្មោះ ហាន លោកស្រីអាចនឹកឃើញទេ នៅភូមិពោធិ៍ចិន្ដាំនោះ?

**ឆ៖** ឈ្មោះអី ឈ្មោះ ហ៊ាន? ឈ្មោះ ហ៊ាន ឈ្លប ទេ។ ប្រធានឈ្លប។

**ស៖** តើ ហ៊ាន នេះមានតួនាទីអីទេ នៅភូមិពោធិ៍ចិន្ដាំក្រោយពេលខ្មែរក្រហមចូលមកដល់?

**ឆ៖** ខាងឈ្លប។ កាលខ្មែរក្រហមចូលមកដល់ ធ្វើឈ្លប។

**ស៖** ហើយតើគាត់នៅតែបន្ដរស់នៅភូមិពោធិ៍ចិន្ដាំហ្នឹងដែរឬ ក្រោយខ្មែរក្រហមចូលមកដល់ភូមិពោធិ៍ចិន្ដាំ?

**ឆ៖** គាត់នៅ។ ឥឡូវគាត់ស្លាប់បាត់ហើយ។ កាលនុំងគាត់នៅ។ ប្រពន្ធកូននៅទាំងអស់។ ស្លាប់តែគាត់ទេ។

**ស៖** ចុះលោកស្រីមាននៅនឹកឃើញឈ្មោះ សេង អីដែរទេ បើខ្ញុំនិយាយពីមនុស្សម្នាក់ឈ្មោះ សេង រស់នៅភូមិពោធិ៍ចិន្ដាំ?

**ឆ៖** សេង នុំងប្រធានឈ្លបដែរ។ ឈ្មោះ សេង។ នៅស្រុកគេទេ មិនមែននៅស្រុកខ្ញុំទេ ប៉ុន្ដែគេចល័តមកនៅស្រុកខ្ញុំ។

[១០:០៥:០៤]

**ស៖** សូមអរគុណច្រើន។ តើលោកស្រីស្គាល់ឈ្មោះអ្នកដែលត្រួតត្រាឃុំរបស់លោកស្រីដែរទេ នៅក្នុងរបបខ្មែរក្រហម?

**ឆ៖** ឈ្មោះ ឆែម – ថ្នាក់ឃុំ ឆែម។ ឆែម, ហ៊ាន ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** តើ ឆែម ហ្នឹងមានអនុប្រធានរបស់គាត់ទេ អនុប្រធានឃុំនៅក្រោមគាត់ហ្នឹងទេ បើមានអ្នកស្រីនឹកឃើញឈ្មោះអនុប្រធានឃុំ នៅក្រោម ឆែម នេះទេ?

**ឆ៖** អត់នឹកឃើញទេ ខ្ញុំអត់ដែលចាំ ខ្ញុំភ្លេចហើយ។ មិនដឹងឯណា ដឹងឯណីទេ តាំងពីហ្នឹង មកដល់នេះ។ ខ្ញុំនឹកមិនឃើញទេ។

**ស៖** ខ្ញុំយល់ហើយលោកស្រី បើលោកស្រីមិនចាំ ក៏មិនចាំទៅចុះ បើចាំសូមលោកស្រីឆ្លើយទៅតាមនោះ។ ចុះបើខ្ញុំនិយាយពីមនុស្សម្នាក់ឈ្មោះ មុត តើលោកស្រីមាននឹកឃើញដែរទេ?

**ឆ៖** មុត ខ្ញុំនឹកឃើញ ហ្នឹងតាំងពីមុនណោះ មិនមែនជំនាន់ហ្នឹងទេ គាត់ធ្វើយូរហើយ ឥឡូវគាត់ស្លាប់បាត់ហើយ។ គាត់មិនមែនធ្វើពីជំនាន់ ឆែម ទេ ធ្វើពីមុនហ្នឹងទៀតន៎។

**ស៖** បុគ្គលដដែល ដែលខ្ញុំបានលើកឈ្មោះពីខាងដើម ឈ្មោះ តាំង ផល បានមកផ្តល់សក្ខីកម្ម នៅម៉ោង ១៥:៤០:៤៨ វិនាទី គាត់និយាយថា "មុត ឈ្មោះ មុត គឺជាអនុប្រធានរបស់ ឆែម"។ បើនិយាយពីឈ្មោះ មុត ថាជាអនុប្រធានរបស់ ឆែម នេះតើលោកស្រីនៅនឹកឃើញទេ?

**ឆ៖** ខ្ញុំនឹកឃើញ មុត ហ្នឹងធ្វើមុន ឆែម។ ឆែម ហ្នឹងធ្វើក្រោយទេ។ ខ្ញុំរកនឹកឃើញ ប៉ុនគាត់គ្រាន់ថា មុត ហ្នឹងគាត់ធ្វើមុន។ ឆែម ហ្នឹងធ្វើក្រោយទេ ជំនាន់យើង អាពតហ្នឹង។

[១០:០៨:០៦]

**ស៖** ខ្ញុំសូមសួរលោកស្រីអំពីបុគ្គលម្នាក់ទៀត ទាក់ទងទៅនឹងការដឹកនាំ គ្រប់គ្រងនៅភូមិពោធិ៍ចិន្តាំ។ លោកស្រីនៅចាំបុគ្គលម្នាក់ឈ្មោះ ង៉ុយ ហើយបើសិនជាលោកស្រីនៅចាំ តើលោកស្រីនៅចាំអ្វីខ្លះដែរពីឈ្មោះ ង៉ុយ នេះ?

**ឆ៖** ង៉ុយ ហ្នឹងខ្ញុំអត់ដឹងទេ ខ្ញុំអត់ចាំទេ ង៉ុយ ហ្នឹង។ ខ្ញុំមិនស្គាល់ផង។ មិនដឹង ង៉ុយ នៅឯណាផង ខ្ញុំមិនស្គាល់ទេ។

**ស៖** ថ្មីៗនេះ បុគ្គលម្នាក់បានមកឆ្លើយនៅចំពោះមុខតុលាការ ខ្ញុំជឿថាជាជីដូនមួយរបស់លោកស្រី ឈ្មោះ ឡាច គ្រី គឺសេចក្តីព្រាងប្រតិចារឹក នៅម៉ោង ១៤:០៤:០៤។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ជីដូនមួយរបស់លោកស្រីថា ង៉ុយ ជាប្រធានសន្តិសុខនៅស្វាយអន្ទរ លោកស្រីនឹកឃើញទេ?

**ឆ៖** ខ្ញុំរកនឹកអត់ឃើញទេ មិនដឹង ង៉ុយ ណាផង។ ខ្ញុំអត់ចាំទេ។ ខ្ញុំភ្លេចបាត់ហើយ មិនដឹងមួយណា មួយណើទេ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកស្រី លោកប្រធាន តើពេលនេះសមស្របនឹងឈប់សម្រាកសិន ឬក៏អនុញ្ញាតឱ្យខ្ញុំសួរបន្ត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងកន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បន្តទៅនេះ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមថ្លែងអំណរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** បាទ លោកស្រីសាក្សី បន្ទាប់ពីខ្មែរក្រហមបានចូលមកដល់ភូមិរបស់លោកស្រី តើមាន

គេមានកំណត់ថាតើអ្នកណាខ្លះជាជនជាតិវៀតណាមទៀតដែរឬទេ នៅក្នុងភូមិរបស់លោកស្រី?

**លោកស្រី ដួង អឿន៖**

**ឆ៖** អត់មានទេ មានតែប៉ុណ្ណឹង។ អត់មានក្រៅពីហ្នឹងទៀតទេ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើលោកស្រីធ្លាប់បានដឹងដែរឬទេ ថាតើមានពួកខ្មែរក្រហមសួរសំណួរទៅលើអ្នកភូមិ ដើម្បីរកថាអ្នកណាជាជនជាតិវៀតណាម មានជនជាតិវៀតណាមដែរឬទេ?

**ឆ៖** អត់មានសួរទេ គ្មានពីណាដើរសួរទេ អត់មានទេ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី បាទ ខ្ញុំសូមអានសម្រង់មួយ គឺដូចជាចម្លើយដែលលោកបានផ្ដល់ទៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយរំឭកដល់ការចងចាំរបស់លោកស្រី គឺលេខ 7562 ហើយជាភាសាអង់គ្លេស 00176057, ខ្មែរ 0034356 ហើយនេះគឺជាបទសម្ភាសន៍ជាមួយនឹងលោកស្រីសាក្សី ហើយសំណួរនោះ គឺបានសួរអំពីប្ដីរបស់លោកស្រី ហើយសំណួរនោះ "ថាតើយើងដឹងយ៉ាងម៉េចថា -- បាទ យើងដឹងយ៉ាងម៉េច ហើយគេបានបញ្ជាក់ថា គេបានត្រួតពិនិត្យមើល ហើយគេដឹងថាតើមានគ្រួសារជនជាតិវៀតណាមប៉ុន្មាននៅក្នុងភូមិ ហើយលោកស្រីបានឆ្លើយថា ត្រឹមត្រូវហើយនេះគឺជាអ្វីដែលពួកគេបានធ្វើ។ អ៊ីចឹងសំណួរថា៖ តើពួកគេធ្លាប់ស្រង់ស្ថិតិនៅក្នុងភូមិរបស់លោកស្រី ឬក៏រៀបចំជាបញ្ជីឈ្មោះដែរឬទេ? ហើយលោកស្រីឆ្លើយថា៖ បាន ពួកគេបានធ្វើនៅក្នុងសម័យប៉ុល ពត នោះ។ អ៊ីចឹងតើគេ -- សំណួរសួរថា៖ តើមានការប្រមូលទិន្នន័យហ្នឹងពីផ្ទះមួយទៅផ្ទះមួយទេ? លោកស្រីបានឆ្លើយថា៖ មែន ហើយគេបានកំណត់ថា ប្ដីលោកស្រី គឺជាជនជាតិវៀតណាម ហើយលោកស្រីសាក្សីថាពិតមែន។" តើលោកស្រីចាំទេ តាមរយៈបទសម្ភាសន៍ដែលលោកស្រីផ្ដល់ទៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ តើៗលោកស្រីបានចាំទេថា នៅពេលនោះ គឺមន្ត្រីរបស់ខ្មែរក្រហមហ្នឹង គឺបានស្រង់ស្ថិតិ ហើយបានសួររក ហើយដឹងថាប្ដីលោកស្រីជាជនជាតិវៀតណាម?

[១០:៣៦:២៦]

**ឆ៖** ខ្ញុំអត់បានដឹងទេ ខ្ញុំអត់បានយល់ទេ កន្លែងត្រង់ហ្នឹង ខ្ញុំមិនបានដឹងទេ។ ខ្ញុំភ្លេចអស់ហើយតាំងពីនុំងមកដល់នេះ។

**ស៖** បាទ សូមថ្លែងអំណរគុណ។ លោកស្រីបានបញ្ជាក់ពីមុនថា ពាក់ព័ន្ធទៅនឹងសំណួរស្ដីអំពីថា នៅពេលណាដែលប្ដីលោកស្រី ត្រូវបានគេយកទៅ ហើយលោកស្រីមិនបានចាំទេ ពាក់ព័ន្ធទៅនឹងថ្ងៃខែឆ្នាំ។ បាទ បើសិនបើខ្ញុំៗបានជម្រាបលោកស្រីថា ការចាប់ខ្លួនហ្នឹង គឺអាចកើតឡើង ធ្វើឡើងនៅក្នុង

ឆ្នាំ១៩៧៧។ តើលោកស្រីបានចងចាំទេ ថាតើនៅពេលណា ឆ្នាំណា ខែណា ដែលប្ដីលោកស្រីត្រូវបានគេចាប់យកទៅ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ បាទ។ ហើយគឺយើងឃើញថា សហព្រះរាជអាជ្ញាហ្នឹង គាត់ចង់សួរទៅលើឆ្នាំ ហើយលោកស្រីសាក្សីហ្នឹង គឺបានប្រាប់ចម្លើយហើយថា ក្នុងឆ្នាំ១៩៧៨។ បាទ ខ្ញុំគិតថាសំណួរនេះ គឺមិនគួរជាសួរទេ បាទ។

[១០:៣៨:០២]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមបញ្ជាក់បន្តិច បាទ គឺខ្ញុំ -- ពាក់ព័ន្ធទៅនឹងចម្លើយមួយ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនដែលកើតឡើងនៅក្នុងរដូវវស្សា ក្នុងឆ្នាំ១៩៧៧ ហើយខ្ញុំចង់សួរជាសំណួរៗបើកសិន បាទ។ ដូច្នេះហើយ ខ្ញុំអាចយកនូវចម្លើយនោះដើម្បីយោង។ ដូច្នេះ ខ្ញុំរីករាយក្នុងការយកចម្លើយដែលបញ្ជាក់នោះ ដើម្បីយោង បាទ ប្រសិនបើអាចនោះ។

**ប្រធានអង្គជំនុំ៖**

តាមធម្មតា សំណួរបើកយើងត្រូវធ្វើមុន ឲ្យបានច្បាស់លាស់ នៅគ្រប់ស្ថានភាព និងហេតុការណ៍ទាំងឡាយ ពាក់ព័ន្ធនឹងចម្លើយដែលគាត់បានឆ្លើយលើកមុន ហើយបន្ទាប់មក បើសិនជាគាត់ឆ្លើយទៅ វាមានបញ្ហាត្រូវផ្ទៀងផ្ទាត់ជាមួយនឹងសក្ខីកម្មពីមុន ទើបយកដកស្រង់នូវសក្ខីកម្មពីឯកសារលើកមុន ដើម្បីសួរបញ្ជាក់គាត់ឲ្យច្បាស់លាស់ ថាតើគាត់នៅចាំដែរទេ ចម្លើយពីមុនហ្នឹង ធៀបជាមួយនឹងគាត់បានចងចាំបានដែរឬទេ។ សូមរៀបចំនូវសំណួរឡើងវិញឲ្យបានច្បាស់លាស់ត្រឹមត្រូវ ជៀសវាងមានបញ្ហា ព្រោះរឿងនេះយើងធ្វើច្រើនដងមកហើយ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមថ្លែងអំណរគុណ បាទ លោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីថា មិនបានចាំពាក់ព័ន្ធទៅនឹងសំណួរនេះ

ជាពិសេស នៅពេលដែលប្ដីលោកស្រីត្រូវបានគេចាប់យកទៅ ហើយខ្ញុំសូមបញ្ជាក់ទៅលើព័ត៌មានមួយ គឺ D22/212 ហើយខ្មែរជាភាសាខ្មែរ គឺ004181584, អង់គ្លេស 0024285 ហើយនៅក្នុងនោះ គឺបានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៧ នៅរដូវវស្សានោះ គឺប្ដីលោកស្រីត្រូវបានគេចាប់យកទៅ។ ថាតើលោកស្រីអាចចងចាំទេថា ពេលដែលប្ដីលោកស្រីត្រូវបានចាប់នោះ គឺនៅក្នុងរដូវវស្សា គឺក្នុងឆ្នាំ១៩៧៧ លោកស្រីចាំបានទេ?

**លោកស្រី ដួង អឿន៖**

**ឆ៖** ចាំបាន គេយកទៅ ខ្ញុំកំពុងតែច្រូត មកពីច្រូតមិនទាន់ប្ដីទេ គេយកទៅបាត់ហើយ។ ខ្ញុំដល់អ៊ីចឹងទៅ ខ្ញុំមកដល់ផ្ទះហើយ ខ្ញុំត្រឡប់ទៅវិញទៅ ថាគាត់គេយកទៅហើយ។ ខ្ញុំក៏ទៅផ្ទះវិញមក។ ខ្ញុំអត់មានឃើញគាត់ថា គេយកទៅឯណេះ ទៅឯណោះទេ ខ្ញុំអត់ឃើញទេ។

**ប្រធានអង្គជំនុំ៖**

សំណួរមិនសួរអ៊ីចឹងទេ។ បំណងនៃសំណួរសួរថាតើលោកស្រីចាំថា គេនាំយកប្ដីលោកស្រីទៅបាត់រហូតដល់សព្វថ្ងៃនោះ តើគេយកទៅនៅឆ្នាំណា នៅពេលណា នៅរដូវវស្សាឆ្នាំ១៩៧៧ ឬក៏ឆ្នាំ១៩៧៨? នេះជាសំណួរទូទៅ ពីព្រោះមានចម្លើយមួយថា ឆ្នាំ១៩៧៨ ហើយនៅក្នុងឯកសារលោកស្រីឆ្លើយលើកមុនថា នៅក្នុងរដូវវស្សាឆ្នាំ១៩៧៧។ ឥឡូវនេះ ចង់សួរអំពីពេលវេលាកាលៈទេសៈដែលត្រូវបានកងកម្លាំង កងឈ្លប ឬក៏សន្តិសុខនៅតំបន់ហ្នឹងបាននាំប្ដីលោកស្រីចាកចេញទៅបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ នៅពេលណា? ឆ្នាំណា?

**លោកស្រី ដួង អឿន៖**

**ឆ៖** ឆ្នាំ៧៧ ត្រង់ខែណាៗ ខ្ញុំមិនដឹងទេ ប៉ុន្តែដឹងថា៧៧។

[១០:៤២:០០]

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** សូមថ្លែងអំណរគុណលោកស្រី។ លោកស្រីបានបញ្ជាក់ថា ក៏ដូចជាមុនហ្នឹងក៏លោកស្រីបានបញ្ជាក់ផងដែរថា គឺលោកស្រីមិនបានត្រឡប់មកភូមិវិញដើម្បីដឹងថា ប្ដីហ្នឹងត្រូវបានគេចាប់យកទៅ ហើយលោកស្រីបានបញ្ជាក់ថា លោកស្រីដឹងអំពីការចាប់ខ្លួនទៅនោះ គឺដឹងពីម្ដាយរបស់លោកស្រី។ បាទ នៅក្នុងកំណត់ហេតុចម្លើយសាក្សីគឺ E3/7809, ភាសាអង់គ្លេស 00282563, ខ្មែរ00271368 ភាសាបារាំង 0084003។ លោកស្រីបញ្ជាក់ថា បានឃើញនូវប្ដីខ្ញុំដើរពីមុខមិនជាប់ចំណង ហើយឈ្លប

តាមពីក្រោយទៅដល់ផ្លូវបំបែក ទៅកំចាយមារហ្នឹងគឺឈ្លបក៏បានដាក់ប្ដីខ្ញុំលើរទេះសេះទៅ ខ្ញុំមិនដឹងទៅទីណា។ តើលោកស្រីចាំបានទេ ថានៅពេលនោះ គឺលោកស្រីបានមានសង្កេតឃើញដែលថា ប្ដីរបស់លោកស្រីត្រូវបានគេចាប់យកទៅដែរឬទេ?

**ផ៖** ត្រង់គេដាក់រទេះសេះទៅ ខ្ញុំអត់ដឹងដែរ ខ្ញុំអត់បានឃើញគាត់ផងហ្នឹង។ ត្រង់គាត់ដាក់រទេះសេះ គេយកដាក់រទេះសេះទៅ ខ្ញុំអត់ឃើញគាត់ដែរ។ ជំនាន់នោះម៉េចនឹងហ៊ានទៅ។ មិនហ៊ានទៅតាមដានខ្លាច។ ត្រង់ថាយកគាត់ទៅណាៗទៀត ខ្ញុំអត់ដឹងទេ។

**ស៖** តើលោក -- តាមម្ដាយរបស់លោកស្រី ឬក៏មានអ្នកណាទៀត បានប្រាប់ ឬក៏បុគ្គលដែលយើងបានបញ្ជាក់កាលពីមុននោះ គឺដូចជា លោក ហាន ឬក៏លោកសេង លោកជឹម។ តើមាននៅទីនោះទេបាទ? គឺពួកអ្នកទាំងអស់នេះ មាននៅឃើញថា ប្ដីលោកស្រីត្រូវបានគេចាប់យកទៅដែរឬទេ?

**ផ៖** ត្រង់ពួកនោះ ខ្ញុំអត់ដឹងទេ ខ្ញុំដឹងពីម៉ែខ្ញុំតែម្ដងព្រោះគាត់នៅផ្ទះ។ គេមកយកទៅ ក៏ម៉ែខ្ញុំនៅផ្ទះដែរ គាត់ឃើញ។ ខ្ញុំមកវិញគេប្រាប់ខ្ញុំ គាត់ប្រាប់ខ្ញុំថា ខ្ញុំ-- "មើល៍ គេយកប្ដីអ្វែង ទៅហើយ។ ត្រង់យកទៅឯណាៗអញមិនដឹងទេ តែអញឃើញគេនាំទៅ"។ គ្រាន់តែថាប៉ុណ្ណឹងទៅ គាត់និយាយប្រាប់ប៉ុណ្ណឹងទៅ ខ្ញុំទៅច្រូតវិញទៅ។ អត់ហ៊ាននៅផ្ទះយូរទេ។

[១០:៤៥:០៨]

**ស៖** តើលោក -- តើម្ដាយរបស់លោកស្រីបានបញ្ជាក់ថា ពួកឈ្លបអីនោះ គឺមាននៅទីនោះដែរឬទេ នៅពេលដែលប្ដីលោកស្រីនោះត្រូវបានគេចាប់នោះ? ហើយមានប៉ុន្មាននាក់?

**ផ៖** អត់បានឃើញទេ ឃើញតែម្នាក់ទេ មិនច្រើនគ្នាទេ។ ឃើញគេបណ្ដើរគាត់ទៅតែម្នាក់ទេ ម៉ែខ្ញុំគាត់ថាអ៊ីចឹង បានជាខ្ញុំដឹងនុ៎ង។ ខ្ញុំដល់ឮគាត់ថាអ៊ីចឹងទៅ ខ្ញុំទៅធ្វើការវិញទៅ។

**ស៖** តើលោកស្រីមានបានសួរពួកឈ្លបដែរទេថា តើពួកនោះមាន និង -- តើពួកគេមានយកកូនស្រីលោកស្រីទៅទេ? តើហេតុអ្វីបានជាត្រូវយកកូនស្រីហ្នឹងទៅបាទ?

**ផ៖** គេអត់យកទៅទេកូននោះ គេយកតែឪពុកទៅទេ ហើយខ្ញុំមានសួរមាននាំអីទេ។ គ្មានសួរនាំគេថា អើឥឡូវគេយកកូនទៅដែរក៏មិនអី ខ្ញុំអត់បានសួរដែរ គេក៏មិនប្រាប់យើងដែរ យើងសួរគេ។

**ស៖** បាទ ខ្ញុំសូមអានន្ទូវចម្លើយដែលលោកស្រីបានបញ្ជាក់នៅក្នុងបទសម្ភាសន៍ 7809 ជាភាសាអង់គ្លេស 00282565, ជាភាសាខ្មែរ 00271367, ហើយជាភាសាបារាំងគឺ 0048013 ហើយនៅក្នុងឯកសារនោះបានបញ្ជាក់ថា៖ "ខ្ញុំបានសួរពួកឈ្លបនេះ ហើយឆ្លើយថាយកប្ដីខ្ញុំទៅកាត់រពាក់។

ហើយខ្ញុំសួរថា យកកូនខ្ញុំទៅណាទេ? រួចឈ្លបក៏ឆ្លើយថាម្ដាយជាខ្មែរគេមិនយកកូនទៅទេ"។ សូមបញ្ចប់សម្រង់។ លោកស្រីដើមបណ្ដឹង តើអ្វីដែលខ្ញុំបានអាននេះ តើធ្វើឱ្យលោកស្រីបានចងចាំទេ ថាពាក់ព័ន្ធនឹងបញ្ហាឈ្លបដែលនឹងមិនចាប់កូនលោកស្រីនេះ?

**ឆ៖** គេវាមិនចាប់មែន កាលនុ៎ងអត់មានអ្នកណាយកទៅទេ ស្មានតែកូនខ្មែរ -- អ៎! ម៉ែខ្មែរ កូនខ្មែរអត់យកទៅទេ គេយកទៅតែឪពុកទេ។ បានជាកូនខ្ញុំនៅហ្នឹងនោះ បើគេយកទៅ ទៅទាំងអស់ហើយ។ ចេះតែលាក់លៀម ចេះតែបិទបាំងអ៊ីចឹងដែរ។

[១០:៤៨:២០]

**ស៖** តើហេតុអ្វីបានជាគេយកកូនហ្នឹងទៅដែរ បើសិនជាម្ដាយហ្នឹងជាជនជាតិវៀតណាម?

**ឆ៖** ជនជាតិវៀតណាមហ្នឹងយកទៅទាំងអស់ហើយ វាមិនទុកទេ ជំនាន់នុ៎ងនោះ។ ទាល់តែម៉ែខ្មែរ គេយកតែប្ដីទៅៗ។

**ប្រធានអង្គជំនុំ៖**

លោកស្រីស្ដាប់សំណួរអត់បាន ស្ដាប់សំណួរអត់យល់។ គេសួរថាហេតុអី? លោកស្រីដឹងទេ ហេតុអីបានគេយកម្ដាយជាវៀតណាម ហើយបានគេទាំងកូន ហើយបើសិនបើម្ដាយជាខ្មែរ គេមិនយកកូនទេ គេយកតែឪពុក? នេះជាសំណួរ គេចង់ដឹងហេតុអីដែលលោកស្រីដឹងទេ ព័ត៌មានពាក់ព័ន្ធនឹងបញ្ហានេះ។

**លោកស្រី ដួង អឿន៖**

**ឆ៖** ខ្ញុំអត់ដឹងផង ខ្ញុំមិនដឹងទេ មិនដឹងគេយកទៅម៉េចអីម៉េច ខ្ញុំមិនដឹងដែរ។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** នៅពេលដែលគេប្រាប់លោកស្រីថា ប្ដីរបស់លោកស្រីត្រូវបានគេយកទៅ ហើយដើម្បីឱ្យទៅកាប់រពាក់នោះ តើលោកស្រីគិតថាពួកគេពិតជាឱ្យគាត់ទៅកាប់រំពាក់មែនឬទេ?

[១០:៥០:០២]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ចំពោះសំណួរនេះ ពីព្រោះសហព្រះរាជអាជ្ញាសួរឱ្យសាក្សីឆ្លើយស្មាន ហើយពីព្រោះ

សាក្សី ដើមបណ្តឹងថាមិនបានឃើញដោយផ្ទាល់ភ្នែកថាគេយកប្តីគាត់ទៅទេ ហើយគាត់ក៏មិនបានដឹងព័ត៌មានហើយមិនមានៗព័ត៌មានណាដើម្បីឲ្យដើមបណ្តឹងហ្នឹងដឹងបានទេ កាលដែលសួរឲ្យគាត់គិតអ៊ីចឹងគឺជាការសួរឲ្យគាត់ធ្វើការនិយាយស្មានហើយ អ៊ីចឹង ខ្ញុំសូមជំទាស់។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

ខ្ញុំសូមឆ្លើយតប។ ដំបូងខ្ញុំបានរៀបចំសំណួរមួយ ក្នុងគំនិតមួយដែលថាគេប្រាប់គាត់ថាគេយកប្តីគាត់ទៅ ហើយខ្ញុំមិនសុំឲ្យគាត់ឆ្លើយព្រាវទេ ហើយក៏ខ្ញុំមិនបានសួរឲ្យគាត់គិតពីអ្វីកើតឡើងទេ ហើយខ្ញុំឲ្យគាត់ដែលថា គាត់គិតនៅពេលហ្នឹង តើគាត់គិតដូចម្តេច? ហើយមេធាវីក៏បានបញ្ជាក់ថា ខ្ញុំមិនបានគោរពតាមគោលការណ៍ហ្នឹង ហើយខ្ញុំមិនបានសួរឲ្យគាត់បញ្ជាក់អំពីគំនិតឲ្យគាត់ស្មាន ឬក៏និយាយព្រាវនោះទេ លោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់ របស់មេធាវីការពារក្តីលោក នួន ជា, លោក វ៉ិចទ័រ កូប៉េ អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបរបស់សាក្សីទៅនឹងសំណួរនេះ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញារងអន្តរជាតិ។

ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះ ប្រសិនបើលោកស្រីនៅចងចាំសំណួរ។

[១០:៥១:៤០]

**លោកស្រី ដួង អឿន៖**

**ឆ៖** ខ្ញុំអត់ចងចាំទេ ខ្ញុំភ្លេចបាត់ហើយ។ ខ្ញុំមិនចាំទេ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារង រៀបចំសំណួរសាជាថ្មីឡើងវិញ ហើយតាំងសំណួរចំពោះគាត់!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលគេប្រាប់ថា គេយកប្តីរបស់លោកស្រីទៅឲ្យកាប់រពាក់ពេលនោះ តើលោកស្រីគិតថាអ៊ីចឹងពិតមែនទេ ដែលថាគេឲ្យទៅគាត់ៗទៅកាប់រពាក់មែនឬទេនៅពេលហ្នឹង?

**លោកស្រី ដួង អឿន៖**

**ឆ៖** គេប្រាប់មែន ប្រាប់អ៊ីចឹង ប្រាប់ថា "ឲ្យទៅកាប់រពាក់ មិនដឹងថ្ងៃណាមកវិញទេ"។ គេថាអ៊ីចឹង ហើយវាបាត់ទាល់ដល់ថ្ងៃនេះទៅ។ មិនចាំអីទៀតទេ។

**ស៖** តើលោកស្រីជឿជាក់លើព័ត៌មានហ្នឹងដែលថាគេឲ្យទៅកាប់រពាក់ហ្នឹង លោកស្រីជឿកាលហ្នឹងថា គេពិតជាឲ្យទៅកាប់រពាក់មែន ឬក៏មិនជឿកាលហ្នឹង?

**ឆ៖** ពិតមែន កាលហ្នឹងពិត គ្មានភូត គ្មានកុហកអីទេ គេថាអ៊ីចឹងតែម្តង ខ្ញុំស្តាប់បានឮថាគេថាអ៊ីចឹង "ប្តីអ្វែងគេយកឲ្យទៅកាប់រពាក់ហើយ" ហើយបាត់ទាល់ឥឡូវហ្នឹងទៅ។

[១០:៥៣:៣០]

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអានសេចក្តីដកស្រង់ពីបទសម្ភាសន៍គឺ E3/7809 អង់គ្លេស 00282562, ខ្មែរ 00271367, បារាំង 00486103។ សំណួរគឺសួរលោកស្រីថា៖ "តើលោកស្រីដឹងដូចម្តេចនៅពេលដែលគេយកប្តីរបស់លោកស្រីទៅ?" ហើយក៏គេសួរអំពីកូនរបស់លោកស្រីដែរ លោកស្រីឆ្លើយថា "ខ្ញុំដឹងពីព្រោះ ប្អូន បីថ្ងៃក្រោយមកគឺថា ហើយៗប្តីរបស់មនុស្សម្នាក់ទៀតគឺត្រូវបានគេយកទៅកាប់រពាក់ដែរក៏បាត់ ហើយបន្ទាប់មកគឺ ឡាច នី ហ្នឹងក៏ត្រូវបានគេហៅឲ្យកាប់រពាក់ដែរ ហើយក្រោយមកក៏បាត់ទៅទៀត"។ អ៊ីចឹងសួរលោកស្រីថា តើនៅពេលដែលគេហៅប្តីលោកស្រីទៅកាប់រពាក់ហ្នឹង តើលោកស្រីដឹងថាគេយកទៅសម្លាប់ដែរឬទេ ឬក៏ជឿតាមដែលគេប្រាប់ថាយកទៅកាប់រពាក់មែន?

**ឆ៖** ខ្ញុំមិនដឹងទេ ប៉ុន្តែគេថាទៅកាប់រពាក់ ខ្ញុំថាទៅកាប់រពាក់មិនវិលវិញទេ តែកាប់ទៅហើយ ខ្ញុំនឹកក្នុងចិត្តខ្ញុំថាអ៊ីចឹង។ ថាទៅកាប់រពាក់មិនមកវិញទេទៅហើយ ហើយទៅបាត់ទាល់ឥឡូវហ្នឹងទៅមានឃើញស្អីមកវិញ។ តែអ៊ីចឹងទាំងអស់តែគ្នាហ្នឹង។

**ស៖** តើលោកស្រីដឹងដែរឬទេ ថាប្តីរបស់លោកស្រីបានប្រព្រឹត្តកំហុសអ្វីដែលនាំឲ្យគេមកចាប់ខ្លួនគាត់ទៅ?

**ឆ៖** កាលជំនាន់ហ្នឹង ខ្ញុំក៏មិនដឹងគាត់ម៉េច អីម៉េចដែរ ខ្ញុំអត់ដឹងទេ។ គាត់មានសួរនាំអីខ្ញុំ ប្រាប់ខ្ញុំទេ ខ្ញុំអត់ដឹងទេ ទាល់តែយកគាត់ទៅបាត់ទៅ បានខ្ញុំដឹងថាគាត់គេយកទៅហើយ។ គាត់គ្មាននិយាយអីប្រាប់ខ្ញុំអ៊ីចេះអ៊ីចុះទេ។

[១០:៥៦:០៥]

**ស៖** មុន ឬក៏ក្រោយគេចាប់ប្ដីរបស់លោកស្រី តើលោកស្រីធ្លាប់ឮពីខ្មែរក្រហមណាម្នាក់ទេ នៅក្នុងភូមិ ដែលនិយាយពីប្ដីរបស់លោកស្រី ឬក៏ជនជាតិវៀតណាមផ្សេងទៀតថា ជាខ្មាំង ឬក៏ជាខ្មាំងបង្កប់ទេនៅក្នុងភូមិលោកស្រី?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់នឹងពាក្យ ប្រើពាក្យថា“ការចាប់ខ្លួន”។ ពីដំបូងដើមបណ្ដឹងរដ្ឋប្បវេណីគាត់ធ្វើសក្ខីកម្មថា គាត់ឮពីម្ដាយគាត់ថា ប្ដីរបស់គាត់ គេបានបណ្ដើរប្ដីគាត់ទៅ ហើយក្រោយមកមានការផ្ដល់ព័ត៌មានថា គេយកទៅ បណ្ដើរចេញទៅ ហើយគាត់ប្រើពាក្យតាមសំណួរហ្នឹង គាត់មិនដែលនិយាយ។ ប៉ុន្តែគាត់មិនដែលប្រើពាក្យថាចាប់ខ្លួនទេ។ អ៊ីចឹងគឺថា ពាក្យថា “ចាប់ខ្លួននេះ” ជាពាក្យច្បាប់ ដែលតុលាការមិនឲ្យខ្ញុំប្រើដែរ។ អ៊ីចឹងហើយ សហព្រះរាជអាជ្ញាមិនគប្បីប្រើពាក្យដែលត្រូវហាមឃាត់នោះទេ។ អ៊ីចឹងខ្ញុំជំទាស់ការប្រើពាក្យថា “ចាប់ខ្លួន”នេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

ខ្ញុំរីករាយនឹងកែសម្រួលសំណួររបស់ខ្ញុំ ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្ដី។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសួរម្ដងទៀត។ មុនពេល ឬក៏ក្រោយពេលដែលគេយកប្ដីលោកស្រីទៅ តើលោកស្រីធ្លាប់ឮថាមេដឹកនាំ ឬក៏ខ្មែរក្រហមណាម្នាក់នៅក្នុងភូមិលោកស្រី និយាយពីប្ដីរបស់លោកស្រី ឬក៏វៀតណាមផ្សេងទៀតថាជាខ្មាំង ឬក៏ថាជាវៀតណាមបង្កប់អីដែរឬទេ?

**លោកស្រី ដួង អឿន៖**

**ឆ៖** អត់មានដែលនិយាយទេ ខ្ញុំអត់ដែលឮនិយាយទេ។ មានឮថាខ្មាំង មានឮថាអីទេ។ ស្រាប់ដល់ថ្ងៃហ្នឹងទៅ គេហៅគាត់ទៅតែម្ដងទៅ ត្រង់ថ្ងៃណាៗខ្ញុំមិនដឹងដែរ។ និយាយបានប៉ុន្មានហ្នឹង គាត់ទៅៗ។

[១០:៥៨:២៤]

**ស៖** ខ្ញុំអានសេចក្ដីដកស្រង់អំពីពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី គឺ D22/212, ខ្មែរ ERN 00418154, អង់គ្លេស ERN 00436795 (អត់មានអត្ថបទភាសាបារាំងទេ)

សេចក្តីដកស្រង់អ្វីដែលលោកស្រីនិយាយ៖ “នៅក្នុងរបបខ្មែរក្រហម មុនពេលដែលប្តីខ្ញុំបាត់ខ្លួន ខ្មែរក្រហមប្រើពាក្យអាក្រក់ ពាក្យមើលងាយ ដែលប្រឆាំងនឹងប្តីរបស់ខ្ញុំ ហើយគេនិយាយថា គាត់ជាខ្មាំងយួន។” តើខ្ញុំអានប៉ុណ្ណេះ ធ្វើឲ្យលោកស្រីនឹកឃើញទេ ដែលថាខ្មែរក្រហមប្រើពាក្យប្រមាថមើលងាយប្តីរបស់លោកស្រីថាជាខ្មាំងយួន?

**ឆ៖** អត់ៗមានផង គេអត់មាននិយាយអីទេ។ គេនិយាយឯណាទៀត ខ្ញុំអត់ឮ ខ្ញុំអត់ដឹងទេ។ ប៉ុន្តែទាល់និយាយចំពោះមុខខ្ញុំ ខ្ញុំមិនដែលដឹងទេ។ អ្នកធ្វើការទាំងអស់គ្នា គ្មានអ្នកណាដឹងទេ។

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀត ខ្ញុំសួរលោកស្រីអំពីបុគ្គលផ្សេងទៀត ដែលយើងនិយាយព្រឹកមិញ គឺមនុស្សពីរនាក់ ដែលមានជនជាតិវៀតណាមនៅក្នុងភូមិរបស់លោកស្រី ដែលគេយកអ្នកទាំងពីរនាក់ហ្នឹងទៅដែរ យកចេញទៅ។ ទី១ ខ្ញុំសួរលោកស្រីអំពីឈ្មោះ ង៉ាង តើលោកស្រីប្រាប់តុលាការបានទេ តើលោកស្រីបានឃើញដែរឬទេ នៅពេលដែលគេយក ង៉ាង ចេញពីភូមិទៅនោះ?

**ឆ៖** ខ្ញុំអត់បានឃើញទេ ប៉ុនគ្រាន់តែឮថាគេយកវាទៅកាប់រពាក់ដែរ ប្រាប់ឃ្លាងទៅបាត់រហូតទាល់ឥឡូវហ្នឹងនេះទៅ។ ខ្ញុំអត់បានដឹងថា គេយកទៅថ្ងៃណា ខែណា ខ្ញុំអត់ដឹងទេ។ គ្រាន់តែដឹងថា គេ ង៉ាង ហ្នឹង ទៅមុន។ វាមានមកវិញឯណា ទៅហ្មង។

**ស៖** អ៊ីចេះប្រពន្ធរបស់គាត់ តើប្រពន្ធគាត់ជាជនជាតិវៀតណាម ឬក៏ជាជនជាតិខ្មែរ?

**ឆ៖** ខ្មែរ ខ្មែរសុទ្ធ។ ប្រពន្ធក៏មិនដែលនៅស្រុកដែរ ឥឡូវ មិនដឹងទៅនៅណា នៅណីទេ។ កាលជំនាន់នុ៎ង នៅនុ៎ង ឥឡូវទៅណាណីទេ ខ្ញុំអត់ដឹងដែរ។

[១១:០១:៣៥]

**ស៖** តើគេយកគាត់ទៅបាត់ដែរឬទេ ប្រពន្ធរបស់គាត់នេះ ប្រពន្ធ ង៉ាង នេះ?

**ឆ៖** ប្រពន្ធ ង៉ាង នៅទេ នៅស្រុកហ្នឹង សព្វថ្ងៃ ប៉ុនមិនមែននៅហ្នឹងទេ ឥឡូវទៅនៅណាស្រុកគេបាត់ហើយ ដែលនៅស្រុកនៅភូមិហ្នឹងទេ ឥឡូវ។ ទៅនៅស្រុកគេផ្សេងហើយ។

**ស៖** តើលោកស្រីចាំដែរឬទេថា ង៉ាង ហ្នឹង គេយកទៅចេញពីភូមិហ្នឹង យកក្នុងខែ ឆ្នាំណា លោកស្រីចាំទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ចាំទេ ដឹងយកទៅខែណា ឆ្នាំណាទេ ខ្ញុំអត់ចាំទេ។ ខ្ញុំភ្លេចបាត់ហើយ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរលោកស្រីពីរបីសំណួរទៀត អំពីបុគ្គលម្នាក់ទៀត ដែលលោកស្រីបញ្ជាក់ព្រឹកមិញនេះ គឺសួរពីប្រពន្ធរបស់ ឡាច នី។ លោកស្រីនិយាយព្រឹកមិញនេះ គ្រាន់តែថា លោកស្រីអាច

ចាំ មិនចាំឈ្មោះទេ។ បើខ្ញុំនិយាយថា ឈ្មោះ ស៊ុន សាន។ តើលោកស្រីអាចនឹកឃើញពីឈ្មោះប្រពន្ធ ឡាច នី ដែរឬទេ? តើនឹកឃើញទេ ពេលដែលខ្ញុំប្រាប់ឈ្មោះថា ស៊ុំ សាន នេះ?

**ធ៖** ខ្ញុំអត់ស្តាប់បាន ខ្ញុំអត់នេះទេ ខ្ញុំមិនស្គាល់ឈ្មោះគាត់ទេ។ ខ្ញុំភ្លេចគាត់ហើយ មិនដឹងឈ្មោះអីទេ ខ្ញុំអត់ដឹង ខ្ញុំអត់ចាំផង។

**ស៖** តើលោកស្រីបានឃើញដែរឬទេ នៅពេលដែលគេយកគាត់ចេញពីភូមិទៅ?

**ធ៖** ខ្ញុំអត់បានឃើញទេ។ ស្រាប់តែគាត់ទៅបាត់ដែរទៅ ខ្ញុំអត់ដឹងទេ អត់ឃើញគាត់ទៅ មិនទៅ ខ្ញុំអត់ឃើញទេ។ ស្រាប់តែគាត់ទៅបាត់ដែរ ដូចតែគ្នាហ្នឹងទៅ។

[១១:០៥:០១]

**ស៖** តើលោកស្រីបានដឹងដោយរបៀបណា ថាគេយកគាត់ពីភូមិទៅនោះ បើលោកស្រីមិនបានឃើញផង?

**ធ៖** ស្រាប់តែគាត់បាត់តាំងពីថ្ងៃហ្នឹងទៅដែរ។ បាត់ខ្លួនតាំងពីថ្ងៃហ្នឹងទៅ។ ព្រោះគេយកគាត់ទៅដែរ ទាំងកូនទាំងចៅទាំងអស់នុ៎ង នៅតែប្តីម្នាក់ឯងនុ៎ង។

**ស៖** សំណួររបស់ខ្ញុំសួរលោកស្រីថា តើលោកស្រីដឹងដោយរបៀបណា ថាគេយកគាត់ទៅ និងកូនគាត់ទៅហ្នឹង មានអ្នកណាប្រាប់ ឬក៏លោកស្រីដឹង ដឹងដោយរបៀបណា?

**ធ៖** ដោយរបៀបបាត់ខ្លួននុ៎ង បានខ្ញុំដឹងនុ៎ង បាត់មនុស្ស។ បាត់ពីនៅស្រុកភូមិហ្នឹងទៅ បានខ្ញុំដឹង។ ព្រោះគេយកទៅអស់ហើយ គាត់ក៏ទៅដែរហើយ គេមិនទៅទុកគាត់ទេ។

**ស៖** តើលោកស្រីដឹងពីមូលហេតុថា ហេតុអីបានគេយកកូនទៅជាមួយម្តាយក្នុងពេលតែមួយ?

**ធ៖** ថាម៉ែយួន គេយកទៅនុ៎ង។ ឲ្យតែម៉ែយួន គេយកទៅហើយ។ តែមួយគេមិនទុកឲ្យផង។

**ស៖** តើលោកស្រីបានឃើញប្រពន្ធរបស់ ឡាច នី ហើយនិងកូនៗរបស់គាត់ទេ ក្រោយពីគេយកអ្នកទាំងនោះទៅ ធ្លាប់បានឃើញជាថ្មីម្តងទៀតនៅកន្លែងណាទេ?

**ធ៖** កន្លែងនៅនឹងភូមិពោធិ៍ចិន្តាំនុ៎ងដែរ ប៉ុនទាស់គាត់នៅឆ្ងាយពីខ្ញុំបន្តិច មិននៅជិតគ្នាទេ។ គាត់នៅថ្នល់នេះ ហើយខ្ញុំនៅឯក្រោយគាត់នុ៎ងទៀត។

**ប្រធានអង្គជំនុំ៖**

សំណួរមិនសួរអីចឹងទេណា៎ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ គេសួរថា តាំងពីមានព័ត៌មានដែលលោកស្រីបានដឹង ទទួលដំណឹងថាបានត្រូវគេយកទៅបាត់នុ៎ង រហូតមកដល់ -- ជាពេលវេលាបន្ត

បន្ទាប់រហូត មកដល់ពេលនេះ មកដល់ក្រោយមកទៀត តើលោកស្រីធ្លាប់បានជួបប្រពន្ធរបស់ ឡាច នី និងកូនៗរបស់ ឡាច នី សាជាថ្មីដែរឬទេ?

[១១:០៦:៤៦]

**លោកស្រី ដួង អឿន៖**

**ឆ៖** ខ្ញុំអត់ដែលជួបទេ ខ្ញុំអត់ដែលឃើញទេ។ ខ្ញុំមិនជួបទេ ខ្ញុំមិនដែលឃើញគាត់ទៀតផង។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** តើត្រឹមត្រូវដែរឬទេ -- ប្ដូរវិញ។ តើក្រៅពីបុគ្គលបីរូបដែល ង៉ាង ហើយនិងប្រពន្ធរបស់ ឡាច នី តើមានជនជាតិវៀតណាមណាផ្សេងទៀតនៅពោធិ៍ចិន្ដាំដែរឬទេ នៅក្នុងរបបខ្មែរក្រហម តាមដែលលោកស្រីស្គាល់ និងដឹង?

**ឆ៖** អត់មានទេ មានតែប៉ុននុ៎ងគ្រួសារទេ អត់មានលើសពីនុ៎ងទៀតទេ។ ខ្ញុំដឹងតែប៉ុណ្ណឹង ត្រង់ពីណាទៀត ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកស្រីធ្លាប់ចូលរួមប្រជុំណាមួយទេ ដែលខ្មែរក្រហមគេហៅទៅប្រជុំកាលនោះ?

**ឆ៖** គេហៅដែរ ប៉ុន្ដែខ្ញុំភ្លេចអស់ហើយ មិនដឹងឯណា ឯអីទេ ខ្ញុំមិនចាំទេ។ ខ្ញុំអត់ចាំ ភ្លេចអស់ហើយ។

**ស៖** ខ្ញុំយល់ហើយថារឿងនេះកើតយូរមកហើយ ប៉ុន្ដែខ្ញុំសួរលោកស្រីថា តើលោកស្រីនៅនឹកឃើញដែរទេ ពីបញ្ហាទាក់ទងទៅនឹងជនជាតិវៀតណាម? តើគេមានពិភាក្សា ឬក៏និយាយនៅក្នុងប្រជុំទេ ពីរឿងបញ្ហាជនជាតិវៀតណាម កាលនោះ?

**ឆ៖** វាអត់ វាមិនដែលនិយាយផង។ ប្រជុំៗទៅ អីៗទៅ វាមិនដែលនិយាយទេ។

[១១:០៩:០០]

**ស៖** ខ្ញុំនៅចង់រំឭកការចងចាំរបស់លោកស្រី។ ខ្ញុំយោងទៅរកៗចម្លើយរបស់លោកស្រីដែលឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/7562, អង់គ្លេស 001170704, ហើយខ្មែរ ERN 00034100 ខ្ញុំមិនជឿថា មានការបកទៅជាភាសាបារាំងទេឥឡូវនេះ។ គេសួរលោកស្រីនូវសំណួរមួយចំនួន អំពីការប្រជុំ។ "សំណួរ៖ តើគេបានព្យាយាមបង្កើតពីចេតនាអាក្រក់ ប្រឆាំងនឹងក្រុមគ្រួសារវៀត-ណាមទេ? លោកស្រីឆ្លើយថា៖ គេបានធ្វើ គេបានរិះគន់យើងជាច្រើន។ សំណួរ៖ តើគេនិយាយអំពីជនជាតិវៀតណាមទេ នៅក្នុងប្រជុំ? លោកស្រីឆ្លើយថា៖ ចា៎ស ពិតមែនគេនិយាយរហូតនៅពេលដែលគេ

ប្រជុំ។" សូមដកស្រង់ -- ចប់សេចក្តីដកស្រង់។

ខ្ញុំអានចម្លើយរបស់លោកស្រីបែបនេះ តើរំឭកឱ្យលោកស្រីនឹកឃើញវិញទេ គឺថាវាមានការប្រជុំមួយចំនួនដែលគេនិយាយពីបញ្ហាជនជាតិវៀតណាម នៅក្នុងប្រជុំនោះ គឺក្រុមគ្រួសារវៀតណាម?

**ឆ៖** គេនិយាយមែន ប៉ុនកាលជំនាន់ហ្នឹងគេគ្រាន់តែថា វាឃើញគេនិយាយពីរឿងរិះគន់ហ្នឹងមែន ប៉ុនត្រង់ម៉េចៗទៀត ខ្ញុំអត់ដឹងទេ។ គ្រាន់តែគេឮគេនិយាយថាអ៊ីចឹង។

**សៈ** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីធ្លាប់បានឃើញបុគ្គលណាម្នាក់ដែលជាជនជាតិវៀតណាម ដែលមិនមែនជាអ្នកភូមិរបស់លោកស្រី ហើយត្រូវបានគេនាំខ្លួនយកទៅបាត់ដែរទេ?

**ឆ៖** អត់បានដឹងទេ អត់មានទេ។ ឃុំគេក្រៅទៀត ក៏មិនឮដែរ។ អត់ដឹងទេ។

**សៈ** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីធ្លាប់ឮវត្តមួយនៅក្បែរភូមិពោធិ៍ចិន្តាំ ឈ្មោះវត្តចាស់ ឬក៏អូរកណ្តាល លោកស្រីធ្លាប់ឮទេ?

**ឆ៖** នៅវត្តស្វាយអន្ទរ -- អុំ! នៅភូមិពោធិ៍ចិន្តាំហ្នឹង គ្មានដែលឮទេ។ ខ្ញុំអត់ដឹងទេ នៅភូមិឯណា ខ្ញុំមិនដឹងទេ។

**សៈ** សូមទោស ក្រែងលោកខ្ញុំសួរទៅវាមិនច្បាស់ តាមដែលខ្ញុំដឹងនោះ ថាវត្តហ្នឹងមិននៅក្នុងភូមិពោធិ៍ចិន្តាំទេ វាវត្តនេះ គឺមានទីតាំងនៅជិតភូមិអូរកណ្តោល។ នៅក្នុងបរិវេណមួយហ្នឹងគេហៅថាវត្តចាស់ ឬក៏វត្តអូរកណ្តោល លោកស្រីស្គាល់ដែរទេ?

[១១:១២:៥៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោកស្រី ដួង អឿន៖**

**ឆ៖** ខ្ញុំស្គាល់ ប៉ុនត្រង់ម៉េចៗទៀត ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹង ខ្ញុំឃើញ ខ្ញុំស្គាល់ អូរកណ្តោលចាស់ហ្នឹងនោះ ឥឡូវគេសង់ថ្មីអស់ហើយ។

**សៈ** តើលោកស្រីដឹងថានៅក្នុងរបបខ្មែរក្រហម គេបានយកវត្តនេះទៅប្រើប្រាស់ជាអ្វីដែរ?

**ឆ៖** ខ្ញុំអត់ដឹងទេៗ។ ត្រង់ហ្នឹង អង្កាល់នុំង គេយកមិនដឹងទៅធ្វើអីៗ ខ្ញុំមិនដឹងទេ។ ខ្ញុំអត់ស្គាល់ ខ្ញុំអត់ដឹងផង។ ភូមិនៅឆ្ងាយពីគ្នាដែរ មិនមែននៅជិតអីណា។

**សៈ** តើលោកស្រីស្គាល់មនុស្សម្នាក់ដែលធ្លាប់រស់នៅភូមិពោធិ៍ចិន្តាំ ឈ្មោះ ទ្រី ស្គាល់ដែរទេ?

**ឆ៖** ឈ្មោះ ទ្រី ណាទេ ខ្ញុំអត់ស្គាល់ផង។ ភ្លេចគេបាត់ហើយ ខ្ញុំមិនដឹងឈ្មោះទេ ខ្ញុំមិនស្គាល់ឈ្មោះផង។

**ស៖** ខ្ញុំ គេប្រាប់ខ្ញុំថា អំណានខ្ញុំជាភាសាខ្មែរហ្នឹង មិនច្បាស់ទេ មិនល្អទេ។ ឈ្មោះ ទ្រី?

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ឈ្មោះដែលសហការីអន្តរជាតិចង់និយាយដល់ គឺឈ្មោះ គ្រី។

**លោកស្រី ដួន អឿន៖**

**ឆ៖** ឈ្មោះ គ្រី មានតែប្អូនខ្ញុំជីដូនមួយហ្នឹង។ ខ្ញុំស្គាល់វាតែប៉ុណ្ណឹង បើ គ្រី ណាទៀត ខ្ញុំអត់ដឹងទេ។ គ្រី ហ្នឹងខ្ញុំស្គាល់។

**ស៖** ខ្ញុំមិននិយាយសំដៅទៅជីដូនមួយលោកស្រី ឈ្មោះគ្រី ហ្នឹងទេ។ បាទ ឥឡូវ ខ្ញុំសូមមកសួរសំណួរបើកសិន មុននឹងប្រើប្រាស់ឯកសារបុគ្គលនេះ។ បុគ្គលនេះឈ្មោះ គ្រី ហើយបុគ្គលនេះ គឺថាមានរទេះសេះមួយ តើលោកស្រីអាចនៅនឹកឃើញទេថា មនុស្សម្នាក់ហ្នឹង ឈ្មោះ គ្រី ហ្នឹងហើយធ្លាប់មានរទេះសេះមួយ?

**ឆ៖** ធ្លាប់មានរទេះសេះមួយ គាត់ស្លាប់បាត់យូរហើយ ឈ្មោះមែន ឈ្មោះគ្រី ហ្នឹងមែន គាត់មានរទេះសេះមួយ ប៉ុន្តែគាត់ស្លាប់បាត់ហើយ ស្លាប់យូរហើយ។ កាលជំនាន់ហ្នឹងគាត់មាន។ គាត់ស្លាប់បានប៉ុន្មានឆ្នាំ ប្អូនដប់ម្ភៃសាមសិបឆ្នាំហើយយ៉ាង។

[១១:១៦:៣៩]

**ស៖** តើលោកស្រីធ្លាប់នឹកឃើញ ដឹងថាគាត់យករទេះសេះរបស់គាត់ហ្នឹង ទៅដឹកមនុស្សម្នាក់ចេញពីពោធិ៍ចិន្តាំ ចេញទៅបា ត់ធ្លាប់ដែលដឹង ធ្លាប់ដែលឮទេ?

**ឆ៖** ខ្ញុំមិនដែលឮទេ។ គាត់មានមែន ប៉ុន្តែត្រង់គាត់ដឹកមនុស្សទៅ ខ្ញុំអត់ដឹងទេ។ ខ្ញុំទៅធ្វើការបាត់ៗទៅ ខ្ញុំមិនដែលដឹងគាត់យកអ្នកណាអ្នកណីទៅទេ ខ្ញុំមិនដឹងទេ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយសហការីជាតិរបស់ខ្ញុំគាត់មានសំណួរខ្លះ។

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ លោកប្រធាន លោក លោកស្រី ចៅក្រម និងអង្គ

សវនាការទាំងមូល។ សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះសុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ ហើយខ្ញុំនៅមានសំណួរមួយចំនួនតូចទេ ដើម្បីសួរបញ្ជាក់ទៅលោកស្រី។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើប្ដីរបស់លោកស្រីហ្នឹងគាត់ចេះនិយាយភាសាខ្មែរទេ? ហើយបើសិនជាគាត់ចេះ តើនិយាយច្បាស់ដែរឬទេ?

**លោកស្រី ដួង អឿន៖**

**ឆ៖** គាត់និយាយ អត់ច្បាស់ទេៗ និយាយស្ដាប់មិនបានផង។

[១១:១៨:២០]

**ស៖** ហើយលោកស្រីបញ្ជាក់បានទេថា ប្ដីរបស់លោកស្រីហ្នឹង មករស់នៅក្នុងភូមិពោធិ៍ចិន្ដាំជាមួយលោកស្រីហ្នឹង តាំងពីក្នុងឆ្នាំណាដែរ ឬក្នុងរបបណាដែរ?

**ឆ៖** ខ្ញុំអត់ចាំទេ ព្រោះយូរហើយ ខ្ញុំភ្លេចបាត់ហើយ មិនដឹងឯណាឯណីទេ។ ខ្ញុំភ្លេច។ មិនដឹងឆ្នាំណា ខែណាទេ ព្រោះយូរហើយ។

**ស៖** តើគាត់មករួមរស់ជាមួយលោកស្រីនៅក្នុងភូមិកំណើតរបស់លោកស្រីហ្នឹងមុនខ្មែរក្រហមមកដល់ ឬក៏នៅក្នុងអំឡុងពេលហ្នឹង?

**ឆ៖** ចូលក្នុងខ្មែរក្រហម។

**ស៖** កាលពីព្រឹកមិញ លោកស្រីបានប្រាប់តុលាការថា លោកស្រីមករួមរស់ជាមួយប្ដីលោកស្រីហ្នឹងនៅក្នុងរបបលន់នល់។ អ៊ីចឹងមុនខ្មែរក្រហម តើខ្ញុំនិយាយអ៊ីចឹងត្រូវទេ?

**ឆ៖** គាត់មកនៅមុនខ្មែរក្រហម។

**ស៖** អ៊ីចឹងពេលដែលគាត់មករស់នៅក្នុងភូមិហ្នឹង ការរស់នៅរបស់គាត់ ជាមួយនឹងប្រជាពលរដ្ឋដែលជាជនជាតិខ្មែរហ្នឹង រស់នៅចុះសម្រុងជាមួយគ្នាដែរឬទេ?

**ឆ៖** គាត់មិនដែលមានមូលហេតុអីទេ គាត់មានទៅអីអ្នកណា អីអ្នកណីទេ។ នៅរួមគ្នាទាំងអស់ សុខសប្បាយទាំងអស់គ្នា មិនដែលគាត់ទៅធ្វើអីអ្នកណាទេ គេក៏មិនទៅធ្វើអីគាត់ដែរ។

**ស៖** ចុះលោកស្រីដឹងទេថាគ្រួសារជនជាតិវៀតណាមផ្សេងទៀត ដែលរស់នៅក្នុងភូមិរបស់លោកស្រីមុនខ្មែរក្រហមចូលមកដល់ហ្នឹង ការរស់នៅរបស់គាត់ហ្នឹង ចុះសម្រុងជាមួយនឹងប្រជាជនខ្មែរដែលរស់នៅក្នុងភូមិជាមួយគ្នាដែរឬទេ?

**ឆ៖** ដែលគ្មានពីណាប្រឆាំងទេ នៅសុខស្រួលទាំងអស់គ្នា។ អ្នកណាធ្វើអីធ្វើទៅ អ្នកណារកអីរកទៅ កាលជំនាន់ហ្នឹង អត់មានធ្វើបាបអីយើងទេ។

**សៈ** ក្រោយរបបខ្មែរក្រហម លោកស្រីនៅតែរស់នៅក្នុងភូមិហ្នឹងរហូតមក ឬក៏មានផ្លាស់ទីទៅកន្លែងណាដែរ ឬក៏នៅប្រចាំនៅក្នុងហ្នឹងរហូតតាំងពីមុនខ្មែរក្រហម អំឡុងរបបខ្មែរក្រហម ហើយក្រោយហ្នឹងទៀត ក៏នៅតែរស់នៅក្នុងភូមិហ្នឹង?

**ឆ៖** ខ្ញុំនៅហ្នឹងតាំងពីអើយ នៅស្រុកភូមិពោធិ៍ចិន្តាំតាំងពី ខ្ញុំកើតឡើងឃើញនៅតែកន្លែងខ្ញុំដដែលស្រុកកំណត់ម៉ែខ្ញុំនៅហ្នឹងស្រាប់ អីនៅហ្នឹងស្រាប់ មានចេញទៅណាទេ នៅហ្នឹងនៅរហូតទាល់តែមិញហ្នឹងទៅ។

[១១:២២:០០]

**សៈ** ចុះក្រោយរបបខ្មែរក្រហមបានដួលរលំឆ្នាំ១៩៧៩ហ្នឹង ក្រោយមកទៀតហ្នឹង មានគ្រួសារវៀតណាមត្រឡប់ចូលមករស់នៅក្នុងភូមិលោកស្រីវិញទេ?

**ឆ៖** គ្មានឃើញទេ បាត់សូន្យរហូត គ្មានពីណាមកមួយទេ បាត់ទាំងអស់ ទាំងទៅទាំងប៉ុន្មាន។

**សៈ** អ្នកដែលលោកស្រីថាបាត់ទៅហ្នឹងបាត់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់លោកស្រីថា ក្រោយខ្មែរក្រហមហើយនេះ ក្រោយ៧៩ នេះ តើមានគ្រួសារខ្មែរក្រហមគាត់ត្រឡប់មក -- អ៎! គ្រួសារវៀតណាម ឬក៏បងប្អូនជនជាតិវៀតណាមនោះ ធ្លាប់ត្រឡប់មករស់នៅក្នុងភូមិលោកស្រីវិញទេ? មានៗ មានវៀតណាមទេ មានជនជាតិវៀតណាមនៅក្នុងភូមិលោកស្រីទេ?

**ឆ៖** អត់មានទេ។ មានពីណានៅទេ តាំងពីហ្នឹងមកគ្មានទេ។

**សៈ** លោកស្រីមុននេះ នៅពេលដែលសហការីអន្តរជាតិរបស់ខ្ញុំបានសួរថា -- កាលហ្នឹងគេនាំយកប្តីលោកស្រីទៅហ្នឹង គេប្រាប់ថាយកទៅកាប់រពាក់ ហើយលោកស្រីថាកាលហ្នឹងគេនិយាយអ៊ីចឹងមែន ហើយលោកស្រីបានបន្តឆ្លើយប្រាប់តុលាការមុននេះថា៖ "ខ្ញុំនឹកក្នុងចិត្តថាបើគេនាំទៅកាប់រពាក់ហ្នឹង មិនមកវិញទេ"។ ហេតុអ្វីបានជាលោកស្រីនឹកក្នុងចិត្តថា បើគេយកប្តីទៅកាប់រពាក់ហ្នឹង ប្តីរបស់លោកស្រីអត់ត្រឡប់មកវិញ?

**ឆ៖** ខ្ញុំតែងនិយាយទៅ ខ្ញុំថាតែទៅហើយបាត់ហើយមិនមកវិញទេ។ ខ្ញុំនឹកក្នុងចិត្តខ្ញុំថា តែទៅប៉ុណ្ណឹងហើយមិនមកវិញទេ ហើយមិនឃើញអ្នកណាមកមួយមែន បាត់ទាំងអស់គ្នា ទៅទាំងប៉ុន្មាន បាត់ទាំងប៉ុណ្ណឹង។

**ស៖** លោកស្រីដឹងទេថា មុនខ្មែរក្រហមចូលមកដល់ហ្នឹង គ្រួសារលោកស្រីហ្នឹងគាត់មានមុខរបរអ្វីដែរ?

**ឆ៖** មុខរបរគាត់ រែកអាចម៍ក្របី អាចម៍គោ យកចាក់ស្រែ។ គេឲ្យធ្វើអីចឹង គេចាត់តាំងឲ្យគាត់ធ្វើអីចឹង។

**ស៖** ខ្ញុំចង់សួរបញ្ជាក់មុន មុនខ្មែរក្រហមចូលដល់ភូមិលោកស្រី តើគាត់ធ្វើការងារអីដែរ មុនៗខ្មែរក្រហមចូលមកដល់?

**ឆ៖** គាត់លក់ដូរបន្តិចបន្តួច ទិញទា ទិញមាន់អីចឹងទៅ យកទៅបោះឲ្យគេទៅ។ គេមកយកដល់ៗផ្ទះទៅ។ តែល្ងាចឡើងគាត់ដើរទិញហើយ។ គេមកយកដល់ៗផ្ទះហ្នឹងទៅ ក៏មិនបាច់ដើរលក់ឯណាទៀតទេ។

[១១:២៥:៥៧]

**ស៖** ចុះកាលគាត់នៅវៀតណាម គាត់មានដែលប្រាប់លោកស្រីទេថាគាត់មានមុខរបរអ្វីដែរទេ?

**ឆ៖** គាត់អត់ដែលនិយាយប្រាប់ខ្ញុំផង។ គាត់មិនដែលឮនិយាយទេ។

**ស៖** តាំងពីមុនខ្មែរក្រហមចូលដល់ភូមិ លោកស្រីថាគាត់មានមុខរបរលក់ដូរមាន់ទា។ ចុះគាត់នៅបន្តមុខរបរអីចឹងរហូតទៅដល់ខ្មែរក្រហមចូលមក ឬក៏ធ្លាប់ធ្វើជាមន្ត្រីរាជការ ឬក៏ធ្លាប់ធ្វើជាទាហានអីដែរ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មិនជាការជំទាស់ទេ គ្រាន់តែជាការកត់សម្គាល់។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្ម ដោយតាមការចងចាំរបស់គាត់ថា សូមដកស្រង់៖ "ខ្មែរក្រហមបានមកដល់នៅក្នុងឆ្នាំ១៩៧៧" វានៅតែជាសក្ខីកម្មរបស់គាត់ដដែល។ ដូច្នេះ សហព្រះរាជអាជ្ញារងគួរតែសួរឲ្យបានច្បាស់លាស់ ប្រុងប្រយ័ត្ន នៅពេលសួរពាក់ព័ន្ធនូវពេលវេលានេះ ព្រោះគាត់បានឆ្លើយថាឆ្នាំ១៩៧៧រួចទៅហើយ។

[១១:២៧:៣០]

**សួរដោយកញ្ញា សុង ឆវ័ន្តៈ**

**ស៖** ដើម្បីឲ្យសវនាការ ហើយនិងមានកំណត់ហេតុក្នុងប្រតិចារឹក ខ្ញុំនឹងរៀបចំសួរអង្គហេតុនេះបញ្ជាក់ឡើងវិញ។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី មុននេះ លោកស្រីបានឆ្លើយជាមួយនឹងសហការីរបស់ខ្ញុំនៅក្នុងសវនាការនេះថា ប្ដីរបស់លោកស្រីត្រូវគេនាំយកទៅក្នុងរដូវវស្សាក្នុងឆ្នាំ៧៧។ តើអ៊ីចឹងមែនទេ?

**លោកស្រី ដួង អឿនៈ**

**ឆ៖** មែន។ ខ្ញុំគ្មានភូតកុហកអីទេ មែន គេយកទៅមែន កាលនុ៎ង។

**ស៖** អ៊ីចឹង ខ្មែរក្រហមចូលមកដល់ក្នុងភូមិលោកស្រីហ្នឹង យូរទេ ទម្រាំតែខាងខ្មែរក្រហមយកប្ដីលោកស្រីទៅ?

**ឆ៖** ប្រហែលមួយខែ បានគេយកប្ដីខ្ញុំទៅ។ នៅមិនយូរទេ តែប៉ុណ្ណឹង។

**ស៖** លោកស្រីរស់នៅក្នុងភូមិជាមួយនឹងជីដូនមួយរបស់លោកស្រីឈ្មោះ ឡាច គ្រី ហ្នឹង មែនទេ?

**ឆ៖** ចាស វានៅជាមួយនុ៎ង ភូមិនុ៎ង ស្រុកនុ៎ង ទាំងអស់គ្នា។

**ស៖** ហើយនៅក្នុងរបបខ្មែរក្រហមហ្នឹង លោកស្រីរស់នៅក្នុងភូមិជាមួយគាត់រហូតដែរ ឬក៏មានផ្លាស់ទៅណា?

**ឆ៖** គ្មានផ្លាស់ទេ នៅនុ៎ង តាំងពីខ្ញុំកើតម្ល៉េះ។ ស្រុកនុ៎ង កំណើតនុ៎ងនៅក្នុងនុ៎ងហ្នង គ្មានទៅណា ផ្លាស់ទៅណាទៅណីទៀតទេ។ សព្វថ្ងៃក៏នៅតាំងនុ៎ងដែរ។ គ្មានផ្លាស់ប្ដូរទៅណាទៀតទេ។

[១១:២៩:៤៤]

**ស៖** ខ្ញុំដឹងថាវាច្រើនឆ្នាំមកហើយ ប៉ុន្តែតាមចម្លើយលោក ឡាច គ្រី ដែលជាជីដូនមួយរបស់លោកស្រីនោះ គាត់បានមកផ្ដល់សក្ខីកម្មនៅមុនលោកស្រីប៉ុន្មានថ្ងៃនេះ។ គាត់បានឆ្លើយនៅក្នុងបន្ទប់សវនាការនេះថា ខ្មែរក្រហមចូលដល់ក្នុងភូមិគាត់នុ៎ង ឆ្នាំ -- ដើមឆ្នាំចិតសិបជាង, ៧១, ៧២។ អ៊ីចឹងពេលវេលាដែលលោកស្រីថា ខ្មែរក្រហមចូលមកដល់៧៧ហ្នឹង វាខុសគ្នាច្រើនឆ្នាំ។ អ៊ីចឹងលោកស្រីជួយរំឭកដល់អង្គហេតុហ្នឹងឡើងវិញមើល៍ ថាតើខ្មែរក្រហមចូលមកហ្នឹងនៅឆ្នាំ៧១, ៧២ ដូចដែលលោកលោក ឡាច គ្រី គាត់និយាយហ្នឹង ឬក៏ឆ្នាំដែលលោកស្រីបាននិយាយ?

**ឆ៖** ខ្ញុំដឹង តែដឹងឆ្នាំ៧៧ ខ្ញុំដឹងខ្លួនខ្ញុំអ៊ីចឹងតែម្ដង។

**ស៖** នៅមុនពេលដែលគេនាំយកប្ដីលោកស្រីប្រាប់ថាទៅកាប់រពាក់ហ្នឹង មានដែលគេហៅលោកស្រីទៅប្រជុំ ឬក៏ប្រជាពលរដ្ឋផ្សេងទៀត មានដែលប្រាប់លោកស្រីថា គេមានដែលប្រជុំនិយាយរឿងជនជាតិវៀតណាមទេ?

**ឆ៖** ទោះប្រជុំ ក៏មិនមែនប្រជុំជាមួយគ្នាដែរ សុទ្ធតែខុសគ្នាទាំងអស់។ មិនមែនប្ដី -- ប្រពន្ធជាមួយប្ដី ប្ដីជាមួយប្រពន្ធទេ សុទ្ធតែបែកគ្នាដោយខ្លួន ខ្ញុំអត់ដឹងទេ។

**ស៖** សំណួរខ្ញុំអ៊ីចេះទេ លោកស្រី។ ចង់ជម្រាបសួរលោកស្រីថា នៅក្នុងរបបខ្មែរក្រហមទាំងមូលហ្នឹង លោកស្រីចូលរួមប្រជុំជាមួយនឹងកម្មាភិបាលខ្មែរក្រហមហ្នឹង គេមានដែលនិយាយរឿងជនជាតិវៀតណាមហ្នឹង ត្រូវធ្វើយ៉ាងម៉េច ឬក៏និយាយពាក់ព័ន្ធរឿងគ្រួសារវៀតណាម ឬក៏ជនជាតិវៀត-ណាមដែរឬទេ នៅក្នុងអង្គប្រជុំដែលលោកស្រីបានចូលរួម?

**ឆ៖** វាមិនដែលនិយាយផង អត់និយាយទេ មិនដែលឮវាថាផង អីផង មិនដែលឮទេ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាសអរគុណ លោកប្រធាន។ ខ្ញុំអស់សំណួរ។ សូមអរគុណ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

បាទ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង១១:៣៣នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣២:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីដែលដំបូងនេះផ្តល់ទៅ វេទិកាទៅសហមេធាវីការពារក្តីជនជាប់ចោទ នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួន ដែលត្រូវសួរលោកស្រីនៅរសៀលនេះ មិនជាច្រើនប៉ុន្មាន សំណួរប៉ុន្មានទេ។ ខ្ញុំសូមចាប់ផ្តើមសួរលោកស្រីនូវសំណួរទាក់ទងទៅនឹងការងារ ឬក៏មុខងាររបស់ប្តីរបស់លោកស្រីដែលបានស្លាប់ទៅ។ ព្រឹកមិញនេះ ខ្ញុំបានសរសេរកត់ត្រាទុក លោកស្រីបានឆ្លើយថា (សរសេរ) "លក់អង្ករ មាន់ ទា ជាដើម។ល។" គឺថាមានស្តុករបស់លក់ដូចជាអង្ករ មាន់ ទា។ តើលោកស្រីបានឆ្លើយថាអ៊ីចឹងទេ ព្រឹកមិញហ្នឹង?

**លោកស្រី ដួង អឿន៖**

**ឆ៖** ប្តីខ្ញុំលក់ទា លក់មាន់ គាត់គ្មានធ្វើការអីទេ គាត់គ្រាន់តែលក់ប៉ុណ្ណឹងទេ ហើយគេមកយកដល់ៗផ្ទះ។

**ស៖** ដូច្នេះគាត់គឺជាពាណិជ្ជករ តើគាត់មានជួញរបស់របរផ្សេងទៀតក្រៅពីមាន់ទានេះដែរទេ?

**ឆ៖** គាត់អត់លក់អីទេ គាត់មានតែប៉ុណ្ណឹង មុខងារគាត់តែប៉ុណ្ណឹង គាត់គ្មានលក់អីទៀតទេ។

**ស៖** ចុះថ្នាំពេទ្យវិញ តើគាត់មានលក់ថ្នាំពេទ្យឲ្យប្រជាជនដែរឬទេ?

**ឆ៖** គាត់អត់មានទេ។

**ស៖** ព្រឹកមិញនេះ លោកស្រីបានឆ្លើយថា"អត់ទេ" ទៅនឹងសំណួរមួយ។ អ៊ីចឹងថាតើគាត់មានលក់អាភៀនដែរទេ?

**ឆ៖** មិនដែលលក់ទេ គាត់អត់លក់ទេ។ គាត់មិនដែលលក់អីទាំងអស់ លក់តែមាន់ទា តែមួយ

មុខៗហ្នឹងទេ។

**ស៖** លោកស្រីប្រាកដថាគាត់អត់មានលក់អាភៀនទេអី?

**ឆ៖** ចាស អត់មានលក់អីទេ។

**ស៖** បាទ ឥឡូវខ្ញុំសូមសួរតទល់ ឬក៏យកចម្លើយដែលលោកស្រីបានឆ្លើយដោយផ្ទាល់ជាមួយនឹងអ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/77562, ខ្មែរ 00034081, អ្នកសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសួរលោកថា៖ “តើប្ដីរបស់លោកស្រីពេលនោះធ្វើអ្វី? លោកស្រីឆ្លើយថា៖ គាត់អត់មានទៅធ្វើមុខជំនួញអីទេ កាលពេលនោះ គាត់ដឹងថាយួនអាចចេញចូលកម្ពុជា គាត់គឺជាអ្នកលក់អាភៀន។” តើលោកស្រីនៅចាំថា លោកស្រីបានឆ្លើយថាដូច្នេះប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

[១៣:៣៧:៣៥]

**ឆ៖** ខ្ញុំមិនដែលបានប្រាប់ផង ខ្ញុំព្រោះខ្ញុំមិនដឹង មានគាត់លក់អីទេ ខ្ញុំអត់ដឹងទេ ខ្ញុំមិនដឹងគាត់មានគាត់លក់អីទេ។ មិនដឹងគាត់លក់ប៉ុណ្ណឹង ប៉ុន្មានមុខហ្នឹង ត្រង់លក់អាភៀន លក់អីខ្ញុំអត់ដឹងទេ។ បានអាភៀនមកពីណាជំនាន់ហ្នឹងនោះ?

**ស៖** ខ្ញុំមិនប្រាកដពីបញ្ហានេះទេ ក៏ប៉ុន្តែ តើលោកស្រីដឹងថាមូលហេតុអីបានជាអ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាសរសេរកត់ត្រាទុកហ្នឹងថា លោកស្រីបានប្រាប់គាត់ថាប្ដីរបស់លោកស្រីហ្នឹងគឺរកស៊ីលក់អាភៀន?

**ឆ៖** ខ្ញុំមិនដែលនិយាយទេ ខ្ញុំមិនដឹងផង ខ្ញុំមិនដែលនិយាយទេ ព្រោះប្ដីខ្ញុំអត់លក់ផង។

**ស៖** មិនថ្វីទេលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ រឿងដែលខ្ញុំសួរសំណួរថាតើគាត់មានបានលក់ទិញលក់ថ្នាំពេទ្យអីដែរទេ លោកស្រីឆ្លើយថាអត់ទេ។ ឥឡូវខ្ញុំសួរតទល់ជាមួយលោកស្រីដែលប្អូនស្រីរបស់លោកស្រីនេះបានប្រាប់អ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាម្នាក់គឺឯកសារE3/6941 ERN អង់គ្លេស 01165890, ខ្មែរ 00418325។ បាទ ខ្ញុំមិនអានសំណួរទាំងស្រុងនោះទេ អានខ្លះ។ “តើគាត់មានរកស៊ីមុខរបរអ្វីក្រៅដែរទេ? គាត់មាន គាត់ជួញថ្នាំពេទ្យចូលមកក្នុងប្រទេសយើង ហើយលក់នៅក្នុងប្រទេសយើង”។ តើលោកស្រីយល់យ៉ាងម៉េចដែរ ដែលប្អូនស្រីរបស់លោកស្រីនេះបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ?

**ឆ៖** មិនដឹងប្អូនខ្ញុំមួយណាផង ខ្ញុំមិនដឹងផង។ ចំណែកខ្ញុំ អត់មានទេ អត់មានលក់អីទេ។ ដឹងតែ

គាត់លក់ប៉ុណ្ណឹង ពីរមុខហ្នឹងទេ មាន់ទាហ្នឹងទេ។ ត្រង់ស្អីទៀត ខ្ញុំអត់ដឹងទេ ខ្ញុំអត់ឮទេ។

**ស៖** ឈ្មោះ ឌិន អៃ គឺជាប្អូនស្រីរបស់លោកស្រីដែលបានឆ្លើយនូវសំណួរនេះជូនទៅមជ្ឈ-មណ្ឌលឯកសារកម្ពុជាថា ប្ដីរបស់លោកស្រីហ្នឹងគឺរកស៊ីរត់ពន្ធថ្នាំពេទ្យ។ ឥឡូវខ្ញុំនឹងសួរពាក់ព័ន្ធទៅនឹងអ្វីដែលប្ដីរបស់លោកស្រីដែលស្លាប់ទៅហ្នឹង ធ្វើអ្វីនៅពេលមុនពេលគាត់ចូលមករស់នៅក្នុងភូមិនោះ? តើប្ដីលោកស្រីមានមុខងារអ្វី ឬធ្វើកិច្ចការអ្វីខ្លះដែរ មុនគាត់ចូលមកក្នុងប្រទេសកម្ពុជាហ្នឹង មុនរបបខ្មែរក្រហមហ្នឹង?

**ឆ៖** គាត់រកស៊ីអី គាត់រកស៊ីតែលក់មាន់ លក់ទាហ្នឹងតែប៉ុណ្ណឹង គាត់គ្មានរកស៊ីផងហ្នឹង។ ហើយទទួលអ៊ីចឹងទៅ ជំនាន់អាពតហ្នឹង គាត់ធ្វើតែការងារខាងអាពតហ្នឹងទៅ។ គាត់មិនដែលទៅរកស៊ីអីផង។ ទទួលស្រុកអ៊ីចឹងទៅ នៅអ៊ីចឹងបណ្ដោលទៅ។ មានទៅរកស៊ីអីណាអីណីទេ។

[១៣:៤១:៥៨]

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់ក៏ថាបាន។ ខ្ញុំសួរសកម្មភាពគាត់ មុនពេលគាត់ក្លាយទៅជាឈ្មួញនេះ ជាអ្នករត់ពន្ធនេះ។ ឥឡូវខ្ញុំសួរដោយផ្ទាល់ទៅចុះ។ តើមានពេលណាមួយ ប្ដីលោកស្រីធ្វើជាសមាជិកនៃកងទ័ពវៀតណាមដែរទេ?

**ឆ៖** បែកមកគាត់ធ្វើ។ គាត់មកនៅស្រុកខ្មែរមក។ តែត្រង់គាត់មកពីណាៗ ខ្ញុំអត់ដឹងទេ ប៉ុន្ដែដឹងថាគាត់មក។

**ស៖** ដូច្នេះ ជាការពិត គឺថាគាត់ធ្លាប់ធ្វើជាកងទ័ពវៀតណាម។ ត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** តើលោកស្រីដឹងថា គាត់នេះជាកងទ័ពវៀតណាមប្រយុទ្ធជាមួយខាងណាដែរទេ? តើគាត់ជាកងទ័ពវៃជាមួយនឹងកងទ័ពវៀតណាមខាងត្បូង ជាសមាជិកកងទ័ពវៀតណាមខាងត្បូង ឬក៏គាត់គឺជាកងទ័ពវៀតណាមខាងជើង ធីវគីនេះ វៀតកុងៗហ្នឹង? តើវៀតកុង គាត់ជាកងទ័ពវៀតកុងឬអត់ទេ?

**ឆ៖** ត្រង់វៀតកុងៗ ខ្ញុំអត់ដឹងទេ ដឹងតែគាត់មកនៅស្រុកខ្ញុំហ្នង។ ខ្ញុំមិនទាន់គាត់ធ្វើអីៗ ខ្ញុំមិនដឹងទេ។ ខ្ញុំដឹងតែប៉ុណ្ណឹង។ ខាងណាៗ ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំយល់ហើយលោកស្រី។ ឥឡូវខ្ញុំគិតថា សួរសំណួរតាមរបៀបផ្សេងវិញម្ដង។ តើប្ដីលោកស្រី ជាកងទ័ពកុម្មុយនីស្ដ? តើគាត់ជាជនកុម្មុយនីស្ដ ហើយចូលរួមវាយប្រយុទ្ធជានឹងខាងទ័ពលន់ នល់ ឬក៏យ៉ាងម៉េចឧទាហរណ៍?

**ផ៖** ខ្ញុំមិនដឹងដែរហ្នឹង កុម្មុយនីស្ត ដឹងមិនកុម្មុយនីស្ត ខ្ញុំអត់ដឹងគាត់ទេ ព្រោះខ្ញុំនៅឯណេះ គាត់នៅឯណាឯនុ៎ង។ ប៉ុនគាត់ដល់អ៊ីចឹងទៅ គាត់រត់មកនៅខ្ញុំ ស្រុកខ្ញុំហ្នឹងមក។ ត្រង់គាត់ធ្វើអីៗ ខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវខ្ញុំព្យាយាមសួរតាមរបៀបផ្សេងម្ដងទៀត តើត្រឹមត្រូវដែរដែលថា គាត់មានសមា -- មានបងប្អូនរស់នៅសៃហ្គន?

**ផ៖** គាត់នៅមែន ប៉ុនមិនដឹងនៅឆ្នាំណាខែណាខ្ញុំមិនដឹងទេ។ ដឹងថាបងប្អូនគាត់នៅ។

**ស៖** តើប្ដីរបស់លោកស្រីកើតនៅសៃហ្គនឬ?

**ផ៖** កើតយើងនៅពាមទេ។ ស្រុកកំណើតគាត់នៅពាម ម៉ែឳគាត់នៅពាមទាំងអស់។

**ស៖** នៅពេលដែលកងទ័ពបក្សកុម្មុយនីស្តវៀតណាមខាងជើងវាយដណ្ដើមយកទីក្រុងសៃហ្គននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ លោកស្រីនៅចាំទេ ពេលហ្នឹង ពេលវ៉ៃយកខាងត្បូងបាន តើប្ដីលោកស្រីពេលហ្នឹងគាត់ៗកើតទុក្ខ ឬក៏គាត់សប្បាយ?

[១៣:៤៦:៤៩]

**ផ៖** គាត់មានអីគាត់ទេ។ ប៉ុនទ័ពហ្នឹង ខ្ញុំមិនដឹងទ័ពខាងណាអីខាង ខ្ញុំអត់ដឹងទេ។ អត់ចាំ បានចាំផង។

**ស៖** ខ្ញុំយល់ហើយលោកស្រី មិនបញ្ហាអ្វីទេ។ ខ្ញុំសូមចូលទៅប្រធានបទថ្មីមួយទៀត។ ព្រឹកមិញនេះ ខ្ញុំបានកត់ត្រានូវចម្លើយដែលលោកស្រីឆ្លើយទៅសហព្រះរាជអាជ្ញារងអន្តរជាតិ គាត់បានសួរថាតើមានអ្វីកើតឡើងចំពោះកូនៗរបស់ប្ដីរបស់លោកស្រី? លោកស្រីឆ្លើយថា ពួកគេគឺជាជនជាតិវៀតណាមដែលរស់នៅក្នុងផ្ទះ។ លោកស្រីថាមានជនជាតិវៀតណាមរស់នៅក្នុងផ្ទះរបស់គាត់។ តើពេលដែលលោកស្រីនិយាយអ៊ីចឹងហ្នឹង (សូមកែតម្រូវ គឺបងប្អូនរបស់នៅក្នុងផ្ទះហ្នឹងជាជនជាតិវៀតណាម)។ តើអ្នកណាហ្នឹង បងប្អូនហ្នឹង?

**ផ៖** មិននៅផ្ទះខ្ញុំទេ នៅផ្ទះគេផ្សេងទេ មិនមកនៅជាមួយខ្ញុំទេ។ គេអ្នកផ្សេងៗទេ នៅនុ៎ងមែននៅស្រុកនៅភូមិទាំងអស់គ្នានុ៎ង ហើយគេយកទៅដូចតែគ្នាហ្នឹងទៅ គ្មានពីណានៅជាមួយខ្ញុំទេ។

**ស៖** នេះខ្ញុំយល់ពីចម្លើយរបស់លោកស្រី។ លោកស្រីនិយាយអំពីប្រជាជនវៀតណាមរស់នៅក្នុងផ្ទះរបស់ប្ដីលោកស្រី។ ហ្នឹងអ្វីដែលលោកស្រីឆ្លើយព្រឹកមិញ។ តើមានជនជាតិវៀតណាមករស់នៅក្នុងផ្ទះប្ដីរបស់លោកស្រីដែរទេ នៅពេលនោះ?

**ឆ៖** មានក្មួយខ្ញុំ ក្មួយខាងប្ដី។ វានាំបងប្អូនវាមកនៅផ្ទះខ្ញុំមែន ប៉ុនដល់ស្រុកអ៊ីចឹងទៅ វានាំបងប្អូនវាទៅវិញអស់ទៅ។ នុំងកូនក្មួយខាងគាត់នុំង។ មិនដឹងជាទៅណាមកណើដែរទេ ខ្ញុំអត់ដឹងដែរ។

[១៣:៤៩:៣៧]

**ស៖** ខ្ញុំនៅតែយល់មិនទាន់ច្បាស់។ តើពួកគេជាសមាជិកគ្រួសាររបស់ប្ដីលោកស្រីឬ គឺថាមិនមែនគ្រាន់តែជនជាតិវៀតណាមមករស់នៅហ្នឹងទេ។ គឺថាតើពួកគេគឺជាបងប្អូនរបស់ប្ដីលោកស្រីឬ?

**ឆ៖** មែន ពិតមែន កូនចៅមកនៅជាមួយខ្ញុំហ្នឹង ក្មួយប្ដីខ្ញុំហ្នឹង។ ដល់ស្រុកវាអ៊ីចឹងទៅ វានាំបងប្អូនវាទៅវិញអស់ទៅ។ ដឹងទៅណាមកណើ ខ្ញុំអត់ដឹងដែរ។

**ស៖** តើនៅពេលដែលពួកគេត្រឡប់មករស់នៅក្នុងផ្ទះហ្នឹង គឺនៅក្នុងឆ្នាំ១៩៧៥ឬ? ព្រឹកមិញលោកស្រីឆ្លើយថា ជនជាតិវៀតណាមត្រូវត្រឡប់ទៅរស់នៅវៀតណាម។ តើពួកគេនេះ បានត្រឡប់មកពីវៀតណាមវិញ មកក្នុងឆ្នាំ១៩៧៥ឬ?

**ឆ៖** ដឹងចិតប៉ុន្មានទេ ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹង គ្រាន់ថាគេមកវិញ គេទៅយៀកណាម គេត្រឡប់មកវិញ។ ត្រង់ឆ្នាំប៉ុន្មាន ខែប៉ុន្មាន ខ្ញុំអត់ដឹងទេ។ ដឹងគេត្រឡប់មកស្រុកវិញ។

**ស៖** និយាយម្យ៉ាងទៀត គឺថាប្ដីរបស់លោកស្រី គឺជាជនជាតិវៀតណាម តែម្នាក់គត់ដែលមកពីក្រុមគ្រួសាររបស់គាត់មករស់នៅក្នុងភូមិពោធិ៍ចិន្ដាំ នឹងដំបូងឡើយ។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស មែន។ គាត់មកនៅភូមិពោធិ៍ចិន្ដាំយូរហើយ។

**ស៖** ព្រឹកមិញ ខ្ញុំស្ដាប់ឮលោកស្រីឆ្លើយជូនសហព្រះរាជអាជ្ញាថា លោកស្រីបានអង្វរឲ្យប្ដីរបស់លោកស្រីត្រឡប់ទៅវៀតណាមវិញទៅ។ តើនៅពេលដែលលោកស្រីបាននិយាយទៅកាន់គាត់អង្វរឲ្យគាត់ទៅវៀតណាមវិញទៅហ្នឹង តើគាត់ឆ្លើយថាម៉េច? ហេតុម៉េចបានជាគាត់បដិសេធ?

**ឆ៖** គាត់ថា គាត់មិនទៅទេ គាត់ដាច់ខាតគាត់មិនទៅទេ។ រស់នៅ ងាប់ស្រុកខ្មែរទៅ ជុំកូនជុំចៅ គាត់មិនទៅទេ ម្នាក់ឯងនុំងនោះ គាត់ថាអ៊ីចេះ។ ហើយខ្ញុំថាឲ្យទៅ ទៅ។ គេទៅលាន់ហើយ ក៏មិនទៅ? ថាខ្ញុំមិនទៅទេ។ ទៅចោលប្រពន្ធ ចោលកូន គាត់មិនទៅទេ សុខចិត្តនៅងាប់ស្រុកខ្មែរចុះ។

[១៣:៥៣:០០]

**ស៖** សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសូមចូលទៅប្រធានបទមួយថ្មីទៀត។ លោកស្រីក៏បានឆ្លើយខ្លះៗហើយ ពាក់ព័ន្ធនឹងប្រធានបទនេះ។ គឺខ្ញុំសំដៅទៅលើអំឡុងពេលមុន១៧ មេសា ៧៥ ឬខាងដើមនោះទៅទៀត។ គឺអំឡុងហ្នឹង ពេលខ្លះ គេហៅថាជាអំឡុងពេលលន់ នល់ អំឡុង

ពេលរបបលន់ នល់ ពីឆ្នាំ១៩៧០ ទៅ៧៥។ តើលោកស្រីនៅចាំអ្វីខ្លះដែរ អំពីការប្រព្រឹត្តមកលើជនជាតិវៀតណាមចន្លោះពីឆ្នាំ១៩៧០ ដល់ ១៩៧៥ នៅក្នុងភូមិរបស់លោកស្រីហ្នឹង ចន្លោះពេលហ្នឹង តើគេប្រព្រឹត្តមកលើជនជាតិវៀតណាមដូចម្ដេចដែរ?

**ឆ៖** គេធ្វើបាប គេឲ្យរែកដី រែកជីអីដូចតែគ្នាហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង ត្រង់គេសម្លុតធ្វើម៉េចៗទៀត ខ្ញុំអត់ដឹងទេ ព្រោះអត់នៅជាមួយគ្នាផង ទៅធ្វើការ ទៅៗដោយខ្លួន។ មិននៅជាមួយគ្នាផង។

**ប្រធានអង្គជំនុំ៖**

មិនមែនទេលោកស្រី គេសួររឿងការប្រព្រឹត្តរបស់អ្នកនៅទីនុំងចំពោះជនជាតិវៀតណាមហ្នឹង ពីឆ្នាំ៧០ ទល់ ៧៥។ ទល់ៗមក៧៥។ បានន័យថា មុនរបបកម្ពុជាប្រជាធិបតេយ្យ របបខ្មែរក្រហមណ៎ា។ តើមានការប្រព្រឹត្តយ៉ាងដូចម្ដេចចំពោះជនជាតិវៀតណាមនៅទីកន្លែងដែលលោកស្រីរស់នៅនុំង?

[១៣:៥៤:៥១]

**លោកស្រី ដួង អឿន៖**

**ឆ៖** អត់អីផង អត់មានធ្វើអីទេ។ ខ្ញុំភ្លេចអស់ហើយ មិនដឹងអីណាអីណីទេ យូរហើយ។

**ស៖** តើលោកស្រីមានដឹងថា អ្នកដែលមានដើមកំណើតជាជនជាតិវៀតណាមនៅក្នុងភូមិរបស់លោកស្រីក្នុងសម័យលន់នល់ហ្នឹង មានគេរើសអើងនឹងពួកគាត់ទេ?

**ឆ៖** មានៗគេថាគាត់វៀតណាម ជនជាតិវៀតណាម ហ្នឹងគេថាមែនពួកនុំង ហើយចេះតែនៅៗទៅ ក៏មិនដឹងទៅណាដែរ គេមិនធ្វើអីយើងដែរ ជំនាន់នុំងនោះ នៅទាល់សព្វថ្ងៃហ្នឹងទៅ។

**ស៖** ខ្ញុំយល់មិនទាន់ច្បាស់ទេ ខ្ញុំមិនដឹងថាលោកស្រីយល់អំពីអំឡុងពេលដែលខ្ញុំកំពុងសួរលោកស្រី ឬក៏អត់នោះទេ។ ឥឡូវ ខ្ញុំសូមអានចម្លើយរបស់មនុស្សមកពីភូមិរបស់លោកស្រីដែលបានប្រាប់អ្នកស៊ើបអង្កេត គឺឯកសារ E3/9352 ជាសំណួរទី២នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់។ លោកប្រធាន គឺជាចម្លើយរបស់មនុស្សម្នាក់ឈ្មោះ អៀង អុន។ លោកស្រីស្គាល់ឈ្មោះ អៀង អុន នេះទេ?

**ឆ៖** អៀង អុន ខ្ញុំស្គាល់នៅនុំងសព្វថ្ងៃ នៅនឹងភូមិខ្ញុំរាល់ថ្ងៃហ្នឹង។ ហ្នឹងគាត់នៅ គាត់មានឈ្មោះ អៀង អុន មែន។

[១៣:៥៧:០២]

**ស៖** អៀង អុន ត្រូវបានអ្នកស៊ើបអង្កេតសួរសំណួរ។ ខ្ញុំនឹងអានសំណួរចម្លើយឲ្យលោកស្រីស្ដាប់ "សំណួរ៖ តើអ្នកភូមិមានរើសអើងប្រឆាំងនឹងពួកគេទេ? "ពួកគេ" នេះសំដៅទៅលើជនជាតិ

វៀតណាមពេលនោះ នៅឯនោះ នៅភូមិនុ៎ង?" អុន គាត់ឆ្លើយថា៖ ពីមុនមក គឺថាមិនមានការរើសអើងទេ គោរពគ្នាទៅវិញទៅមក គឺថារៀបការដោយគោរពតាម ត្រូវធ្វើតាមប្រពៃណីទំនៀមទម្លាប់។ ប៉ុន្តែការរើសអើងហ្នឹង ចាប់ផ្ដើមឡើងនៅក្នុងសម័យលន់នល់។" បញ្ចប់ការដកស្រង់។

ដូច្នេះលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី មនុស្សម្នាក់នេះ អុន នេះដែលលោកស្រីស្គាល់នេះ ថាការចាប់ផ្ដើមរើសអើងប្រឆាំងនឹងជនជាតិវៀតណាម គឺចាប់ផ្ដើមឡើងនៅសម័យលន់នល់។ តើលោកស្រីអាចបញ្ជាក់អះអាងពីរឿងនេះបានទេ ឬក៏មិនអាចបញ្ជាក់បានទេ?

**ឆ៖** មិនបានទេ ខ្ញុំមិនសូវចាំ ខ្ញុំមិនសូវច្បាស់ផង។

**ស៖** បាទ មិនជាបញ្ហាអ្វីទេ។ ឥឡូវនេះ ខ្ញុំសូមចូលនិយាយអំពីពេលវេលាដែលលោកស្រីបានឆ្លើយថាម្ដាយរបស់លោកស្រី ឃើញគេយកប្ដីលោកស្រីដែលស្លាប់ទៅនោះ ឃើញគេបណ្ដើរចេញទៅបាត់។ ហើយលោកស្រីក៏បានបញ្ជាក់ផងដែរថា វាជារដូវវស្សានៅចុងឆ្នាំ១៩៧៧។ អ៊ីចឹងពាក់ព័ន្ធទៅនឹងចម្លើយនេះ ខ្ញុំសូមអាន ដែលលោកស្រីបានសរសេរនៅក្នុងទម្រង់បំពេញព័ត៌មានបន្ថែម ឯកសារ D22/2128, ERN អង់គ្លេស 01166071, ខ្មែរ 00584569 នេះ គឺជាចម្លើយដែលលោកស្រីបានឆ្លើយនៅខែមិថុនា ឆ្នាំ២០១០។ លោកស្រីបានឆ្លើយថា "ប្ដីរបស់ខ្ញុំ ជុយ គឺជាជនជាតិវៀតណាម ជាកងទ័ពវៀតណាម ជាកងទ័ពវៀតណាម។ គាត់ត្រូវបានចាប់ខ្លួន ហើយត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលនៅក្នុងឆ្នាំ១៩៧៨។ ឥឡូវនេះ មានភាពច្របូកច្របល់ ថាតើឆ្នាំ១៩៧៧ ឬ១៩៧៨។

អ៊ីចឹងខ្ញុំសូមសួរម្ដងទៀត តើតាមការចងចាំរបស់លោកស្រី គឺឆ្នាំនុ៎ង ឆ្នាំ១៩៧៧ ឬ៧៨?

**ឆ៖** ៧៧ ដឹងតែឆ្នាំ៧៧ ខ្ញុំដឹង។ ៧៨ទេ ព្រោះអង្កាល់ហ្នឹងខ្ញុំទៅច្រូតកាត់ទៅ។

**ស៖** សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកស្រី--

[១៤:០០:៤៨]

**ចៅក្រម ក្លូឌា ហ្វេនស៖**

គាត់បានឆ្លើយថាឆ្នាំ១៩៧៧ ពីរដងតាមខ្ញុំស្ដាប់ឮជាភាសាអង់គ្លេស។ អ៊ីចឹងតាមអ្នកបកប្រែអ្វីដែលខ្ញុំឮនោះគឺឆ្នាំ១៩៧៧ មិនមែនឆ្នាំ១៧៧៧ទេ។

**លោកស្រី ដួង អឿន៖**

**ឆ៖** ខ្ញុំដឹងអាពាក្យ ១៧៧០ហ្នឹងទេ មិនដឹងប៉ុន្មានអីប៉ុន្មានទៀតទេ ខ្ញុំមិនដឹងទេ។ ខ្ញុំដឹងតែប៉ុណ្ណឹងព្រោះខ្ញុំអត់ចាំ ភ្លេចហើយយូរហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំស្តាប់ក៏មិនច្បាស់ដែរមើលទេ ខ្ញុំឮសួរឆ្នាំ១៩៧០ លោកស្រីចង់និយាយថាឆ្នាំ១៩៧៧ហ្នឹង មែនទេលោកស្រី?

**ឆ៖** ចាស អ៊ីចឹងមែន។ មិនមែន៧៨ទេ ៧៧ទេ។

**ស៖** អរគុណលោកស្រីដើមបណ្តឹង។ ឥឡូវនេះ ខ្ញុំបន្តទៅផ្នែកមួយទៀត។ ចំណុចនេះគឺសាក្សីមួយទៀតក៏បានធ្វើសក្ខីកម្ម គាត់ក៏បាននិយាយអំពី គឺចុងឆ្នាំ១៩៧៦ ដើមឆ្នាំ១៩៧៧ គឺ 2-TCW-848 ឈ្មោះ តេង ហ៊ុយ។ គាត់ៗហៅថាគេបណ្តេីរមនុស្ស ឬក៏គេចាប់ ប៉ុន្តែអ្វីដែលគាត់ខក -- គាត់ហៅថាក្រុមហ្នឹងជាក្រុម សោ ភឹម។ តើលោកស្រីធ្លាប់ឮហេតុការណ៍ សោ ភឹម ទេកាលនោះ?

[១៤:០២:៥៧]

**ឆ៖** គ្មានឮអី ខ្ញុំមិនដែលឮទេ ខ្ញុំមិនដែលឮ សោ ភឹម ទេ។ ខ្ញុំអត់ដឹងអត់យល់ផង។

**ស៖** បាទ មិនបញ្ហាទេ លោកស្រី។ ហើយសាក្សីដដែលនេះបាននិយាយថា ការបណ្តេីរមនុស្សចេញទៅ ឬក៏គេបណ្តេីរប្តីលោកស្រីចេញទៅបានកើតឡើង គឺសូមដកស្រង់៖ “មុនក្រុមនិរតីបោសសម្អាតក្រុមបូព៌ា”។ គឺឯកសារE3/5244។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីបានឆ្លើយព្រឹកមិញទៅសហព្រះរាជអាជ្ញានោះថាខ្មែរក្រហមបានចូលមកដល់ឆ្នាំមួយប្រាំរយចិត -- ក្នុងឆ្នាំ១៩៧៧។ តើអាចទៅរួចដែរទេ ដែលលោកស្រីនិយាយអំពីកម្មាភិបាលដែលមកពីតំបន់មួយ -- ពីភូមិភាគមួយហៅថា “ភូមិភាគនិរតី” មិនមែនហៅថាខ្មែរក្រហមទេ?

**ឆ៖** ខ្ញុំអាចដឹង យល់ត្រង់ហ្នឹង ព្រោះគាត់មែនអង្កាល់នុ៎ង ខ្ញុំអត់ចាំអស់ទេ ខ្ញុំភ្លេចដែរ មិនដឹងឯណា ឯណីទេ។ ខ្ញុំយល់ព្រមដឹងឮអង្កាល់នុ៎ង។

**ស៖** តើគាត់មានន័យថាអ្នកណា? តើលោកស្រីសំដៅទៅអ្នកណានៅពេលនិយាយថា គាត់ពាក់ព័ន្ធនឹងហេតុការណ៍ហ្នឹង?

**ឆ៖** ពាក់ព័ន្ធកាលហ្នឹងមិនពីណាផង ខ្ញុំអត់ដឹងទេ ខ្ញុំភ្លេចអស់ហើយ។ ខ្ញុំអត់ចាំបានទេ ខ្ញុំភ្លេច។ តាំងពីនោះមកដល់ឥឡូវ ខ្ញុំមិននឹកឃើញទេ។

[១៤:០៥:១៧]

**ស៖** អរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំនឹងបន្តទៅប្រធានបទមួយផ្សេងទៀត គឺជាប្រធានបទដែលនិយាយដូចខាងក្រោមនេះ។ តើលោកស្រីធ្លាប់ឮ ឬក៏បានឃើញ ឬក៏បានឆ្លងកាត់ ឬជួប

ប្រទះតាមរបៀបណាមួយ ស្នូរកាំភ្លើង ឬក៏ការបាញ់កាំភ្លើងត្បាល់ កាំភ្លើងធំ ឬក៏ការផ្ទោងគ្រាប់ផ្លោង ចេញមកពីទឹកដីវៀតណាមចូលមកប្រទេសកម្ពុជាទេ? តើ ស្នូរម៉្យាងថាធ្លាប់ឮស្នូរគេធ្វើសង្គ្រាមច្បាំងគ្នាទេ?

**ឆ៖** ខ្ញុំដឹងតែជំនាន់អាពតហ្នឹង គេច្បាំងគ្នា វ៉ៃគ្នា។ ខ្ញុំដឹងតែប៉ុណ្ណឹងហ្នឹង។ ហើយខ្ញុំរត់ទៅៗនៅស្រុកគេទៅ។ ដល់វ៉ៃហើយអីហើយ ខ្ញុំចូលមកស្រុកខ្ញុំវិញមក បែកហើយ។ បែកជំនាន់អាពតហ្នឹងហើយ ខ្ញុំមកវិញមក។ ខ្ញុំអត់មានដីខ្លាញ់ ទៅដីអីគេទេ គ្មានទេ។

**ស៖** ខ្ញុំគិតថាលោកស្រីនិយាយទៅដល់ខែ ពីរបីខែ ដែលទ័ពវៀតណាមវាយលុកចូលកម្ពុជា ខែធ្នូ ឆ្នាំ១៩៧៨។ តើលោកស្រីនៅចាំថារថក្រោះវៀតណាម កងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជានៅខែវិច្ឆិកា ឆ្នាំ១៩៧៧ទេ គឺមួយឆ្នាំមុនពីហ្នឹង មុន?

**ឆ៖** ខ្ញុំអត់ដឹងផង ខ្ញុំអត់ចាំទេ។ មិនដឹងឆ្នាំណាខែណា ខ្ញុំអត់យល់ទេ។ ខ្ញុំអត់ចាំផង។ ខ្ញុំភ្លេចអស់ហើយ។

[១៤:០៧:២៧]

**ស៖** ខ្ញុំយល់។ សំណួរចុងក្រោយទាក់ទងនឹងប្រធាននេះ លោកស្រីដើមបណ្តឹង តើលោកស្រី ឬក៏អ្នកភូមិជាមួយគ្នា ធ្លាប់រត់ចេញ ឬក៏រត់គេចពីភូមិអំពីហិង្សានៃសង្គ្រាមដែរឬទេ? ឬក៏រត់ បាទ រត់គេចពីរថក្រោះ ឬក៏កាំភ្លើងត្បាល់ផ្លោងរបស់វៀតណាម ធ្លាប់ដែរឬទេ?

**ឆ៖** ធ្លាប់ ខ្ញុំរត់គេចទៅស្រុកគេ។ ដល់សង្គ្រាមចប់ហើយ ខ្ញុំចូលផ្ទះខ្ញុំវិញ ខ្ញុំមកវិញ។ បែកហើយបានខ្ញុំមកផ្ទះវិញនោះ បែកពីជំនាន់នុ៎ង។ បើមិនរត់ពួនណា បើវាផ្លោងខ្លាំងៗ។

**ស៖** តើការផ្លោងដែលថាធ្ងន់ធ្ងរហ្នឹង នៅចម្ងាយប៉ុនណា នៅជិតប៉ុនណា ពីភូមិរបស់លោកស្រីដែលថាគ្រាប់ផ្លោងហ្នឹងធ្លាក់? តើវាធ្លាក់នៅក្នុងភូមិ ឬក៏ធ្លាក់ជិតៗភូមិ? តើលោកស្រីចាំទេ?

**ឆ៖** ធ្លាក់ទៅឆ្ងាយៗដែរ បានខ្ញុំរត់ទៅឆ្ងាយទៀតទៅ ផ្លោងខ្លាំងៗខ្ញុំទៅទៀតទៅ។ នាំកូននាំចៅរត់ទៅទៀតទៅ។ បើនៅជិតហ្នឹងខ្លាចតែត្រូវ។ បើខ្ញុំរត់ ចេះតែរត់ទៅទៀតទៅ។ ដល់ស្រុកអីចឹងទៅបែកហើយ បានខ្ញុំត្រឡប់មកផ្ទះវិញ។

**ស៖** តើចម្ងាយប៉ុនណាពីភូមិ? ១០០ម៉ែត្រ ឬក៏១គីឡូម៉ែត្រពីហ្នឹង? ឬក៏ធ្លាក់នៅភូមិផ្សេង? តើលោកស្រីនៅចាំទេ តាមគិតមើលទៅ?

**ឆ៖** ខ្ញុំអត់ចាំទេ មិនដឹងឯណាឯណីទេ។ ប៉ុនខ្ញុំរត់ទៅ ជិតៗដែរ មិនសូវឆ្ងាយប៉ុន្មានទេ ឲ្យតែ

ផុតផ្ទះទៅហ្នឹង។ នៅផ្ទះទៅ ខ្លាចផ្ដោងដាក់ត្រូវ។ អ៊ីចឹងហើយ រត់ទៅនៅភូមិគេមួយថ្ងៃពីរថ្ងៃទៅ។ បានបែកហ្នឹង ខ្ញុំត្រឡប់មកវិញ។

[១៤:១០:00]

**ស៖** តើលោកស្រីដឹងដែរឬទេ ថាតើអ្នកភូមិណានៅក្នុងភូមិអ្នកស្រីរងរបួស ឬក៏ត្រូវគ្រាប់នៅពេលដែលគេផ្ដោង ឬក៏គេបាញ់កាំភ្លើងមកដល់ទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ ត្រង់កន្លែងនុំងក៏គ្មានដែរ ត្រង់មានៗខ្ញុំមិនដឹងទេ ប៉ុនខ្ញុំរត់ទៅបាត់ហើយ ខ្ញុំមិននៅមើលទេ។ ខ្ញុំរត់ទៅស្រុកភូមិគេបាត់ហើយ។ បានបែកហើយ បានខ្ញុំមកវិញ។

**ស៖** អរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំគិតថាប្រធានបទចុងក្រោយខ្ញុំហើយពេលនេះ។ សូមលោកស្រីជម្រាបតុលាការម្ដងទៀត ពីរបៀបដែលលោកស្រីបានឮ ឮអ្វីៗអំពីកុមារជនជាតិវៀតណាម កុមារដែលមានម្ដាយជាវៀតណាមនោះ ជាទិសដៅៗ ហើយកុមារជាកូនៗរបស់ស្ត្រីម្ដាយជាខ្មែរហ្នឹងគេមិនចាត់ជាទិសដៅទេ។ អ៊ីចឹងសូមលោកស្រីពន្យល់តុលាការឲ្យច្បាស់ជាងមុនបន្តិចមើល?

**ឆ៖** កូនវៀតណាមហ្នឹង -- កូនខ្មែរហ្នឹង គេអត់យកទេ គេយកតែកូនវៀតណាមទេ ព្រោះកូនគាត់យកទៅអស់ហើយ កូន ឡាច នី នេះ គ្មានទុកមួយទេ យកទៅអស់ហើយ។ ហើយនុំងទៀត គ្មានពីណាមានកូនទេ មានគាត់ហ្នឹងមានកូនច្រើនជាងគេ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់ ប៉ុន្តែនេះជាអ្វីដែលលោកស្រីបានឃើញ ឬក៏បានឮ ប៉ុន្តែអ្វីដែលខ្ញុំព្យាយាមឲ្យយល់តើជាការសន្និដ្ឋានរបស់លោកស្រី ឬក៏ប្រជាជនផ្សេងនិយាយ ឬក៏អ្នកភូមិនិយាយ ឬក៏បានស្ដាប់នៅក្នុងការប្រជុំ ឬក៏តាមវិទ្យុ ឬក៏ឮពីអ្នកណាអំពីរឿងនេះ?

**ឆ៖** ខ្ញុំអត់ឮទេ ប៉ុន្តែគ្រាន់ឮថា គាត់ហ្នឹងទៅបាត់តែម្ដង មិនឃើញមកវិញទេ យកទៅយកបាត់រហូតទៅ។ ខ្ញុំក៏មិនដឹងគេយកគាត់ទៅណាទៅណីដែរ ខ្ញុំអត់ដឹងដែរ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទ ខ្ញុំយល់។ ខ្ញុំសួរម្ដងទៀតជាចុងក្រោយ។ តើមានអ្នកណាម្នាក់ មេភូមិ ឬក៏អ្នកណាម្នាក់មកពីមន្ទីរសន្តិសុខ ជាយោធា ឬក៏អ្នកណាម្នាក់មកពីក្រុមខ្មែរក្រហមដែលនិយាយថា កូនៗរបស់ម្ដាយវៀតណាមនោះ គេមិនទុកទេ ដែលគេនិយាយអ៊ីចឹង។ តើលោកស្រីនឹកឃើញថាអ្នកណាម្នាក់ប្រាប់លោកស្រីអ៊ីចឹងទេ?

**ឆ៖** មាន ខ្ញុំដឹងថា ម្ដាយវៀតណាម កូនក៏គេយកទៅដែរ គេអត់មានទុកនៅកន្លែងទេ យកទៅអស់ហើយ នៅតែឪម្នាក់ឯងទេ សូមតែកូនមួយទុក គេមិនទុកឲ្យផង។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[១៤:១៣:៥៩]

**ស៖** ខ្ញុំយល់ហើយលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ លោកស្រីបាននិយាយពីរបីដងហើយនៅពេលនេះ។ ខ្ញុំព្យាយាមយល់ តើនេះជាអ្វីដែលលោកស្រី ហើយនិងអ្នកភូមិសន្និដ្ឋានយល់ដោយខ្លួនឯងថាកើតអ៊ីចឹង ឬក៏ជាអ្វីដែលលោកស្រីបានឮអ្នកណាម្នាក់និយាយ ដែលថាឮតាមការប្រជុំ ឬក៏ឮតាមការស្តាប់វិទ្យុ។ តើលោកស្រីយល់ពីភាពខុសគ្នានេះដែរឬទេ?

**ឆ៖** ខ្ញុំដឹងថាអ៊ីចឹងមែន ប៉ុនត្រង់អាម៉េចៗទៀត ខ្ញុំអត់ដឹងទេ។ បើដឹងថាគេយកកូនគាត់ទៅអស់រលីងហើយ គ្មាននៅសល់មួយទេ។ ខ្ញុំដឹងតែប៉ុណ្ណឹង។ ត្រង់ម៉េចៗទៀតខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ចាំផង។

**ស៖** អរគុណលោកស្រីដើមបណ្តឹង។ សំណួរចុងក្រោយ ហើយជាសំណួរខ្លីផងដែរ បាទ។ កូនស្រីរបស់លោកស្រី តើគាត់កើតនៅក្នុងឆ្នាំ១៩៧០ឬ? ម្យ៉ាងវិញទៀត រវាងឆ្នាំ១៩៧០ ដល់១៩៧៩ ប្រហែលជាគាត់អាយុប្រហែលជា៩ឆ្នាំ ឬក៏អាយុប៉ុន្មាន?

**ឆ៖** អាយុប្រហែលនៅប្រាំពីរ ប្រាំបីឆ្នាំទេ អាយុកូនខ្ញុំនុ៎ង ឥឡូវ វា៤៥ហើយ។

**ស៖** មូលហេតុដែលខ្ញុំសួរបញ្ហានេះ នេះជាសំណួរចុងក្រោយលោកស្រីដើមបណ្តឹង ដែលថាម្តាយរបស់លោកស្រីជាជីដូនរបស់កូននោះ បានប្រាប់អ្នកស៊ើបអង្កេតគឺថា E3/759 គឺថាកូនស្រីរបស់លោកស្រី -- E3/7598។ អ៊ីចឹង តើត្រូវដែរឬទេ កូនស្រីរបស់លោកស្រីពិតជាមិនបានដឹងអ្វីដែលបានកើតឡើងក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ទេ?

**ឆ៖** ខ្ញុំអត់ចាំផង។ អត់ចាំ វាភ្លេច មិនដឹងឆ្នាំណា ខែណាទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកស្រីចៅក្រម ខ្ញុំអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី -- សូមទោស លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំជា

ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន ខ្ញុំមានសំណួរខ្លីៗទេ ដើម្បីសុំការបំភ្លឺពីលោកស្រីនៅចម្លើយដែលលោកស្រីបានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះ។ ខ្ញុំចង់និយាយអំពីថាតើលោកស្រីត្រូវបានសម្ភាសប៉ុន្មានដងនៅក្នុងភូមិលោកស្រី? លោកស្រីឆ្លើយជូនលោកប្រធានថា៖ “អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានទៅសម្ភាសលោកស្រី”។ ដូច្នេះ ខ្ញុំចង់ដឹងថាលោកស្រីចាំថា មានបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទៅសម្ភាសលោកស្រីទេ?

[១៤:១៧:៥៨]

**លោកស្រី ដួង អឿន៖**

**ឆ៖** មាន អង្កាល់នុ៎ង មាន។ គាត់ទៅសម្ភាសខ្ញុំដល់ផ្ទះ។

**ស៖** លោកស្រីចាំថ្ងៃណា ខែណា ឆ្នាំណាទេ?

**ឆ៖** ខ្ញុំអត់ចាំទេ ខ្ញុំភ្លេចហើយ។ មិនដឹងណាណើទេ យូរហើយ។

**ស៖** ប្រសិនបើខ្ញុំថា ខែកុម្ភៈ ឆ្នាំ២០០០ តើលោកស្រីនឹកឃើញទេ?

**ឆ៖** នឹកមិនឃើញទេ បាត់ចងចាំ ភ្លេចអស់ហើយ។

**ស៖** លោកស្រីចាំទេថា ពេលដែលគេសម្ភាសលោកស្រីហ្នឹង គេមានថតសំឡេងលោកស្រីទេ? គេមានកាសែតម៉ាញេអីថតសំឡេងទេ?

**ឆ៖** កាលនុ៎ង ថត ថតសំឡេង។ មិនដឹងយកមកធ្វើអី ខ្ញុំមិនដឹងដែរ ប៉ុនដឹងថាគាត់ថត។

**ស៖** ខ្ញុំសួរសំណួរ សុំឲ្យលោកស្រីបំភ្លឺនេះ ពីព្រោះថា មុននេះ ពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់មេធាវី កូប៉េ ពាក់ព័ន្ធទៅនឹងអ្វីដែលលោកស្រីបាននិយាយអំពីមុខរបរប្ដីលោកស្រី។

លោកស្រីថា ខ្ញុំមិនដែលនិយាយអ៊ីចឹងទេ ពាក់ព័ន្ធទៅនឹងមុខរបររបស់ប្ដីលោកស្រីថាជាអ្នកលក់អាភៀននោះ។ ដូច្នេះ ខ្ញុំសូមអានន្ធូវសម្រង់នៃប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់លោកស្រីជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7562។ ខ្ញុំសូមអានជាភាសាអង់គ្លេស ពីព្រោះថាអត់មានជាភាសាបារាំងទេ។ ERN ជាភាសាអង់គ្លេសគឺ 01157781, ជាភាសាខ្មែរ គឺ00034081។ គេសួរលោកស្រីនៅពេលនោះដូចទៅ៖ “តើលោកស្រីអាចប្រាប់បាន យើងទេថា ប្ដីរបស់លោកស្រីនៅពេលនោះ ធ្វើអ្វីដែរ? ចម្លើយ៖ គាត់មិនរកស៊ីអ្វីទេកាលនោះ។ កាលហ្នឹង គឺគាត់អាងថា ទ្វារចេញចោល យួនចេញចូលនុ៎ងណ៎ា គាត់លក់អាភៀន។ សំណួរ៖ គាត់លក់អាភៀនមែនឬ? ឆ្លើយ៖ ចាស។ កាលមួយហ្នឹង គាត់ចេញចូលប្រទេសកម្ពុជា គាត់អត់មានអ្វីធ្វើទេ គាត់នៅតែនឹងផ្ទះ ហើយនៅនឹងផ្ទះហ្នឹង គឺៗគាត់មាន

អាភៀន ហើយប្រជាជនគេ -- តើ -- សួរ៖ គេប្រជាជន គេមកទិញអាភៀនហ្នឹងឬ? ឆ្លើយ៖ ចាស គឺពួកគេមកទិញអាភៀន។ គាត់អត់មានធ្វើអ្វីក្រៅពីនុំងទេ។ សួរ៖ តើគាត់លក់ប៉ុន្មានៗដែរ បានច្រើនប៉ុន្មានដែរកាលនុំង? សួរ៖ គឺថាគាត់មានលុយច្រើនណាស់ កាលហ្នឹង។ នៅពេលហ្នឹង យួនហូរចូលមកស្រុកខ្មែរ គេមកទិញអាភៀន។ សួរ៖ តើគាត់មានលុយច្រើនទេ? ឆ្លើយ៖ ចាស ច្រើនដែរ។" បញ្ចប់ការដកស្រង់។

[១៤:២២:១៣]

លោកស្រី ដួង អឿន ខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងសម្រង់នៃចម្លើយដ៏វែងរបស់លោកស្រីឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ធ្វើឱ្យលោកស្រីនឹកឃើញទេ ហើយលោកស្រីនៅតែរក្សាចម្លើយដដែលទេថា ប្តីរបស់លោកស្រីហ្នឹង គ្រាន់តែជាអ្នកលក់មាន់ទាទេ នៅសម័យនោះនោះ?

**ឆ៖** គាត់លក់មែន ខ្ញុំដឹងថាគាត់លក់តែប៉ុណ្ណឹង គ្រាន់គាត់ទៅឯណា ទៅឯណីទៀត ខ្ញុំអត់ដឹងទេ ប៉ុន្តែគ្រាន់តែដឹង គាត់លក់អ៊ីចឹង រកស៊ីលក់មាន់ លក់ទាអ៊ីចឹង។ លក់ក៏គាត់មិនដែលទៅឆ្ងាយដែរ នៅតែផ្ទះ គេមកយកដល់ៗផ្ទះ។ ទិញបានមក ក៏យើងយកដល់ៗផ្ទះៗទៅ។

**ស៖** ដូច្នេះ លោកស្រីអាចពន្យល់បានទេ ហេតុអីជានៅក្នុងសម្រង់នុំង លោកស្រីនិយាយផ្សេងទៅវិញ? យើងមានចម្លើយរបស់លោកស្រី ដែលគេបានចម្លងចេញពីកាសែតស្តាប់សំឡេងលោកស្រី ហើយលោកស្រីក្នុងនុំង លោកស្រីថាលក់អាភៀន ហើយដល់ពេលឥឡូវនេះ លោកស្រីថាលក់មាន់ទា។ លោកស្រីអាចពន្យល់អំពីភាពខុសគ្នានេះបានទេ?

**ឆ៖** ពន្យល់អី បើខ្ញុំដឹងតែប៉ុណ្ណឹងមែន ខ្ញុំអត់ដឹងអីទៀតផង។ គាត់មិនដែលលក់អីផង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៤:២៤:០៥]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ តាមការពិតការ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយរួចមកហើយ ហើយអ្វីដែលខ្ញុំចង់និយាយ គឺថាសំណួរដែលលោកស្រីមេធាវី អង់តា ហ្គីសសេ បានលើកទាំងពីរសំណួរ ហើយទាំងការអានផ្នែកដែលពាក់ព័ន្ធនោះ គឺលោក កូប៉េ បានលើក ហើយនិង -- បានអាន ហើយនិងលើកសំណួរដដែលនេះហើយ អ៊ីចឹងគ្រាន់តែចង់បញ្ជាក់ កត់សម្គាល់បញ្ហាហ្នឹងទេ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមឆ្លើយតបយ៉ាងខ្លី។ មេធាវី កូប៉េ គាត់មិនបានដកស្រង់ចម្លើយទាំងស្រុងដែលខ្ញុំទើបតែដកស្រង់នោះទេ។ ខ្ញុំគិតថា មិនមែនច្រំដែលទេ។ វាគឺជាការសំខាន់ ក្នុងការលើកឡើងនូវចម្លើយពីមុនរបស់គាត់នេះ។ ពីព្រោះថាគាត់ៗអ្នកឆ្លើយផ្ទាល់ នៅពេលនុ៎ង។ អ៊ីចឹងហើយបានខ្ញុំអានឡើងវិញ ដើម្បីរំឭកការចងចាំរបស់គាត់។ ខ្ញុំអត់មានសំណៅទាំងស្រុងនៃប្រតិចារឹកខ្សែអាត់នេះទេ ក៏ប៉ុន្តែភាគីអាចត្រួតពិនិត្យបានជាពិសេសភាគីខ្មែរ ពីព្រោះថាឯកសារខ្មែរគឺមានទាំងស្រុង។ នៅក្នុងឯកសារសម្ភាសន៍នោះលោកស្រីឆ្លើយបែបហ្នឹង ហើយឥឡូវនេះ លោកស្រីថាលោកស្រីមិនដឹងអំពីការរកស៊ីរបស់គាត់ទេ។ នៅក្នុងឯកសារដដែលគឺជាភាសាខ្មែរ 00034084 លោកស្រីបានរៀបរាប់លម្អិតយ៉ាងច្បាស់អំពីរបៀបទិញលក់អាភៀន ហើយនៅភាសាខ្មែរក៏មាននៅ ERN 00034082 ដែរ។ នៅក្នុងទំព័រនោះ លោកស្រីបានបញ្ជាក់ថាគេលក់ហ្នឹង គឺលក់ ដាក់ជាសម្ងាត់ដើម្បីកុំឲ្យរដ្ឋអំណាចដឹង ព្រោះថាបើសិនជាលក់ជាចំហហ្នឹងគឺជាប់គុក។ នេះជាចំណុចចុងក្រោយរបស់ខ្ញុំហើយ។ ខ្ញុំចង់បញ្ជាក់ថាតើលោកស្រីនឹកឃើញឡើងវិញទេ ថាពេលហ្នឹងប្តីរបស់លោកស្រី គឺលួចលាក់លក់អាភៀនជាសម្ងាត់ ព្រោះថាបើសិនជាអាជ្ញាធរដឹងនោះគឺជាប់គុក។ អ៊ីចឹងលោកស្រីមាននឹកឃើញចម្លើយរបស់លោកស្រី ដែលបានឆ្លើយកាលពីមុនហ្នឹងទេ?

**ផ៖** ខ្ញុំអត់នឹកឃើញទេ ខ្ញុំភ្លេចអស់ហើយមិនដឹងឯណាឯណីទេ ខ្ញុំស្តាប់អត់បានទេ យូរហើយតាំងពីហ្នឹងមកដល់នេះហើយ មើលខ្ញុំអាយុ៧៥ហើយ ល្មមខ្ញុំភ្លេចដែរ។ ប៉ុនប្តីខ្ញុំក៏គ្មានអ៊ីចឹងទេ គាត់អត់លក់អ៊ីចឹងទេ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១៤:២៧:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកស្រី ដួង អឿន ជាចុងក្រោយនេះ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុអំពីទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលចោទប្រកាន់ទៅលើជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកស្រីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងជំងឺចិត្ត និងជា

សមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពអន្តរាយដែលមានចំពោះលោកស្រីជាអាទិ៍។ ការខូចខាតរាងកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត និងជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងកើតលើពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

**លោកស្រីដួង អឿន៖**

ខ្ញុំអង្គាល់ហ្នឹងខ្ញុំឈឺចាប់។ គេធ្វើបាបខ្ញុំឲ្យខ្ញុំរែកដី ឲ្យខ្ញុំលីសែង ដកស្ទូង ធ្វើបាបខ្ញុំ ឥឡូវខ្ញុំឈឺពេញខ្លួនទាំងអស់ តាំងពីនុ៎ងមកដល់ហ្នឹង ព្រោះខ្ញុំធ្វើការធ្ងន់ៗពេក។ ទៅដល់ចាស់ទៅជ្រុឌទ្រោមដែរ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ នៅថ្ងៃមុនដែលយើងខ្ញុំបានស្នើសុំលោកប្រធានដើម្បីឲ្យយើងខ្ញុំសួរលោកស្រីតែម្តងចំពោះការបាត់បង់ ការឈឺចាប់របស់គាត់ ហើយនៅនេះគឺយោងទៅឯកសារ E1/371.1 ត្រង់ERN -- បាទ ហើយដែលខ្ញុំបានស្នើសុំលោកប្រធានថាដោយសារថាដើមបណ្តឹងរដ្ឋប្បវេណីមិនចេះនិយាយច្រើន ដូច្នេះស្នើសុំលោកប្រធានដើម្បីសួរជាសំណួរនាំមុខ ដើម្បីឲ្យគាត់ឆ្លើយអំពីការឈឺចាប់របស់គាត់។ ដូច្នេះសូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សំណួរនាំមុខ អង្គជំនុំជម្រះសាលាដំបូងដូចជាមិនអនុញ្ញាតឲ្យភាគីណាប្រើប្រាស់នៅក្នុងកិច្ចពិភាក្សាដេញដោលទេ។ អង្គជំនុំជម្រះឲ្យសម្រួលឲ្យលោកអាចសួរបាន ប៉ុន្តែមិនអនុញ្ញាតឲ្យលោកប្រើសំណួរនាំមុខទេ។

[១៤:៣០:៣០]

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន អធ្យាស្រ័យប្រហែលជាខ្ញុំប្រើពាក្យមិនត្រឹមត្រូវ។ បាទ អ៊ីចឹងខ្ញុំសុំអនុញ្ញាតសួរសំណួរ ដើម្បីឲ្យពាក់ព័ន្ធទៅនឹងការឈឺចាប់ ការបាត់បង់របស់លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ បាទ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក ពេជ អង្គ៖**

**សៈ** បាទ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំចង់សួរថាតើនៅពេលដែលលោកស្រីបាត់បង់ប្តី

របស់លោកស្រីឈ្មោះ ទេព យុន ហៅ ផុយ ហើយនឹងកូនប្រុសរបស់លោកស្រីឈ្មោះ ម៉ុន មុំាង នៅក្នុងរបបខ្មែរក្រហមនោះ ថាតើក្នុងអារម្មណ៍របស់លោកស្រី មានអារម្មណ៍យ៉ាងដូចម្ដេចដែរ? តើលោកស្រីអាននិយាយបានទេ?

**លោកស្រី ដួង អឿន៖**

**ឆ៖** បាន និយាយឈឺចាប់ ធ្វើទុក្ខបុកម្នេញខ្ញុំ បែបសព្វបែបយ៉ាង។ ប្រើខ្ញុំគ្មានដែលទំនេរថ្ងៃណាទេ។ ខ្ញុំនឹកឆ្អែតចិត្តត្រង់ហ្នឹងហ្មង។ ប្រើខ្ញុំហ្នឹង ប្រើៗគ្មានទំនេរទេ។ គ្មានដែលនៅស្រុកនៅភូមិអីគេទេ ដើរតែជីកព្រែក ជីកដី ដកស្ទូង មិនដែលបានទំនេរទេ។ ខ្ញុំឈឺចិត្តឆ្អែតត្រង់ហ្នឹង ព្រោះកូនព្រោះប្ដីខ្ញុំបាត់អស់រលីងហើយ ខ្ញុំឈឺចាប់។ ថ្ងៃអីទៅ នឹកតែឃើញ អីទៅនឹកតែឃើញប្ដីកូនប្រពន្ធ សព្វបែប សព្វយ៉ាង។ ណាមួយទៀតអត់ពីប្ដីទៅ វេទនា នៅម្នាក់ឯង រកស៊ីចិញ្ចឹមកូន។ សូរតែមានទៅ ឯងហ្នឹងក្រទៀត។

[១៤:៣២:៣៧]

**ស៖** អ៊ីចឹងតើក្រោយពីបែកសម័យខ្មែរក្រហមឆ្នាំ១៩៧៩ ថាតើក្រោយឆ្នាំនេះ ក្រោយឆ្នាំហ្នឹងថាតើលោកស្រីរស់នៅ ការរស់នៅ ឬក៏ជីវភាពរបស់លោកស្រីមានស្ថានភាពបែបណាដែរ នៅពេលដែលលោកស្រីអត់មានប្ដី ហើយអត់មានកូនហ្នឹង? លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំពិបាក រកស៊ីមិនបាន អីមិនបាន។ កូន នឹកតែកូន នឹកតែប្ដី។ មានរកអីទីពឹងកើត រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក។

**ស៖** អ៊ីចឹងក្រៅពី លោកស្រីមានអ្វីបន្ថែមទៀតទេ លោកស្រីជាចុងក្រោយនេះ? សូមអញ្ជើញ!

**ឆ៖** ចាបន្ថែម មិនដឹងឲ្យវាជួយខ្ញុំខ្លះផង ព្រោះខ្ញុំក្រីក្រណាស់សព្វថ្ងៃ។ បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក។ ចាស់ហើយទៅរកអី? ទៅលក់ដូរអី មិនកើតគេ ដើរតែខ្លួនមិនរួច។

**ស៖** អ៊ីចឹងខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះអរគុណ លោកស្រី ដួង អឿន។ សវនាការស្ដាប់សក្ខីកម្មរបស់លោកស្រី និងសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មក្នុងឋានៈលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីបានដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកស្រីអាចនឹងរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ឥឡូវនេះ លោកស្រីអាចត្រឡប់ទៅវិញបានហើយ ទៅលំនៅដ្ឋាន ឬក៏

គោលដៅណាដែលលោកស្រីចង់មានបំណងចង់ទៅបានហើយ។ ហើយសូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ទេព ធីតា បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជូនគាំទ្រដល់អង្គជំនុំជម្រះជួយសម្របសម្រួលដំណើរការសវ-នាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ដែលប្រព្រឹត្តក្នុងរយៈពេលមួយថ្ងៃនេះ។ ហើយឥឡូវនេះ លោកស្រីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោកស្រី ដួង អឿន វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយសវនាការនៅវគ្គបន្ទាប់នេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1009 ហើយសាក្សីរូបនេះមានលោក មឿន សុវណ្ណ ជាមេធាវីប្រឹក្សា។

ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការតទៅនេះ អង្គជំនុំជម្រះ ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1009 ដែលមានលោក មឿន សុវណ្ណ ជាមេធាវីប្រឹក្សាសាក្សីរូបនេះ។ ហើយមុននឹងកោះអញ្ជើញសាក្សី និងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E382 ជាមុនសិន។ នៅក្នុងសំណើមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E382 សហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីដែលមានរហស្ស-នាម 2-TCW-1010 និងទទួលកំណត់ហេតុស្តាប់ចម្លើយចំនួនពីររបស់សាក្សី 2-TCW-1010 គឺឯកសារ

E319/23.3.34 និង E319/23.3.36 ពាក់ព័ន្ធនឹងអង្គហេតុនៃការប្រព្រឹត្តលើក្រុមមនុស្សគោលដៅជាក់លាក់ជនជាតិវៀតណាម។

នៅក្នុងការអនុវត្ត -- នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង E380/1 អង្គជំនុំជម្រះបានបដិសេធសំណើសុំឲ្យស្តាប់សក្ខីកម្មសាក្សី 2-TCW-1010 ដោយមិនបានសម្រេចទៅលើការទទួលយកកំណត់ហេតុស្តាប់ចម្លើយនោះទេ។ នៅថ្ងៃនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងមកអង្គជំនុំជម្រះ បានរយៈសារអេឡិចត្រូនិចថា ខ្លួនមានបំណងក្នុងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយរបស់ 2-TCW-1010 នៅក្នុងអំឡុងពេលសួរដេញដោល។ សក្ខីកម្មបន្ទាប់ គឺសាក្សី E-TCW-1009។ ហើយបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីអាចប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានភាគីណាមួយជំទាស់ទៅនឹងណើ E382 ដែលបានស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយនេះធ្វើជាឯកសារភស្តុតាងនោះទេ។

អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង ទទួលយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយសំអាងហេតុពេញលេញលើបញ្ហានេះ និងផ្តល់ជូននាពេលក្រោយ។

បាទ តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី 2-TCW-1009 រួមទាំងមេធាវីប្រឹក្សាសាក្សី ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

បាទ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[១៥:០៨:៤១]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមការបំភ្លឺមួយពាក់ព័ន្ធនឹងអ្វីដែលលោកប្រធានបានលើកឡើង។ យើងបានជំទាស់ជាផ្ទាល់មាត់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា និងក្នុងការសុំកោះហៅសាក្សី និងកំណត់ហេតុរបស់គាត់។ ដូច្នេះខ្ញុំមិនចង់ -- ខ្ញុំមិនដឹងថាតើអង្គជំនុំជម្រះកែប្រែសេចក្តីសម្រេចរបស់ខ្លួនដែរឬក៏យ៉ាងណា ពីព្រោះថាយើងៗប្រឆាំងទៅនឹងការដាក់ឯកសារជាភស្តុតាងហ្នឹង និងការកោះហៅសាក្សីរូបនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ទោះបីជាមានការជំទាស់ដូច្នេះក៏ដោយ អង្គជំនុំជម្រះបានសម្រេចថាទទួលយកនូវឯកសារ

ទាំងពីរ តាមសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីដាក់បង្ហាញ និងមកពិភាក្សាដេញដោលចំពោះសាក្សីរូបនេះ។

[១៥:១០:៣៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** បាទ ខ្ញុំឈ្មោះព្រុំ សារ៉ាត។

**ស៖** អរគុណ លោកព្រុំ សារ៉ាត។ តើលោកកើតនៅថ្ងៃ ខែ ឆ្នាំណា? លោកចាំដែរទេ?

**ឆ៖** កាលខ្ញុំបាទកើតនៅថ្ងៃទី០១ ខែ៣ ឆ្នាំ១៩៥៩។

**ស៖** អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** ភូមិកំណើតរបស់ខ្ញុំកើតនៅព្រៃឈើទាល ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅរបស់ខ្ញុំបាទសព្វថ្ងៃរបស់ក្នុងភូមិអូរត្រែង ឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុករបស់ខ្ញុំបាទឈ្មោះ ព្រុំ ទង។ ម្ដាយឈ្មោះ មិន ញូន (ស្លាប់)។

[១៥:១២:០៥]

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំបាទឈ្មោះ វែង រីម។ មានកូនបួននាក់។

**ស៖** បាទ អរគុណ លោក ព្រុំ សារ៉ាត។ តាមរបាយការណ៍របស់ក្រឡាបញ្ជីអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹងគឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះពិតដែរឬទេ?

**ឆ៖** បាទ របាយការណ៍នេះពិត។

**ស៖** ហើយមុននឹងចូលមកចំពោះអង្គជំនុំជម្រះនាពេលនេះ តើលោកបានធ្វើសម្បថនៅចំពោះ

មុខអ្នកតាដំបងដែកនៅពីខាងកើតសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបាទបានធ្វើសម្បថនៅទី -- នៅកន្លែងដំបងដែករបស់សវនាការរួចហើយ។

**ស៖** បាទ អរគុណ។ ហើយឥឡូវនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកចូលរួមសវនាការជាសាក្សី។ លោក ព្រុំ សារ៉ាត ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវ-នាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើការរៀបរាប់ណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច លោក ព្រុំ សារ៉ាត ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយ ឬក៏រៀបរាប់របស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ហើយម្យ៉ាងទៀត ក្នុងឋានៈលោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោក ព្រុំ សារ៉ាត តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក? ហើយបើសិនបើមាន តើធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណាខ្លះ?

[១៥:១៤:៤២]

**ឆ៖** បាទ ខ្ញុំបាទបានធ្លាប់ចូលសម្ភាសជាមួយអ្នកស៊ើប យកព័ត៌មានមួយនៅវាលស្រែរបស់ខ្ញុំនៅឆ្នាំ២០០៧ ហើយក្រោយមកទៀត បានមកឆ្លើយនៅក្នុងជាសាក្សីនៅថ្ងៃ២៥ ចប់នៅថ្ងៃ២៩ ខែមេសា ឆ្នាំ២០១៤។

**ស៖** បាទ អរគុណ។ នៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាន ឬក៏ស្តាប់ការអានពីបុគ្គលណាម្នាក់នូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទបានអាន និងបានពិនិត្យនូវឯកសារដែលខ្ញុំបានឆ្លើយនូវលើកទី១ និងលើកទី២។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាព ដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានដែលទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីចង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលនោះដែរឬទេ?

**ឆ៖** បាទ ចម្លើយដែលខ្ញុំបានអាន ហើយនិងពិនិត្យនូវឯកសារពាក់ព័ន្ធដល់ចម្លើយរបស់ខ្ញុំលើកទី១ និងលើកទី២ វាជាការសមស្របទៅតាមអ្វីដែលខ្ញុំបានចងចាំពីមុន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា សួរដេញដោលសាក្សី ព្រុំ សារ៉ាត មុនភាគីដទៃទៀតក្នុងរឿងក្តី។ ហើយមេធាវីការពារក្តីទាំងពីរក្រុម មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការសួរសាក្សីរូបនេះ ដោយវគ្គដំបូងគឺ -- និងវគ្គចុងក្រោយនៃថ្ងៃសវនាការ។ ឥឡូវនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៥:១៧:២៨]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំនឹងសួរសំណួរមួយចំនួនទៅលោកនៅល្ងាចនេះ ហើយនិងស្អែកទៀត។ ខ្ញុំចាប់ផ្តើម ដោយសួរឲ្យលោក សុំឲ្យលោករៀបរាប់អំពីសកម្មភាពយោធារបស់លោកមុនថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ តើលោកចូលបដិវត្តន៍នៅថ្ងៃណា? ចូលនៅពេលណា...។ល។?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** បាទ ខ្ញុំបាទសូមរាប់រៀបអំពីសកម្មភាពយោធារបស់ខ្ញុំ ដែលបានធ្វើសកម្មភាពនៅមុនឆ្នាំ៧៥។ ខ្ញុំបាទចូលបដិវត្តន៍នៅថ្ងៃទី០៦ ខែ៩ ១៩៧០ ហើយចូលនៅក្នុងកងទ័ពតំបន់កំពត។

**ស៖** តើលោកចាំនៅកងពលលេខប៉ុន្មានទេ ដែលនៅក្នុងតំបន់កំពតកាលនោះ?

**ឆ៖** បាទ ខ្ញុំចូលនៅក្នុងតំបន់កំពត ពេលនោះមិនទាន់រៀបចំជាកងពលទេ កម្រិតត្រឹមកងតំបន់របស់ -- ប្រចាំនៅខេត្តកំពត។

**ស៖** បាទ ត្រឹមត្រូវ។ តើលោកដឹងទេ នៅពេលណាដែលកងកម្លាំងនិរតីនៅកំពត បានក្លាយទៅជា គេបញ្ចូល ឬក៏បង្រួមគ្នាបង្កើតជាកងពល តើលោកនៅចាំទេ នៅពេលណា?

**ឆ៖** បាទ ខ្ញុំចាំមិនបានថ្ងៃខែទេ តែខ្ញុំចាំនៅឆ្នាំ១៩៧៤ រៀបជាកងពលទី៣ ភូមិភាគនិរតី។

**ស៖** ខ្ញុំឮលោកនិយាយថា ១៩៧៩។ បាទ អ៊ីចឹងគឺថា តើមុនឆ្នាំ១៩៧៥ ដែលលោកចង់កែតម្រូវ ឬយ៉ាងម៉េច ខ្ញុំស្ដាប់ទៅឮអ៊ីចឹង?

**ឆ៖** ខ្ញុំសុំបញ្ជាក់ម្ដងទៀត។ ខ្ញុំចេញពីកងទ័ពតំបន់កំពត មកចូលជាកងទ័ពភូមិភាគនិរតី រៀបចំជាកងពលនៅឆ្នាំ១៩៧៥។ ហៅថាកងពលលេខ៣។

**ស៖** បាទ អរគុណ។ តើលោកស្គាល់មេបញ្ជាការកងពលលេខ៣ឈ្មោះអ្វីឬទេ?

**ឆ៖** បាទ ខ្ញុំពេលនោះខ្ញុំស្គាល់គាត់ មេបញ្ជាការកងពលលេខ៣ គាត់ឈ្មោះ មាស មុត។

**ស៖** ខ្ញុំនឹងនិយាយពីមេបញ្ជាការផ្សេងៗទៀតឈ្មោះ សឿត ក្នុងពេលខាងមុខ។ ឥឡូវនេះខ្ញុំត្រឡប់មកពេលវេលាជាក់លាក់មួយ។ តើលោកនៅចាំឬទេថា តើកងពលរបស់លោកហ្នឹងចូលពាក់ព័ន្ធនៅក្នុងការវាយប្រហារទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ឬទេ?

**ឆ៖** បាទ កងពលរបស់ខ្ញុំបានមានការជាប់ពាក់ព័ន្ធវាយប្រយុទ្ធនៅសមរភូមិភ្នំពេញនៅឆ្នាំ១៩៧៥។ វាជាការពិត។

[១៥:២១:៤៥]

**ស៖** តើរូបលោកផ្ទាល់បានចូលរួមនៅក្នុងការវាយប្រហារនោះទេ? គឺចូលរួមនៅក្នុងការវាយប្រយុទ្ធ ដើម្បីចូលកាន់កាប់ទីក្រុងភ្នំពេញកាលនោះឬទេ?

**ឆ៖** បាទ ខ្លួនខ្ញុំបាទបានចូលរួម។

**ស៖** សូមលោករៀបរាប់ដោយសង្ខេបជូនតុលាការ តើសកម្មភាពជាក់លាក់ថា តើផ្នែកណានៃការវាយប្រហារ ឬក៏ចំណុចណាដែលលោកវាយប្រហារចូលមកនោះ?

**ឆ៖** បាទ មុខសញ្ញារបស់ខ្ញុំបាទ គឺចូលវាយខ្ញុំពេលនោះខ្ញុំចាំបានថា ជាប់នឹងសមរភូមិ ហៅថាម៉ុងចិន តែម្ដុំខាងកើតត្នោតពង បាទ។

**ស៖** តើលោកមានឋានៈជាអ្វីនៅពេលនោះ នៅក្នុងកងពលរបស់លោកដែលវាយប្រហារចូល

ភ្នំពេញ តើលោកមានឋានៈជាអ្វីកាលនោះ?

**ឆ៖** បាទ ខ្ញុំពេលនោះ ខ្ញុំមានឋានៈជាប្រធានកងអនុសេនាធំ។

**ស៖** តើមានសមាជិកប៉ុន្មានដែលឋិតនៅក្រោមការបញ្ជារបស់លោក ជាពិសេសយុទ្ធជនដែលក្រោម ដែលឋិតនៅក្រោមការបញ្ជា ការដឹកនាំរបស់លោក?

**ឆ៖** បាទ ខ្ញុំបាទមានទាហានសរុបរួមចំនួន ១០០នាក់។

**ស៖** ហើយតើលោកចាំដែរឬទេ តើមានកងអនុសេនាធំប៉ុន្មាននៅក្នុងវរសេនាតូច? ហើយមានវរសេនាតូចប៉ុន្មាន នៅក្នុងកងពលធំ ដែលលោកនៅក្នុងនោះ?

**ឆ៖** តាមខ្ញុំចាំ ក្នុងកងពលរបស់ខ្ញុំ កងពលលេខ៣ មានតែបីវរសេនាធំ។ សូមបញ្ជាក់ ក្នុងកងពលលេខ៣ មានបីវរសេនាធំ។

**ស៖** ហើយតើមានវរសេនាធំមួយមានបួនវរសេនាតូចនៅក្នុងហ្នឹង ត្រឹមត្រូវអីចឹងទេ លោកសាក្សី?

**ឆ៖** តាមខ្ញុំចាំ មួយវរសេនាធំមានតែបីវរសេនាតូចទេ បាទ។

[១៥:២៥:០៣]

**ស៖** តើត្រឹមត្រូវដែរឬទេនៅក្នុងកងអនុសេនាតូចរបស់លោកមានកងអនុសេនា -- អ៎! មានអនុសេនាតូចបីដែលឬទេ?

**ឆ៖** ក្នុងកងអនុសេនាធំរបស់ខ្ញុំមានកងអនុសេនាតូចបីកង។

**ស៖** តើកងអនុសេនាធំរបស់លោកបានទទួលការរងរបួស ឬក៏ស្លាប់ដែរឬទេសមាជិកនោះពេលដែលវាយចូលទីក្រុងភ្នំពេញកាលនោះ?

**ឆ៖** កងអនុសេនាធំរបស់ខ្ញុំបាទ ពេលវាយចូលសមរភូមិភ្នំពេញពេលនោះ ការរបួស និងស្លាប់វាជាការប្រយុទ្ធមានការស្លាប់និងរបួសជាប់រៀងរាល់ថ្ងៃបាទ។

**ស៖** តើលោកនៅចាំដែរឬទេ តើមានយុទ្ធជនប៉ុន្មាននាក់នៅក្នុងកងអនុសេនាធំរបស់លោកដែលបានពលី ពេលដែលវាយប្រហារចូលទីក្រុងភ្នំពេញកាលនោះ?

**ឆ៖** បាទ កងអនុសេនាធំរបស់ខ្ញុំ ពេលនោះខ្ញុំចាំមិនបានទេព្រោះពេលវេលាវា៤0ឆ្នាំជាងហើយបាទ។

**ស៖** ខ្ញុំយល់មិនមានបញ្ហាទេ ខ្ញុំនឹងសួរពីរបីសំណួរទៀត ជាពិសេសអំពីសប្តាហ៍ ឬក៏ប៉ុន្មានថ្ងៃ

បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកនៅចាំទេ តើលោកទៅណានៅពេលដែលទីក្រុងភ្នំពេញបានដួលរលំហើយ? ជាពិសេសគឺបន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥?

**ឆ៖** បាទ ក្រោយពីទីក្រុងភ្នំពេញបានដួលរលំ ខ្ញុំបាទទទួលបទបញ្ជាពីថ្នាក់លើ នាំកងទ័ពអនុសេនាធំរបស់ខ្ញុំ ធ្វើដំណើរទៅកាន់សមរភូមិកំពង់សោមដោយថ្មើរជើងពីកំបូល រហូតទៅដល់វាលរេញ ទើបមានឡានដឹកចូលក្រុងកំពង់សោម។

**ស៖** តើត្រឹមត្រូវដែរឬទេកងអនុសេនាធំរបស់លោកគឺថា ប្រើពេលប្រាំថ្ងៃមុនទៅដល់ក្រុងកំពង់សោម ទាល់តែថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ បានទៅដល់ក្រុងកំពង់សោម។ តើត្រូវដែរឬទេ?

**ឆ៖** បាទ ត្រូវ។

**ស៖** ខ្ញុំនឹងសួរលោកអំពីបញ្ហាជាក់លាក់ដែលកើតឡើងក្នុងរយៈពេលប្រាំថ្ងៃបន្ទាប់ពីរថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ទៅនោះ។ តើលោកនៅចាំដែរឬទេ ថាតើនៅពេលដែលធ្វើដំណើរក្នុងកងអនុសេនាធំទៅកំពង់សោម តើមានការវាយប្រហារ ឬក៏ការពួនស្ទាក់តាមផ្លូវដោយកងទ័ពលន់ នល់ ដែរឬទេ ទៅលើកងអនុសេនាតូចរបស់លោក?

[១៥:២៨:៥៩]

**ឆ៖** បាទ នៅពេលដែលខ្ញុំធ្វើដំណើររយៈពេលប្រាំឆ្នាំ ខ្លួនខ្ញុំមិនបានជួបការប្រយុទ្ធនៅសមរភូមិដោយមានការពួនស្ទាក់ពីរកងកម្លាំងរបស់លោក លន់ នល់ទេបាទ។

**ស៖** ខ្ញុំគិតថាលោកនិយាយប្រាំថ្ងៃ មិនមែនប្រាំឆ្នាំទេ។ ខ្ញុំអានចម្លើយរបស់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកប្រធាន E3/9113, អង់គ្លេសទំព័រ១៧ ERN00974170, ខ្មែរ00926353។ មិនមានអត្ថបទបកប្រែជាភាសាបារាំងទេ។ សំណួរ(អ្នកស្រាវជ្រាវពីមជ្ឈមណ្ឌលឯកសារកម្ពុជា)៖ នៅពេលដែលលោកធ្វើដំណើរទៅកំពង់សោម តើមានការវាយប្រហារអ្វីដែរឬទេ? ពេលនោះលោកឆ្លើយថា យើងមានការប៉ះទង្គិចគ្នានៅដោះកញ្ជរ ពីព្រោះថានៅដោះកញ្ជរនោះ មិនទាន់បរាជ័យនៅឡើយទេ ពួក លន់ នល់នោះ។ នៅពេលនោះ នរោត្តម ច័ន្ទ រង្សី នៅទីនោះ។ គេមិនទាន់លើកទង់ជ័យសនៅឡើយទេ ពីព្រោះគេមានដំណើរទៅបរទេស។ ហើយយើងធ្វើដំណើរទៅ ក៏យើងជាន់មីនដែរ។ ខ្ញុំបានឮស្នូរមីនផ្ទុះ ហើយខ្ញុំបានឃើញទាហានលើកទង់ជ័យសនៅក្នុងព្រៃជាសញ្ញាថា១ នរោត្តម ច័ន្ទ រង្សី បានរងរបួស។” បញ្ចប់សេចក្ដីដកស្រង់។ តើលោកនៅចាំថា លោកបានឆ្លើយចម្លើយនេះ ប្រាប់ទៅអ្នកស៊ើបអង្កេត ឬអ្នកស្រាវជ្រាវមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆ៖** បាទ ឯកសារនេះ ខ្ញុំបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បាទ។

**ស៖** ខ្ញុំសួរលោកបញ្ជាសំណួរមួយចំនួន ជាពិសេសរយៈពេលប្រាំថ្ងៃ ដែលលោកធ្វើដំណើរហ្នឹង មានមូលហេតុពីរ។ មូលហេតុទី១ គឺ ពាក្យដែលលោកប្រើថា ការលើកទង់ជ័យស។ សូមលោកពន្យល់បន្ថែម។ តើមានអត្ថន័យដូចម្តេចនៅពេលដែលលោកនិយាយ ពួកក្រុមនោះមិនទាន់លើកទង់ជ័យសនៅឡើយទេ។ តើមានន័យថាៗ ពួកទាហានលន់នល់ លើក ឬក៏មិនលើកទង់ជ័យស ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា សមរភូមិភ្នំពេញទាំងមូល ថ្ងៃ១៧ មេសា គឺបានលើកទង់សគ្រប់ទីតាំង តែដោយឡែក នៅក្នុងទីតាំងបន្ទាយដោះកញ្ជរ គឺអត់បានលើកទេ។ ក្រោយពីខ្ញុំធ្វើដំណើរហួសដោះកញ្ជរហ្នឹងទៅ ទៅដល់ទីតាំងកំពង់សិលា ខ្ញុំមានស្នូរមីនផ្ទុះមួយគ្រាប់ បានស្តាប់សូរឮ។ សំឡេងហ្នឹង ក៏មួយសន្ទុះ ប្រហែលជាកន្លះម៉ោង ឃើញទាហានរបស់ខ្ញុំមិនទាន់ដឹងថា ជាទាហានខាងណាទេ ប៉ុន្តែដល់ឃើញ -- ក្រឡេកមើលទៅ បានឃើញកាន់ទង់សដើរចូលមកសំដៅផ្លូវ ដោយមានសែងរបួសផង។ ពេលនោះ ខ្ញុំក៏ទៅដល់ ជួបនឹងទាហានដែលសែងរបួស ហើយឃើញអ្នករបួស ហើយក៏បានសួរបញ្ជាក់ថា៖ “តើពេលដែលផ្ទុះមីនហ្នឹងជានរណា?” ទាហានក៏បានឆ្លើយប្រាប់ខ្ញុំថា៖ “ជាលោក នរោត្តម ច័ន្ទរង្សី –ទ្រង់ ច័ន្ទ រង្សី។” អ៊ីចឹងខ្ញុំ ពេលដែលខ្ញុំឮឈ្មោះទ្រង់ ច័ន្ទ រង្សី ខ្ញុំបាទមិនដែលស្គាល់ថាតើ ទ្រង់ ច័ន្ទ រង្សី រូបរាងយ៉ាងម៉េចអីទេ ប៉ុន្តែពេលដែលខ្ញុំឃើញ បានខ្ញុំដឹងថា អូ៎! នេះជា នរោត្តម ច័ន្ទ រង្សី។ ធ្លាប់ឮតែឈ្មោះ។ អ៊ីចឹង ពេលដែលខ្ញុំជួបហើយ ខ្ញុំឱ្យពេទ្យរបស់ខ្ញុំបានរុំរបួសរួច ខ្ញុំប្រាប់គាត់ថា៖ “បងប្អូនទាហានទាំងអស់ទៅមុខក៏មិនបាន អ៊ីចឹងបងប្អូនត្រូវសម្រាកនៅទីនេះ។ ខ្ញុំមិនមានភារកិច្ចជួយបងប្អូនទេ ខ្ញុំត្រូវធ្វើដំណើរឱ្យទាន់ពេលវេលារបស់ខ្ញុំ។” ខ្ញុំក៏ឆ្លងកាត់ផុតពីតំបន់នោះទៅ។ បាទ អស់។

[១៥:៣៤:១៧]

**ស៖** លោកបាននិយាយថា បានឃើញគេលើកទង់ជ័យស គឺទាហានលន់នល់ លើកទង់ជ័យសគ្រប់ទីកន្លែងនៅទីក្រុងភ្នំពេញ។ ហើយទង់ជ័យស ក៏បានត្រូវបានគេគ្រវី ឬក៏លើកនៅតំបន់ដែលលោកបានទើបតែរៀបរាប់អំមិញនេះ។ សូមលោកជម្រាបតុលាការផងមើល ថាតើមានន័យដូចម្តេច នៅថ្ងៃទី ១៧ ខែមេសា នៅពេលដែលទាហានលន់នល់គ្រវី ឬក៏លើកទង់ជ័យសនោះ? តើមានអត្ថន័យដូចម្តេចនៅក្នុងអ្វីដែលលោកយល់នោះ?

**ឆ៖** តាមខ្ញុំយល់ ពេលនោះ ខ្ញុំមើលឃើញទង់ជ័យស បានន័យថាជាទង់ជ័យមួយគឺបញ្ចប់ការប្រយុទ្ធរវាងកងកម្លាំងទាំង -- គូប្រយុទ្ធទាំងសងខាង។

**សះ** ខ្ញុំយល់។ តើគេធ្វើអ្វីបន្ទាប់ពីៗអ្នកទាំងនោះលើកទង់ជ័យស តើគេបានចាត់ការដូចម្ដេច?

**ឆះ** សំណួរ ខ្ញុំអត់ទាន់យល់។

**សះ** តើនឹងមានអ្វីកើតឡើងចំពោះទាហានលន់ នល់ ដែលបានលើកទង់ជ័យស? បាទ ថាតើខាងភាគីម្ខាងទៀតនោះ ត្រូវធ្វើដូចម្ដេចចំពោះពួកគេដែលលើកទង់ជ័យស?

**ឆះ** ភាគីម្ខាងទៀតដែលចំពោះខ្ញុំយល់ឃើញថា បើភាគីម្ខាងទៀត ដែលឃើញខាងភាគីម្ខាងទៀតលើកទង់ស ភាគីម្ខាងក៏យល់ថាជាការចប់សង្គ្រាម។

**សះ** ឥឡូវ ខ្ញុំព្យាយាមរំឭកការចងចាំរបស់លោកបន្តិចលោកសាក្សី។ លោកប្រធានខ្ញុំសូមអានសេចក្ដីដកស្រង់ពីឯកសារ E3/24 គឺជាកំណត់ហេតុស្ដាប់ចម្លើយសាក្សី របស់សាក្សីម្នាក់ដែលបានធ្វើសក្ខីកម្មនៅក្នុងរឿងក្ដី០០២/០១ បាទឈ្មោះ ភី ភួន។ អង់គ្លេស ERN 00223581, ខ្មែរ ERN 00204069, បារាំង 00503921។ លោកសាក្សី ភី ភួន បានឆ្លើយប្រាប់តុលាការដូចខាងក្រោមនេះ គាត់រៀបរាប់ពីហេតុការណ៍ដែលកើតឡើងនៅក្នុងទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ ខ្ញុំផ្ដល់ជាបរិបទបន្តិចដើម្បីឲ្យលោកដឹងថាតើគាត់និយាយពីរឿងអី។ "ខ្ញុំបានចូលភ្នំពេញនៅថ្ងៃទី២០ មេសា ឆ្នាំ១៩៧៥ ជាមួយ សុន សេន ដើម្បីពិនិត្យមើលស្ថានភាព ស្ថានការណ៍ គឺដែលប៉ុល ពត ជាអ្នកចាត់តាំង។ ខ្ញុំបានឃើញប្រជាជនចេញគ្រប់ទិសដៅ ប៉ុន្តែក្រុមទិសដៅមិនទាន់ចាកចេញនៅឡើយទេ។ សះ តើមានបញ្ជាឲ្យស្វែងរកខ្មាំងទេ? ឆះ ទេ ផ្ទុយទៅវិញ នៅពេលនោះគេប្រាប់យើងថា ឲ្យយើងប្រុងប្រយ័ត្នកងទ័ពដែលលាក់ខ្លួននៅក្នុងផ្ទះ ទោះបីកងទ័ពភាគធំត្រូវបានកម្ទេចហើយក៏ដោយ។ សះ តើមានបញ្ជាដើម្បីស្វែងរកទាហានលន់ នល់ ដែរឬទេ? ឆះ ទេ ពីព្រោះពួកគេបានលើកទង់ជ័យសរួចហើយ មានការណែនាំច្បាស់ថាមិនឲ្យប៉ះពាល់ ឬក៏ធ្វើម៉េចប៉ះពាល់ពួកគេទេ ចំពោះ នៅក្នុងសមរភូមិផ្សេងដោយសារពួកគេលើកទង់ជ័យសចុះចាញ់ យើងមិនត្រូវប៉ះពាល់ពួកគេទេ យើងត្រូវស្វាគមន៍ ហើយនិងទទួលពួកគេ ហើយនិងឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលគេសួរពួកយើង។ គាត់និយាយថា ពួកគេជាជនជាតិខ្មែរដូចតែយើងទេ កុំប៉ះពាល់ពួកគេធ្វើអី នេះជាពាក្យចេញពីមាត់របស់ប៉ុល ពត។" លោកសាក្សីដើម្បីបញ្ចប់សេចក្ដីដកស្រង់នេះ នៅថ្ងៃទី៣០ កក្កដា ឆ្នាំ២០១២ សាក្សីដដែលហ្នឹង ភី ភួន ត្រូវបានតទល់នៅក្នុងម៉ោង១៥:៣០ យោធាទាំងអស់ហ្នឹង -- "ទាហានទាំងអស់ហ្នឹងក៏បានចុះចាញ់លើកទង់ជ័យសហើយយើងមិនធ្វើអ្វីដើម្បីឲ្យប៉ះពាល់រូបកាយគេទេ។ យើងទទួលការណែនាំគឺមិនឲ្យប៉ះពាល់អ្នកទាំងអស់នោះទេ។" សូមបញ្ចប់សេចក្ដីដកស្រង់។ សំណួរដែលខ្ញុំត្រូវសួរលោកៗសាក្សី សក្ខីកម្មរបស់សាក្សី

ភី ភួន នេះត្រឹមត្រូវដែរឬទេ? កាលណាយើងនិយាយអំពីការប្រព្រឹត្តលើទាហានលន់ នល់ ដែលបានលើកទង់ជ័យសចុះចាញ់កាលនោះ?

**ឆះ** តាមខ្ញុំយល់ សម្ដីរបស់សាក្សី ភី ភួន ដែលបានគាត់ឆ្លើយ វាជាការត្រឹមត្រូវ ព្រោះពេលនោះ ខ្ញុំអង្គភាពខ្លួនខ្ញុំ មិនបានមានផែនការប្រយុទ្ធអីតទៅទៀតទេ ព្រោះការលើកទង់ស វាសញ្ញាប្រាប់ថាកងទ័ពទាំងអស់ ភាគីប្រយុទ្ធ ពីរភាគីគឺត្រូវបានបញ្ចប់ជាស្ថាពរហើយ។ ដូច្នេះ ខ្ញុំឯកភាពទាំងស្រុងលើកចម្លើយរបស់ ភី ភួន។

[១៥:៤០:៥៥]

**សះ** តើលោកដឹងថា មានការសម្លាប់ទាហានលន់ នល់ ដែលបានសុំចុះចាញ់ដែរឬទេ ទោះជាក្នុងកងអនុសេនាធំលោក ឬក៏នៅក្នុងកងវរសេនាធំ ឬក៏អនុសេនាធំរបស់លោកក្ដី មានទេ?

**ឆះ** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំធ្វើដំណើរពីភ្នំពេញទៅកំពង់សោម សម្រាប់កងនិងអង្គភាពរបស់ខ្ញុំ ខ្ញុំអត់មានប៉ះពាល់ដល់ពលទាហានរបស់លោក លន់ នល់ សូម្បីតែម្នាក់ក៏គ្មានដែរបាទ ក្រោយថ្ងៃ១៧ មេសា ១៩៧៥។

**សះ** តើលោកដឹងថា មានគេសម្លាប់ទាហានលន់ នល់ ដែរទេ ក្រោយសង្គ្រាមចប់ទៅឧទាហរណ៍ដូចជាការសម្លាប់មន្ត្រីលន់ នល់ មន្ត្រីរដ្ឋការលន់ នល់ ក្នុងឆ្នាំ១៩៧៥ ឬក៏ក្នុងឆ្នាំ១៩៧៦?

**ឆះ** ចម្លើយ ខ្ញុំសូមបញ្ជាក់ថា វាគ្រាន់តែជាការឮ។ ការឮនេះ វាជាការណ៍មួយដែលកើតឡើងនៅក្រោយពេលដែលខ្ញុំបំពេញភារកិច្ច កាតព្វកិច្ចថ្មីរបស់ខ្ញុំ គឺពេលដែលខ្ញុំហាត់ហ្វឹកហ្វឺនកងទ័ពជើងទឹកនៅកំពង់សោម។

**សះ** សូមអរគុណលោកសាក្សី។ សំណួរមួយទៀត ទាក់ទងទៅនឹងសម្រង់របស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ព័ន្ធទៅនឹង នរោត្ដម ច័ន្ទ រង្សី។ តើ នរោត្ដម ច័ន្ទ រង្សី ជាមេបញ្ជាការជាន់ខ្ពស់ អាចថាជាមេបញ្ជាការកងពលតូចក៏ថាបាន លោកដឹងទេ នៅក្នុងរបបលន់ នល់ គាត់មានឋានៈ ជាមេបញ្ជាការបុណ្យស័ក្ដិធំប៉ុនណាដែរ?

**ឆះ** ខ្ញុំដឹងឈ្មោះថា នរោត្ដម ច័ន្ទ រង្សី ក្នុងរបបលន់ នល់ លោកមានឋានៈជាឧត្ដមសេនីយ៍ ក្នុងកងពលថ្មើជើងលេខ១៣។

[១៥:៤៣:៥២]

**សះ** ខ្ញុំមានសំណួរច្រើនណាស់ពាក់ព័ន្ធនឹង ច័ន្ទ រង្សី នេះ ប៉ុន្តែដោយសារតែពេលវេលា។ តើ

លោកដឹងទេថា នៅក្នុងឆ្នាំ -- ពីឆ្នាំ១៩៧៥ ដល់ ៧៩ នោះថាតើ នរោត្តម ច័ន្ទរង្សី មានទំនាក់ទំនងជាមួយ សឹង ង៉ុកថាញ់ ដែរទេ លោកដឹងទេ?

**ឆ៖** ចម្លើយ ខ្ញុំបាទ ព័ត៌មាននេះ ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែតើខ្លួនលោកផ្ទាល់ធ្លាប់ដែលឮឈ្មោះ សឹង ង៉ុកថាញ់ ហ្នឹងដែរទេ លោក?

**ឆ៖** ខ្លួនខ្ញុំផ្ទាល់ធ្លាប់ឮឈ្មោះ សឹង ង៉ុកថាញ់។

**ស៖** ចុះលោកឮអ្វីខ្លះទៀតដែរទេ ក្រៅពីគ្រាន់តែឮឈ្មោះគាត់?

**ឆ៖** ខ្ញុំមិនមានដែលឮអីទៀតទេ។

**ស៖** ខ្ញុំមិនបញ្ហាអ្វីទេលោកសាក្សី។ ខ្ញុំនឹងសួរអំពីគាត់នេះឡើងវិញទៀត ប្រហែលជានៅថ្ងៃស្អែក។ ខ្ញុំសួរលោកអំពីវគ្គរៀនសូត្ររបស់លោកជាមួយ សុន សេន។ ឥឡូវនេះ ខ្ញុំសួរអំពីកងពល១៦៤ តើនៅក្នុងកងពល១៦០ -- កងពលលេខ៣នេះ តើមានពេលណាមួយនេះ លោកគឺជាមេបញ្ជាការកងអនុសេនាធំនៅក្នុងកងពលលេខ៣នេះដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:៤៦:០៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សំណួរនេះដូចជាមិនត្រឹមត្រូវទេ។ ខ្ញុំស្តាប់ឮថាតើកងពលលេខ៣ហ្នឹង នៅពេលណាមួយហ្នឹងបានក្លាយទៅជាកងពល១៦៤ ឬក៏យ៉ាងម៉េច។ គួរតែនិយាយថា កងពលមជ្ឈិមវិញ។ កងពល១៦៤ហ្នឹង ជាកងទ័ពជើងទឹក។ ដូច្នេះ ខ្ញុំគិតថា គួរតែរៀបចំសំណួរនេះឲ្យច្បាស់ជាងនេះបន្តិចឡើងវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនបញ្ហាអ្វីទេ។ មានភស្តុតាងពេញលេញដែលអាចឲ្យសួរបែបនេះ ប៉ុន្តែខ្ញុំរីករាយណាស់ក្នុងការដែលសួរសំណួរបើកចំហដើម្បីឲ្យវាកាន់តែលឿនទៅមុខ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើមានពេលណាមួយនោះ លោកក្លាយទៅជាសមាជិកកងពល សមាជិកទាហានកងទាហានកងទ័ព កងពល១៦៤ ដែរទេ?

លោក ព្រុំ សារ៉ាត៖

**ឆ៖** ខ្ញុំចាំបាននៅខែ៦ ឆ្នាំ១៩៧៦ -- សូមទោសបាទ ខែ៦ ឆ្នាំ១៩៧៥ ខ្ញុំបានក្នុងអង្គភាពខ្ញុំបានប្រែក្លាយទៅជាកងជើងទឹក នៅក្នុងកងពល១៦៤។

**ស៖** លោកសាក្សី ខ្ញុំគិតថា ត្រឹមត្រូវហើយដែលលោកនិយាយថា កងពល១៦៤ ត្រូវបានបង្កើតឡើងនៅខែមិថុនា ១៩៧៧ ពីព្រោះនៅក្នុងចម្លើយ១៩-២០ របស់លោក ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង គឺឯកសារ E319/23.3.54 លោកថា នៅក្នុងខែមិថុនា ១៩៧៦។ តើត្រឹមត្រូវទេ ដែលថាកងពល១៦៤ គឺមានកងទ័ពហ្នឹងច្រើនជាងគេ ហើយស្ថិតនៅក្រោមការបញ្ជារបស់មជ្ឈិម? អ៊ីចឹងមានអ៊ីចឹងទេ?

**ឆ៖** នេះ ខ្ញុំបញ្ជាក់ក្នុងឯកសារដែលខ្ញុំបានឆ្លើយជាមួយឯកសារក្រុមស្រាវជ្រាវរបស់ -- ស្វែងរកការពិតអង្គតុលាការ ខ្ញុំបានដាក់ក្នុងហ្នឹង គឺមាន៩០០០នាក់។

[១៥:៤៩:១៦]

**ស៖** ត្រឹមត្រូវហើយ លោកថាមានចន្លោះពី ៧០០០ ទៅ ៩០០០នាក់។ តើកងពល១៦៤ ក្នុងចំណោម -- ជាកងពលមួយក្នុងចំណោមកងពលទាំង១០ ឬទាំង១៥ របស់មជ្ឈិមហ្នឹងដែរទេ ដែលគ្រប់គ្រងដោយមជ្ឈិមហ្នឹងដែរទេ?

**ឆ៖** ក្នុងកងពល១៦៤ វាជាចំណុះក្នុងកងពលបញ្ជាដោយមជ្ឈិម។

**ស៖** តើលោកចាំទេថា នៅក្នុងកងវរសេនាធំមួយណានៃកងពល១៦៤នេះ ដែលលោកចំណុះនេះ លោកចំណុះឲ្យកងវរសេនាធំមួយណាដែរ នៃកងពល១៦៤ នៅខែមិថុនា ១៩៧៦នុ៎ង?

**ឆ៖** ខ្ញុំនៅក្នុងវរសេនាធំ១៤០ ចំណុះឲ្យកងពល១៦៤។

**ស៖** ហើយតើលោកនៅចាំទេថា កងវរសេនាធំ១៤០នេះឈរជើងនៅឯណាដែរ បោះទីតាំងនៅឯណាដែរ?

**ឆ៖** តាមខ្ញុំចាំ កងវរសេនាធំ១៤០នេះ គឺបោះទីតាំងនៅ រៀបចំកងជាលើកដំបូង គឺនៅអូរឈើទាល ក្រុងកំពង់សោម។

**ស៖** លោកបានឆ្លើយថា ចំនួនកងទ័ពសរុបនៃកងពល១៦៤ គឺចន្លោះពី៧.០០០ទៅ៩.០០០នាក់។ មានភស្តុតាងថា នៅក្នុងខែតុលា ១៩៧៦ មាន៨.៦០០នាក់។ លោកនៅចាំទេថា នៅក្នុងកងវរសេនាធំលេខ១៤០ហ្នឹង មានកងទ័ពទាំងអស់ប៉ុន្មាន? ហើយមានកងទ័ពសកម្មប៉ុន្មាន? កងទ័ពមិនសកម្មហ្នឹង

ប៉ុន្មាន?

**ឆ៖** ក្នុងវរសេនាធំ១៤០ មានកងទ័ពសរុបប្រមូល១.៤០០នាក់។ ហើយកងទ័ពដែលសកម្ម រៀបចំដំបូង គឺបាន១២០នាក់ដែលត្រៀមទទួលហាត់ហ្វឹកហ្វឺននាវានៅលើនាវា ដែលបានជំនួយមកពីចិន ប្រទេសចិន។

[១៥:៥២:៤៦]

**ស៖** តើវរសេនាធំលេខ១៤០ ត្រូវបានគេបំបែកចេញទៅជាកងវរសេនាតូច៤២, ៤៣, ៤៤ ហើយនៅក្រោយមកហ្នឹងក៏លោកក្លាយ -- ក៏លោកចំណុះឲ្យកងវរសេនាតូចសែសិប -- ជាមេបញ្ជាការរបស់កងវរសេនាតូច៤៤?

**ឆ៖** បញ្ជាក់ នៅក្នុងកងវរសេនាធំ១៤០ មានសែកងវរសេនាតូច៤១, វរសេនាតូច៤២, ៤៣, ៤៤។ ខ្ញុំចំណុះខ្លួនខ្ញុំផ្ទាល់ចំណុះនៅក្នុងកងវរសេនាតូច៤៤ អនុសេនាធំលេខ២។

**ស៖** ហើយតើលោកហ្នឹង គឺជាមេបញ្ជាការកងអនុសេនាធំលេខ២ ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំជាមេបញ្ជាការអនុសេនាធំលេខ២។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី E319/23.3.54 នៅក្នុងសំណួរចម្លើយលេខ២៥ លោកក៏បានឆ្លើយថា៖ "ពីពាក់កណ្តាលឆ្នាំ១៩៧៦ ដល់៧៩ កងវរសេនាធំលេខ១៤០ មាននាវាប្រយុទ្ធ១០ មាននាវាល្បាត១០ មាននាវាវាវមីនហ្នឹងចំនួនបួន។" តើត្រឹមត្រូវដែរទេ លោក?

**ឆ៖** បញ្ជាក់ នេះជាការត្រឹមត្រូវ។

**ស៖** សូមបញ្ជាក់ចំណុចមួយ។ លោកថា លោកជាមេបញ្ជាការកងអនុសេនាធំលេខ២ នៃកងវរសេនាធំ១៤៤ វរសេនាតូចលេខ៤០។ តើនៅក្នុងកងអនុសេនាធំលេខ២ហ្នឹង មានកងទ័ពប៉ុន្មាន ក្រោមការបញ្ជារបស់លោក?

**ឆ៖** នៅក្រោមបញ្ជារបស់ខ្ញុំ មានកងទ័ព១១០នាក់។

**ស៖** ហេតុផលដែលខ្ញុំសួរលោកសំណួរនេះ គឺថាដោយសារនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកត្រង់សំណួរចម្លើយលេខ៥៥ លោកបានឆ្លើយថា នៅពេលមួយនោះ លោកក៏បានក្លាយទៅជាមេបញ្ជាការ នាវាជើងទឹកលេខ១៧ នាវាលេខ១៧ -- បាទ គឺៗ គឺនាវាលេខ១៧ ទៅដល់លេខ១០។ នាវាទាំងអស់នេះក្រោមការបញ្ជារបស់លោក ហើយលោកទទួលខុសត្រូវបញ្ជាលើនាវិកចំនួន៣៨នាក់។ តើអ៊ីចឹងដែរឬមែនទេ?

**ធ៖** ខ្ញុំទទួលបន្ទុកជាប្រធាននាវា។ ក្នុងហ្នឹង យើងសរសេរនូវប៉ាយដាក់សញ្ញាសម្គាល់សម្រាប់នាវានីមួយៗ គឺមាន១៧-១ (ដប់ប្រាំពីរ មួយ) រហូតដល់១៧-១០ (ដប់ប្រាំពីរ ដប់)។ ខ្ញុំជាប្រធាននាវា ១៧-១០។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែនៅពេលនោះដែរនោះ តើលោកនៅតែជាមេបញ្ជាការអនុសេនាធំលេខ២ វរសេនាតូចលេខ៤០ វរសេនាធំលេខ១៤០ហ្នឹងដដែលហ្នឹងឬ?

**ធ៖** ខ្ញុំត្រូវដកឈប់បំពេញភារកិច្ចជាងអនុសេនាធំលេខ២ទៀតហើយ ខ្ញុំបានមកទទួលបន្ទុកភារកិច្ច ទទួលខុសត្រូវហាត់ហ្វឹកហ្វឺនបច្ចេកទេសជាមេបញ្ជាការនាវាកម្លាំងក្រោមបញ្ជារបស់ខ្ញុំ គឺ៣៨ រូប ជាទាហាន។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី។ សំណួរមួយចុងក្រោយសម្រាប់ថ្ងៃនេះ និយាយអំពីការតម្លើងបុណ្យស័ក្តិរបស់លោក នៅពេលដែលលោកក្លាយទៅជាមេបញ្ជាការកងនាវា១៧-១០។ តើនៅពេលហ្នឹងលោក តើបុណ្យស័ក្តិរបស់លោកហ្នឹង ឡើង ឬក៏ចុះ?

**ធ៖** ក្នុងពេលដែលខ្ញុំឡើងជាប្រធាននាវា បើខ្ញុំគិតក្នុងឋានៈរបស់ខ្ញុំពេលនោះ គឺខ្ញុំឡើងជាប្រធាននាវាបានន័យថា ខ្ញុំមានលំដាប់បច្ចេកទេស។ អ៊ីចឹងក្នុងឋានៈជាបុណ្យស័ក្តិ ខ្ញុំបានឡើងផុតពីកងថ្មើរជើងទៅជាកងទ័ពជើងទឹក ប្រយុទ្ធលើទឹក។

[១៥:៥៨:៥៤]

**ស៖** ច្បាស់លាស់ហើយលោកសាក្សី។ ឥឡូវ ខ្ញុំនិយាយអំពីសមាសភាពទូទៅនៃកងពល១៦៤។ លោកនៅចាំទេថា មានកងទ័ពមកពីភូមិភាគបូព៌ា ដែលជាផ្នែកមួយនៃកងពល១៦៤ដែរទេ មានកងទ័ពមកពីបូព៌ាមកហ្នឹង ហើយក្រោយមកហ្នឹង ក៏ក្លាយចំណុះកងពល១៦៤ដែរទេ?

**ធ៖** ចំនួនកងទ័ពដែលថ្នាក់លើចាប់បញ្ជូនមកចូលរួមជាកងទ័ពជើងទឹក ចាត់តាំងដំបូង នៅក្នុងហ្នឹងមានចំនួន៧០០នាក់ ជាកងទ័ពដែលប្រចាំនៅភូមិភាគបូព៌ា។

**ស៖** ឥឡូវ ខ្ញុំសូមអានសម្រង់ពាក់ព័ន្ធទៅនឹងចំណុចនេះ។ លោកសាក្សីគឺចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺE3/9113, ទំព័រជាអង់គ្លេសលេខ22 ERN ជាភាសាអង់គ្លេស 00 --

**អ្នកបកប្រែ៖**

លោកប្រធានសូមការអនុញ្ញាត ញាប់ពេកអត់ទាន់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកវ៉ិចទ័រ កូប៉េ ញាប់ពេកអត់ -- អ្នកបកប្រែបកអត់ទាន់ទេ លេខអត្តសញ្ញាណ លេខឯកសារ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំសូមទោសលោកប្រធាន។ គឺE3/9113 ជាចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រជាអង់គ្លេស២២, ERN 00974175, ខ្មែរ 00926358, ជាសំណួរទាក់ទងទៅនឹងអនុមេបញ្ជាការកងពលលេខ១៦៤ ឈ្មោះជិន ហេតុផលដែលថា -- ឡឿន – ឈ្មោះឡឿន។ គឺថាសំណួរសួរទៅទៀតថាដូច្នេះ “កងទ័ពមកពីភូមិភាគបូព៌ា៧០០នាក់ត្រូវបាន -- មកពីភូមិភាគបូព៌ា ក្នុងចំណោះកងវរសេនាធំលេខ១៦៤ -- ១៤០ កងពលលេខ១៦៤។ នៅត្រង់ចំណុចនេះ លោកថាកងទ័ពទាំងអស់ទាំង៧០០នាក់មកពីភូមិភាគបូព៌ា ត្រូវរើសចេញមកពីកងពលលេខ៣៧០០ ត្រឹមត្រូវទេ លោកសាក្សី?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** សំណួរ សូមបញ្ជាក់ៗម្តងទៀត ព្រោះខ្ញុំអត់ច្បាស់។ សូមបញ្ជាក់សំណួរម្តងទៀត ខ្ញុំអត់ច្បាស់សំណួរ អត់ទាន់យល់។

**ស៖** លោកបានបញ្ជាក់ថាកងទ័ពមកពីភូមិភាគបូព៌ាដែលក្លាយទៅជាសមាជិកនៃកងពលលេខ១៦៤ហ្នឹងគឺថា លោកថាកងទ័ពទាំង៧០០នាក់មកពីបូព៌ាហ្នឹងគឺជ្រើសរើស សូមដកស្រង់៖ “ចេញពីកងពល៣៧០០ គឺកងពលលេខ៣៧០០”។ តើត្រឹមត្រូវដែរទេ ថាចេញពីលេខកងពល៣៧០០ហ្នឹង?

[១៦:០២:៤៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាប្រហែលជាមានកំហុសនៅក្នុងការបកប្រែជាភាសាអង់គ្លេស តាមពិតទៅគឺកងពលលេខ៣ ហើយ៧០០ហ្នឹងជាចំនួនទាហានទេ មិនមែនមានន័យថាកងពល៣៧០០ទេ គឺថាមនុស្ស៧០០នាក់មកពីភូមិភាគបូព៌ាហ្នឹងមកចូលក្នុងកងពលទី៣។ ខ្ញុំគិតថាភាសាអង់គ្លេសគឺមិនច្បាស់ទេ ប្រហែលជាបកប្រែខុស បកឯកសារក្រដាសហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថាមិនត្រឹមត្រូវទេ កងពលលេខ៣ គឺជាកងពលមកពីភូមិភាគនិរតី។ ខ្ញុំកំពុង

តែនិយាយពីកងទ័ពភូមិភាគបូព៌ា។ តាមការបកប្រែជាភាសាអង់គ្លេសហ្នឹងថាកងទ័ពភូមិភាគបូព៌ា បីប្រាំពីរ សូន្យ សូន្យ។ ខ្ញុំឃើញសាក្សីគាត់ងក់ក្បាល អ៊ីចឹងប្រហែលជាខ្ញុំអាចត ឬក៏យ៉ាងម៉េច?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើកងទ័ពភូមិភាគបូព៌ាមកពីកងពលលេខ ៣៧០០ ឬក៏យ៉ាងម៉េចលោក?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** សូមបញ្ជាក់។ លេខកងពល៣៧០០ មិនមានទេបូព៌ា។ មានចំនួនកងទ័ព៧០០នាក់។ លេខ ៣៧០០ ខ្ញុំមិនៗៗ -- សូមថាមិនយល់ស្រប ព្រោះអត់មានបាទ។ អត់មានទេអង្កាល់ហ្នឹង។

**ស៖** យើងកំពុងតែលើសម៉ោងបន្តិចហើយ។ ប៉ុន្តែនៅក្នុងចំណោមកងទ័ពទាំង៧០០ មកពីភូមិភាគបូព៌ាហ្នឹង ក៏យកមកទៅផ្គុំគ្នាបង្កើតទៅចំណុះឲ្យកងពលលេខ១៦៤ ត្រឹមត្រូវអ៊ីចឹងដែរទេ?

**ឆ៖** ត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយមុននឹងសម្រាក។ ចង់បញ្ជាក់លោកមេធាវី វ៉ិចទ័រ កូប៉េ រួមជាមួយនឹងមេធាវីលោក ខៀវ សំផន ការតាំងសំណួរដេញដោលសាក្សីរូបនេះ តើប្រព្រឹត្តទៅយ៉ាងដូចម្ដេចនៅថ្ងៃស្អែក ព្រោះយើងបានប្រាប់ហើយ ជាគោលការណ៍គឺ ខៀវ សំផន ទាមទារសុំតាំងសំណួរនៅវគ្គចុងក្រោយនៃថ្ងៃសវនាការក្នុងការតាំងសំណួរបែបនេះ តើដោះស្រាយបញ្ហាយ៉ាងដូចម្ដេចអំពីពេលវេលា ហើយជាមួយភាគី ទាំងពីរក្រុម មេធាវីទាំងពីរក្រុមនេះ?

[១៦:០៥:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការពិតហើយ លោកប្រធាន ខ្ញុំនឹងបន្តសួរនៅថ្ងៃស្អែកទៀត ហើយមេធាវីក្រុម ខៀវ សំផន ក៏ត្រូវសួរដែរក្រោយគេនៅពេលដែលខាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខសួររួចរាល់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៦ ខែមករា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ព្រុំ សារ៉ាត ហើយនិងមានបម្រុង សាក្សីបម្រុងមួយរូបគឺ

2-TCW-849 ពាក់ព័ន្ធនឹងអង្គភាពចោទប្រកាន់ការប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ចំពោះជនជាតិវៀតណាម។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ព្រុំ សារ៉ាត សវនាការស្តាប់សក្ខីកម្មរបស់លោកនៅក្នុងឋានៈជាសាក្សីនូវមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី។ អង្គជំនុំជម្រះក៏អញ្ជើញលោកមកចូលរួមប្រឹក្សាសាក្សីរូបនេះដែលនឹងបន្តធ្វើនៅថ្ងៃស្អែកដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក ព្រុំ សារ៉ាត វិលត្រឡប់ទៅទីកន្លែងដែលគាត់ស្នាក់នៅវិញ និងសូមឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកវិញ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*